# មាគ៌ាឆ្ពោះទៅរកយុត្តិធម៌

# សិទ្ធិទទួលបានយុត្តិធម៌ ដោយផ្តោតលើ

# ជនក្រីក្រ ស្ត្រី និងជនជាតិភាគតិច

## ជំពូកទី២

## តម្រូវការយុត្តិធម៌ក្នុងសង្គម

ក្រសួងយុត្តិធម៌ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

២០០៥

# ជំពូក II
# តម្រូវការយុត្តិធម៌ក្នុងសង្គម

នៅក្នុងជំពូកនេះ យើងនឹងវិភាគអំពីមូលហេតុទាំងឡាយ ដែលនាំឱ្យមានតម្រូវការយុត្តិធម៌នៅក្នុងសង្គម ដោយយកចិត្តទុកដាក់សំខាន់ទៅលើទស្សនៈ ឬការយល់ឃើញរបស់អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច។

ដំបូងយើងនឹងលើកមកបង្ហាញពីទិដ្ឋភាពជាក់ស្តែងទូទៅ នៃស្ថានភាពរបស់ក្រុមគោលដៅ។ បន្ទាប់មកយើងនឹងបង្ហាញនូវការវិភាគ និងទិន្នន័យទាំងឡាយដែលប្រមូលបានពីសិក្ខាសាលា បទសម្ភាសន៍ និងការស្ទង់មតិដែលបញ្ជាក់ប្រាប់អំពីតម្រូវការយុត្តិធម៌ជាក់ស្តែង និងតម្រូវការយុត្តិធម៌ជាសក្តានុពលនៅក្នុងសង្គម ដូចជាវិវាទដែលកើតមានប្រចាំថ្ងៃនៅមូលដ្ឋាន ការរំលោភសិទ្ធិ និងការរំលោភអំណាច។

## មា តិ កា


១. ទិដ្ឋភាពជារួមនៃស្ថានភាពក្នុងប្រទេសដោយផ្តោតលើអ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច..........៧៥

២. ធាតុផ្សំ ឬបញ្ហានាំឱ្យមានតម្រូវការយុត្តិធម៌ក្នុងសង្គមកម្ពុជា..........៨៨

៣. វិវាទដែលកើតមាននៅក្នុងសង្គម..........៨៩

៣.១. វិវាទនៅតាមមូលដ្ឋាន..........៩១

៣.២. វិវាទទាក់ទិននឹងដីធ្លី..........៩៤

៣.៣. តម្រូវការយុត្តិធម៌ជាក់លាក់របស់ស្ត្រី : អំពើហិង្សាខាងយេនឌ័រ និងការរើសអើង..........១០០

៣.៤. បទល្មើសព្រហ្មទណ្ឌនានា..........១១៥

៤. ការរំលោភសិទ្ធិបុគ្គល និងនីតិវិធីច្បាប់..........១២២

៥. ការរំលោភសិទ្ធិសង្គម និងការរំលោភអំណាច..........១២៥

៦. តម្រូវការយុត្តិធម៌នៅក្នុងសហគមន៍ជនជាតិដើមភាគតិច..........១៣០

៧. តម្រូវការយុត្តិធម៌ក្នុងសង្គមជាក់ស្តែង : លក្ខណៈវិនិច្ឆ័យនៃតម្រូវការយុត្តិធម៌..........១៣៦

៧.១. កម្មវត្ថុនៃរឿងក្តី និងក្របខ័ណ្ឌច្បាប់..........១៣៦

៧.២. អត្ថិភាពនៃស្ថាប័ន : ភាពនៅជិត និងការស្គាល់ច្បាស់..........១៣៩

៧.៣. ការយល់ដឹងផ្នែកវប្បធម៌ និងលទ្ធភាពនៃការចរចារ..........១៤០

# ១. ទិដ្ឋភាពជារួមនៃស្ថានភាពក្នុងប្រទេស ដោយផ្ដោតលើអ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច

អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ជាក្រុមដែលស្ថិតក្នុងលក្ខខ័ណ្ឌជីវភាពរស់នៅ ជាអ្នកបាត់បង់ផលប្រយោជន៍ ដោយសារការខ្វះខាតខាងសេដ្ឋកិច្ចសង្គម បញ្ហាហិង្សា យេនឌ័រ និងការរើសអើង ព្រមទាំងការបដិសេធជាតិពន្ធុដែរ។ កត្តាទាំងអស់នេះជះឥទ្ធិពលដោយផ្ទាល់ដល់សិទ្ធិទទួលបានយុត្តិធម៌ ដើម្បីការពារសិទ្ធិរបស់ពួកគេ។ ម្យ៉ាងទៀត សិទ្ធិទទួលបានយុត្តិធម៌ជាឧបករណ៍មួយយ៉ាងសំខាន់ ក្នុងការកែលំអការការពារសិទ្ធិមនុស្ស និងលុបបំបាត់ស្ថានភាពបាត់បង់ផលប្រយោជន៍ក្នុងសង្គម[៦៧]។

ប្រទេសកម្ពុជាស្ថិតនៅខាងត្បូងឆៀងខាងលិចឧបទ្វីបឥណ្ឌូចិន ចំងាយពីខ្សែអេក្វាទ័រប្រហែល ១០អង្សា។ ប្រទេសនេះមានព្រំប្រទល់ជាមួយនឹងឈូងសមុទ្រថៃ ប្រទេសថៃ វៀតណាម និងឡាវ។ ប្រទេសនេះរួមមាន ២០ខេត្ត និង ៤ក្រុង[៦៨]។

អ្នកក្រីក្រនៅតាមតំបន់ជនបទ

វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា (NIS) បានប៉ាន់ស្មានប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេសថាមានចំនួន ១៣,៨ លាននាក់ នៅឆ្នាំ២០០៥[៦៩]។ ពាក់កណ្ដាលនៃប្រជាពលរដ្ឋមានអាយុតិចជាង១៩ឆ្នាំ (៥០%)[៧០]។ ភាគច្រើននៃប្រជាពលរដ្ឋ (៨៤%) រស់នៅតំបន់ជនបទ[៧១] ហើយកម្លាំងពលកម្មភាគច្រើនរបស់ប្រទេស (៧៥%) គឺឋិតក្នុងផ្នែកកសិកម្ម។ មានតែ ២១% នៃផ្ទៃដីក្នុងប្រទេសប៉ុណ្ណោះ ដែលអាចធ្វើការដាំដុះបាន[៧២] ហើយវិស័យកសិកម្មបានរួមចំណែកត្រឹមតែមួយភាគបី នៃផលិតផលក្នុងស្រុកសរុប(៣៥%) ដែលមានន័យថាចំណូលរបស់កសិករ មានកម្រិតតិចជាងចំណូលពីវិស័យដទៃទៀត[៧៣]។ ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ៗ (GNI) មានប្រហែល ៣០០ ដុល្លារអាមេរិក ឬ ០,៨២ដុល្លារអាមេរិកក្នុងមួយថ្ងៃ[៧៤]។ ប្រជាពលរដ្ឋភាគច្រើនបំផុតដែលរស់នៅតាមតំបន់ជនបទ ប្រកបរបរចិញ្ចឹមជីវិតដោយធ្វើកសិកម្ម ហើយ៨៥% ក្នុងចំណោមពួកគេឋិតក្នុងភាពក្រីក្រ[៧៥]។ សិទ្ធិប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ គឺជារឿងសំខាន់ក្នុងការចិញ្ចឹមជីវិត ហើយជារឿយៗវាក៏ជាប្រភព

---

៦៧ ស្ថានភាពនៃសង្គម-សេដ្ឋកិច្ច យេនឌ័រ និងអត្ថប្រយោជន៍ជាតិពន្ធុ ត្រូវការយកចិត្តទុកដាក់ដោយកំណែទម្រង់យុត្តិធម៌ដើម្បី ធានាថាកំណែទម្រង់យុត្តិធម៌អាចដោះស្រាយបានពិតប្រាកដនូវស្ថានភាពបាត់បង់ផលប្រយោជន៍នៅក្នុងសង្គមទាំងនេះ។

៦៨ សូមមើលតារាងខាងក្រោម។

៦៩ វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា (NIS)-គេហទំព័រ: http://www.nis.gov.kh/SURVEYS/CDHS2000/AboutCDHS2001.htm (ថ្ងៃចូលមើលគេហទំព័រ: ២៥ មេសា ២០០៥)។ ចាប់ពីពេលនេះតទៅត្រូវសរសេរ: គេហទំព័រ វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា (NIS)

៧០ គេហទំព័រ វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា (NIS)

៧១ ប្រជាពលរដ្ឋរស់នៅតាមជនបទមានប្រមាណ ៨៤,៣ % ហើយប្រជាពលរដ្ឋនៅទីប្រជុំជនមានប្រមាណជា ១៥,៧% នៃប្រជាពលរដ្ឋទាំងអស់។ គេហទំព័រ វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា (NIS)

៧២ ព្រៃឈើគ្របដណ្ដប់លើផ្ទៃដីប្រមាណជា ៥៣ % នៅកម្ពុជា។ សូមមើលគេហទំព័ររបស់ព្រះរាជាណាចក្រកម្ពុជា: http://www.cambodia.gov.kh/unisql1/egov/english/country.land&resource.html. (ចាប់ពីពេលនេះទៅត្រូវសរសេរ: គេហទំព័ររបស់ព្រះរាជាណាចក្រកម្ពុជា ( KCW )

៧៣ ផលិតផលក្នុងស្រុកសរុប តាមវិស័យ(ប៉ាន់ប្រមាណនៅឆ្នាំ ២០០៣): កសិកម្ម ៣៥% ឧស្សាហកម្ម ៣០% សេវាកម្ម ៣៥% *USA World Factbook.*

៧៤ ធនាគារពិភពលោក (២០០២): ឯកសារទិន្នន័យស្ដីពីព្រះរាជាណាចក្រកម្ពុជា។ គេហទំព័រ: http://www.worldbank.org/data/countrydata/countrydata.html (ថ្ងៃចូលមើលគេហទំព័រ ២៥ មេសា ២០០៥)។ ចាប់ពីពេលនេះទៅត្រូវសរសេរ: គេហទំព័រ ធនាគារពិភពលោក (WB)

៧៥ អង្គការ FAO, ឆ្នាំ ១៩៩៧ ដកស្រង់ដោយ លោក Kirjavainen, Leena M.: *Gender Issues. Cambodia*. Regional Environmental Technical Assistance 5771. Poverty Reduction & Environmental Management in Remote Greater Mekong Subregion (GMS) Watersheds (Phase I). ១៩៩៩ ទំព័រ ១៥ ។ ចាប់ពីពេលនេះទៅត្រូវសរសេរ: *Kirjavainen*

នៃជម្លោះដែរ។ ក្នុងចំណោមប្រជាកសិករ ៦៥%គឺ ជាស្ត្រី[៧៦]។ នៅឆ្នាំ ២០០៤ មាន ៤០% នៃប្រជាពលរដ្ឋដែលត្រូវបានគេប៉ាន់ស្មានថារស់នៅក្រោមបន្ទាត់ភាពក្រីក្រ[៧៧]។

អាយុជាមធ្យម គឺ ៥៤ឆ្នាំ (១៥ឆ្នាំ ទាបជាងនៅវៀតណាម និងថៃ) ហើយអត្រាអនក្ខរកម្មសរុប (អាយុ១៥ឆ្នាំឡើងទៅ) មានដល់ ៣១%[៧៨] ដែលអត្រានេះខ្ពស់ជាងប្រទេសផ្សេងៗទៀតនៅក្នុងតំបន់។ យោងតាមសន្ទស្សន៍អភិវឌ្ឍមនុស្ស (HDI) ប្រទេសកម្ពុជាឋិតក្នុងលំដាប់លេខរៀងទី ៧៤ ក្នុងចំណោមប្រទេស កំពុងអភិវឌ្ឍន៍ទាំង៩៥ប្រទេសដែលគេបានសិក្សា។ សមាមាត្រភាគច្រើននៃប្រជាពលរដ្ឋកម្ពុជា គឺស្ថិតនៅក្រោមខ្សែបន្ទាត់មាត្រដ្ឋាន នៃការអភិវឌ្ឍមនុស្ស ដូចជាការរស់នៅមានអាយុវែង និងជីវិតប្រកបដោយសុខភាពល្អ បានទទួលការអប់រំ និងកម្រិតជីវភាពល្អប្រសើរ[៧៩]។

សេវាសាធារណៈដូចជាផ្នែកអប់រំ សុខាភិបាល និងយុត្តិធម៌ មានការខ្វះខាតធនធានមនុស្ស សម្ភារៈ និងហិរញ្ញវត្ថុ។ ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ មានការលំបាកក្នុងការទទួលបានសេវាទាំងនោះ ដោយសារស្ថានភាពផ្លូវមានការលំបាក និងកង្វះខាតការដឹកជញ្ជូនសាធារណៈ ដែលខូចខាតខ្លាំងនៅរដូវភ្លៀង (មានតិចជាង១/៤នៃផ្លូវជាតិធំៗ និងមានផ្លូវនៅតាមជនបទតិចតួចប៉ុណ្ណោះដែលគេបានចាក់កៅស៊ូស្អាត)[៨០]។ មន្ត្រីរាជការទាំងអស់ (ដូចជាគ្រូបង្រៀន គិលានុប្បដ្ឋាក នគរបាល និងក្រឡាបញ្ជីតុលាការ) ទទួលបានប្រាក់ចំណូលទាបណាស់ (តិចជាងមួយដុល្លារក្នុងមួយថ្ងៃ)។

**តារាងទី១: ទិន្នន័យទូទៅនៃព្រះរាជាណាចក្រកម្ពុជា**

| ប្រទេស | ព្រះរាជាណាចក្រកម្ពុជា | ដកស្រង់ពី [៨១] |
|---|---|---|
| **ទីតាំងភូមិសាស្ត្រ** | ស្ថិតនៅតំបន់អាស៊ីភាគអាគ្នេយ៍ និងប៉ែកនីរតីនៃឧបទ្វីបឥណ្ឌូចិន មានព្រំប្រទល់ជាប់ជាមួយឈូងសមុទ្រថៃ (ជាប់សមុទ្រប្រមាណ ៤៤៣គ.ម) ប្រទេសថៃ (៨០៣គ.ម) វៀតណាម(១២២៨ គ.ម) និងប្រទេសឡាវ(៥៤១ គ.ម)។ វាលាតសន្ធឹងនៅក្នុងតំបន់ត្រូពិកទាំងស្រុង ដែលស្ថិតនៅខាងលើខ្សែស្របទី១០ ខាងលើខ្សែរអេក្វាទ័រ។ | ប្រភពទី១ |

៧៦ *Kirjavainen.* ១៩៩៩ ទំព័រ ៨

៧៧ *USA World Factbook.*

៧៨ ធនាគារពិភពលោក ឆ្នាំ ២០០២

៧៩ UNDP: Human Development Report 2004. UNDP, p. 67 and 132, គេហទំព័រ http://hdr.undp.org/statistics/data/country_fact_sheets/cty_fs_KHM.html (UNDP: *HDR 2004*).

៨០ សូមមើលតារាង, *USA World Factbook.*

៨១ ប្រភពទី១: USA Government: *The World Factbook, Cambodia,* គេហទំព័រ http://www.cia.gov/cia/publications/factbook/geos/cb.html (ថ្ងៃចូលមើល ២៥ មេសា ២០០៥)

ប្រភពទី២: UNIFEM,WB, ADB, UNDP and DFID/UK : *A fair share for women, Cambodia Gender Assessment.* Phnom Penh, UNIFEM, WB, ADB, UNDP and DFID/UK, 2004.

ប្រភពទី៣: វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា (NIS), គេហទំព័រ http://www.nis.gov.kh/SURVEYS/CDHS2000/AboutCDHS2001.htm (ថ្ងៃចូលមើល ២៥ មេសា ២០០៥)

ប្រភពទី៤: Oxfam: Mekong Land and Forests - Cambodia Information, at http://www.oxfammekong.org/graphics_pages/land_and_forest/Countries/Cambodia.htm (ថ្ងៃចូលមើល ២៥ មេសា ២០០៥)

ប្រភពទី៥: http://www.nis.gov.kh/areaname/area_name.htm

ប្រភពទី៦: http://www.worldbank.org/data/countrydata/countrydata.html

ប្រភពទី៧: ប្រកាសលេខ ៤៩៣ ប្រ.ក ស្តីពីចំនួន ឈ្មោះ និងព្រំប្រទល់របស់ឃុំ និងសង្កាត់ទាំងអស់នៃកម្ពុជា

ប្រភពទី៨: គេហទំព័ររបស់ក្រសួងអប់រំ យុវជន និងកីឡា http://www.moeys.gov.kh/profile/edu_in_cambodia/country_background.htm (ថ្ងៃចូលមើល : ខែមិថុនា ឆ្នាំ ២០០៥)

<table>
<tr><td>ផ្ទៃក្រឡា</td><td colspan="3">សរុប : ១៨១.០៣៥ គីឡូម៉ែតក្រឡា</td><td>ប្រភពទី៨ និងទី១</td></tr>
<tr><td>រាជធានី</td><td colspan="3">ភ្នំពេញ</td><td>ប្រភពទី៧</td></tr>
<tr><td>ការបែងចែក រដ្ឋបាល</td><td colspan="3">ខេត្តចំនួន ២០ និងក្រុងចំនួន៤<br>ខេត្តទាំង២០ មាន: បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កោះកុង កណ្ដាល ក្រចេះ មណ្ឌលគីរី ឧត្ដរមានជ័យ ពោធិសាត់ ព្រះវិហារ ព្រៃវែង រតនៈគីរី សៀមរាប ស្ទឹងត្រែង ស្វាយរៀង តាកែវ ។ ខេត្តចែកជាស្រុក ហើយស្រុកចែកជាឃុំ ។<br>ក្រុងទាំង ៤ មាន: កែប ប៉ៃលិន ភ្នំពេញ និង ព្រះសីហនុ (អតីតក្រុងកំពង់សោម) ។ ក្រុងចែកជាខណ្ឌ និងខណ្ឌចែកជាសង្កាត់ ។</td><td>ប្រភពទី៧</td></tr>
<tr><td rowspan="4">ផ្លូវជាតិ<br>(ប៉ាន់ស្មាននៅ ឆ្នាំ២០០០)</td><td>ស្ថានភាព</td><td>ប្រវែង</td><td>ភាគរយ</td><td rowspan="4">ប្រភពទី១</td></tr>
<tr><td>ធម្មតា (ឥតកៅស៊ូ):</td><td>១០.៣២៧ គ.ម</td><td>៨៣,៨០ %</td></tr>
<tr><td>ចាក់កៅស៊ូ:</td><td>១.៩៩៦ គ.ម</td><td>១៦,១៩ %</td></tr>
<tr><td>សរុប :</td><td>១២.៣២៣ គ.ម</td><td>១០០ %</td></tr>
<tr><td>ធនធានធម្មជាតិ</td><td colspan="3">ប្រេងនិងហ្គាស ឈើ ត្បូងមានតម្លៃ ដែក ម៉ង់ហ្គាណេស ផូស្វាត សក្ដានុពលវារីអគ្គិសនី</td><td>ប្រភពទី១</td></tr>
<tr><td>ដីប្រើប្រាស់</td><td colspan="3">ដីអាចដាំដំណាំបាន: ២០,៩៦ % ដំណាំអចិន្ត្រៃយ៍ : ០.៦១ %<br>ព្រៃឈើ : ៥០ % (ប្រភពទី៤)<br>ផ្សេងៗទៀត : ២៨,៤៣ %</td><td>ប្រភពទី១ និងទី៤</td></tr>
<tr><td>ផលិតផលកសិកម្ម</td><td colspan="3">ស្រូវ កៅស៊ូ ពោត បន្លែ ស្វាយចន្ទី និងដំឡូង</td><td>ប្រភពទី១</td></tr>
<tr><td>ឧស្សាហកម្ម</td><td colspan="3">ទេសចរណ៍ វាយនភ័ណ្ឌ ម៉ាស៊ីនស្រូវ នេសាទ ផលិតផលធ្វើពីឈើ និងព្រៃឈើ កៅស៊ូ ស៊ីម៉ងត៍ រ៉ែមាស សំលៀកបំពាក់</td><td>ប្រភពទី១</td></tr>
<tr><td>ប្រជាពលរដ្ឋ</td><td colspan="3">១៣ ៣៦៣ ៤២១ (ប៉ាន់ប្រមាណនៅ ឆ្នាំ២០០៤)</td><td>ប្រភពទី១</td></tr>
<tr><td rowspan="6">ជនជាតិភាគតិច</td><td>ជនជាតិដើម</td><td colspan="2">ភាគរយ</td><td rowspan="6">ប្រភពទី១ និងទី៣</td></tr>
<tr><td>ខ្មែរ</td><td colspan="2">៩០%</td></tr>
<tr><td>វៀតណាម</td><td colspan="2">៥%</td></tr>
<tr><td>ចិន</td><td colspan="2">១%</td></tr>
<tr><td>ជនជាតិដើមភាគតិច</td><td colspan="2">១%</td></tr>
<tr><td>ដទៃទៀត</td><td colspan="2">៣%</td></tr>
<tr><td rowspan="3">ភាសា</td><td>ខ្មែរ (ផ្លូវការ)</td><td colspan="2">៩៥%</td><td rowspan="3">ប្រភពទី១ និងទី៣</td></tr>
<tr><td>ភាសាជនជាតិដើមភាគតិច</td><td colspan="2">១%</td></tr>
<tr><td>ដទៃទៀត</td><td colspan="2">៤ %</td></tr>
<tr><td>សាសនា</td><td colspan="3">ព្រះពុទ្ធ ៩៥% ដទៃទៀត ៥ %</td><td>ប្រភពទី១</td></tr>
<tr><td>ប្រជាពលរដ្ឋ/ភេទ</td><td colspan="3">ស្ត្រី ៥២% ប្រុស ៤៨%</td><td>ប្រភពទី២ (ទំព័រ ៣)</td></tr>
<tr><td>កំណើនប្រជាពលរដ្ឋ</td><td colspan="3">១,៨% (ប៉ាន់ប្រមាណនៅ ឆ្នាំ២០០៤)</td><td>ប្រភពទី១</td></tr>
</table>

<table>
<tr><td>ប្រជាពលរដ្ឋនៅតំបន់ជនបទ និងទីប្រជុំជន</td><td colspan="2">នៅទីប្រជុំជន ១៥.៧%<br>នៅជនបទ ៨៤.៣%</td><td colspan="3"></td><td>ប្រភពទី៣</td></tr>
<tr><td rowspan="5">រចនាសម្ព័ន្ធ អាយុ (ប៉ាន់ប្រមាណដោយ NIS ក្នុងឆ្នាំ២០០៥)</td><td>អាយុ</td><td>ចំនួន</td><td>ភាគរយ</td><td>ប្រុស</td><td>ស្រី</td><td rowspan="5">ប្រភពទី៣</td></tr>
<tr><td>0-១៩ ឆ្នាំ</td><td>៦.៩៦៣.0៧៤</td><td>៥0%</td><td>៣.៥៤៥.៧0៥</td><td>៣.៤១៧.៣៦៩</td></tr>
<tr><td>១៩-៦៤ ឆ្នាំ</td><td>៦.៣៧២.៤៣៥</td><td>៤៦%</td><td>២.៩៨២.៥២៦</td><td>៣.៣៨៩.៩0៩</td></tr>
<tr><td>៦៥ ឆ្នាំឡើងទៅ</td><td>៥0១.៤១៥</td><td>៤%</td><td>២00.៥៥៣</td><td>៣00.៨៦២</td></tr>
<tr><td>សរុប:</td><td>១៣.៨0៦.៩២៣</td><td>១00%</td><td>៦.៦៩៨.៧៨៣<br>៤៨,៥២%</td><td>៧.១0៨.១៤0<br>៥១,៤៨%</td></tr>
<tr><td>រំពឹងអាយុជាមធ្យម</td><td colspan="5">ប្រជាពលរដ្ឋសរុប : ៥៨.៤១ ឆ្នាំ<br>បុរស : ៥៥.៧១ ឆ្នាំ<br>ស្ត្រី : ៦១.២៣ ឆ្នាំ (ប៉ាន់ប្រមាណនៅ ឆ្នាំ២00៤)</td><td>ប្រភពទី៣</td></tr>
<tr><td>អត្រាមានកូន</td><td colspan="5">ក្នុងស្ត្រីម្នាក់មានកូនចំនួន ៣.៥១ នាក់ (ប៉ាន់ប្រមាណនៅឆ្នាំ២00៤)</td><td>ប្រភពទី១</td></tr>
<tr><td>អាត្រាទារកស្លាប់</td><td colspan="5">សរុប : ៧៣.៦៧ នាក់/ទារកកើតចំនួន ១000នាក់<br>ស្ត្រី : ៦៤.៤៧ នាក់/ទារកកើតចំនួន ១000នាក់ (ប៉ាន់ប្រមាណឆ្នាំ២00៤)<br>ប្រុស : ៨២.៥១ នាក់/ទារកកើតចំនួន ១000នាក់</td><td>ប្រភពទី១</td></tr>
<tr><td>ចំណូលជាតិសរុបក្នុងម្នាក់</td><td colspan="5">៣00 ដុល្លារអាមេរិក (២00៣) ក្នុងមួយឆ្នាំ (ឬ 0.៨២ ដុល្លារក្នុងមួយថ្ងៃ)</td><td>ប្រភពទី៦</td></tr>
<tr><td>ផលិតផលសរុបក្នុងស្រុក តាមវិស័យ</td><td colspan="5">កសិកម្ម : ៣៥%<br>ឧស្សាហកម្ម: ៣0%<br>សេវា : ៣៥% (ប៉ាន់ប្រមាណនៅ ឆ្នាំ២00៣)</td><td>ប្រភពទី១</td></tr>
<tr><td>កម្លាំងពលកម្ម</td><td colspan="5">៧ លាននាក់ (ប៉ាន់ប្រមាណនៅ ឆ្នាំ២00៣)</td><td>ប្រភពទី១</td></tr>
<tr><td>កម្លាំងពលកម្មតាមវិស័យ</td><td colspan="5">កសិកម្ម ៧៥% (ប៉ាន់ប្រមាហេនៅ ឆ្នាំ២00៣)</td><td>ប្រភពទី១</td></tr>
<tr><td>អត្រាគ្មានការងារ</td><td colspan="5">២.៥%</td><td>ប្រភពទី១</td></tr>
<tr><td>ប្រជាពលរដ្ឋក្រីក្រក្រោមបន្ទាត់ក្រីក្រ</td><td colspan="5">៣៦% (ប៉ាន់ប្រមាណនៅ ឆ្នាំ១៩៩៧)</td><td>ប្រភពទី១</td></tr>
<tr><td rowspan="4">ភាពចេះអក្សរៈ (អាយុពី១៥ឡើងទៅអាចអាននិងសរសេរបាន)</td><td colspan="2">ប្រជាពលរដ្ឋ</td><td colspan="2">ភាពចេះអក្សរ</td><td>អនក្ខរកម្ម</td><td rowspan="4">(២00២)<br>ប្រភពទី១</td></tr>
<tr><td colspan="2">សរុប</td><td colspan="2">៦៩.៤%</td><td>៣0.៦%</td></tr>
<tr><td colspan="2">ប្រុសៈ</td><td colspan="2">៨0.៨%</td><td>១៩.២%</td></tr>
<tr><td colspan="2">ស្រីៈ</td><td colspan="2">៥៩.៣%</td><td>៤0.៧%</td></tr>
</table>

### អំពីស្ត្រី

ស្ត្រីមានចំនួនប្រហែល ៥២% នៃប្រជាពលរដ្ឋទាំងអស់ ហើយមានសមាមាត្ររបស់ស្ត្រីខ្ពស់ នៅក្នុងចំណោមប្រជាពលរដ្ឋពេញវ័យ[៨២] ។ វាបង្ហាញឱ្យឃើញថា មានចំនួនគួរឱ្យកត់សំគាល់នូវស្ត្រី ដែលទទួលបន្ទុកគ្រួសារតែម្នាក់ឯង ។ កង្វះខាតនូវចំនួនបុរសពេញវ័យមានពាក់ព័ន្ធដោយផ្ទាល់នឹងសង្គ្រាម ដែលប្រទេសបានទទួលរងនៅក្នុងទសវត្សរ៍កន្លងទៅ ។ អត្រាភាពមានកូនសរុបគឺ ៣.៥១នាក់ ក្នុងចំណោមស្ត្រីម្នាក់ៗ ដោយយោងតាមការប៉ាន់ស្មាននៅ ឆ្នាំ២០០៤[៨៣] ។

ស្ត្រីមានចំនួនតិចជាងបុរសក្នុងការបានទទួលការអប់រំ ។ ភាពមិនចេះអក្សរ ( អនក្ខរកម្ម) នៅក្នុងប្រទេសមានប្រមាណជា ៣១% នៃប្រជាពលរដ្ឋទាំងអស់ (អាយុចាប់ពី ១៥ឆ្នាំឡើងទៅ) ។ ភាពមិនចេះអក្សរ ចំពោះបុរសមាន២០% ប៉ុន្តែភាពមិនចេះអក្សរ ចំពោះស្ត្រីមានចំនួនទ្វេដង គឺត្រូវជា ៤១%[៨៤] ។ សន្ទស្សន៍នៃការអភិវឌ្ឍយេនឌ័រ (GDI) បានចាត់ថ្នាក់ប្រទេសកម្ពុជាលេខរៀង ១០៥ ក្នុងចំណោមប្រទេស ១៤៥ ដែលនេះបានបង្ហាញពីវិសមភាពរបស់ស្ត្រីក្នុងជីវភាពរស់នៅ បើប្រៀបធៀបនឹងបុរស[៨៥] ។ កម្លាំងពលកម្មរបស់ស្ត្រីត្រូវបានឋិតនៅក្នុងការងារ ដែលមិនទាមទារលក្ខណៈសម្បត្តិខ្ពស់ទេ ហើយស្ត្រីជារឿយៗទទួលបានប្រាក់ខែតិចជាងបុរសសម្រាប់ការងារដូចគ្នា ។ ស្ត្រីទទួលបានត្រឹមតែ១៣%នៃការងារថ្នាក់ធ្វើសេចក្តីសម្រេច ( អ្នករដ្ឋបាល និងអ្នកគ្រប់គ្រង)[៨៦] ។

ទោះបីជាស្ត្រីមានចំនួនភាគច្រើន ក្នុងស្រទាប់មនុស្សពេញវ័យនៅក្នុងប្រទេសក្តី ពួកគេបែរជាមានចំនួនតិចទៅវិញក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច និងនយោបាយ ។ រឿងនេះទាក់ទងនឹងកង្វះខាតការអប់រំ និងមានការរើសអើងផ្លូវភេទ ។ ស្ត្រីមានចំនួនត្រឹមតែ ៨.៥%ប៉ុណ្ណោះ នៅក្នុងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ៩%នៅក្នុងជួរមន្ត្រីរាជការ ៧%ក្នុងចំណោមចៅក្រម និង ១២%ក្នុងចំណោមសមាជិកសភា ។ តាមរង្វាស់សិទ្ធិអំណាច យេនឌ័រ (Gender Equity Measure - GEM) ប្រទេសកម្ពុជាមានលំដាប់លេខ ៦៩ ក្នុងចំណោមប្រទេស៨៣ ដែលនេះបង្ហាញឱ្យដឹងពីភាពខ្វះខាតការចូលរួមរបស់ស្ត្រី នៅក្នុងផ្នែកសេដ្ឋកិច្ច និងនយោបាយរបស់ប្រទេស[៨៧] ។

---

៨២ គេហទំព័រ វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា (NIS)

៨៣ *USA World Factbook.*

៨៤ គេហទំព័រ ធនាគារពិភពលោក ( WB)

៨៥ "The gender-related development index (GDI), introduced in Human Development Report 1995, measures achievements in the same dimensions using the same indicators as the HDI but captures inequalities in achievement between women and men. It is simply the HDI adjusted downward for gender inequality. The greater the gender disparity in basic human development, the lower is a country's GDI relative to its HDI." របាយការណ៍ អភិវឌ្ឍន៍មនុស្សឆ្នាំ ២០០៤ ដោយអង្គការ UNDP (UNDP: *HDR 2004)*

៨៦ របាយការណ៍ អភិវឌ្ឍន៍មនុស្សឆ្នាំ ២០០៤ ដោយអង្គការ UNDP (UNDP: *HDR 2004)*

៨៧ "The gender empowerment measure (GEM) reveals whether women take an active part in economic and political life. It focuses on gender inequality in key areas of economic and political participation and decision-making. It tracks the share of seats in parliament held by women; of female legislators, senior officials and managers; and of female professional and technical workers- and the gender disparity in earned income, reflecting economic independence. Differing from the GDI, the GEM exposes inequality in opportunities in selected areas." របាយការណ៍ អភិវឌ្ឍន៍មនុស្សឆ្នាំ ២០០៤ ដោយអង្គការ UNDP (UNDP: *HDR 2004)*

## តារាង: ស្ថិតិស្តីពីស្ថានភាពស្ត្រីនៅកម្ពុជា

| ស្ថិតិស្ត្រីនៅព្រះរាជាណាចក្រកម្ពុជា | | |
|---|---|---|
| **ទិន្នន័យ** | **ភាគរយ (%)** | **ដកស្រង់ពី** [៨៨] |
| ចំនួនប្រជាពលរដ្ឋ : ស្រី | ៥២% នៃប្រជាពលរដ្ឋទាំងអស់ | ប្រភពទី៩ |
| ស្ត្រីមិនចេះអក្សរ | ៤៥% នៃប្រជាពលរដ្ឋស្ត្រីទាំងអស់ | ប្រភពទី២ ទំព័រ៨ |
| ស្ត្រីរស់នៅជនបទ | ៨០% នៃប្រជាពលរដ្ឋស្ត្រីទាំងអស់ | ប្រភពទី២ ទំព័រ៣ |
| សមាជិកសភា (២០០៣-២០០៨) | ១៥/១២៣ | |
| ១២% នៃសមាជិកសភាទាំងអស់ . | ប្រភពទី២ ទំព័រ១១ | |
| រដ្ឋមន្ត្រី | ២/២៦ | ប្រភពទី១២ ទំព័រ២១ |
| រដ្ឋលេខាធិការ | ៨/១៣៦ | ប្រភពទី១២ ទំព័រ២១ |
| អនុរដ្ឋលេខាធិការ | ១៣/១៤៦ | ប្រភពទី១២ ទំព័រ២១ |
| អភិបាលខេត្ត /ក្រុង | ០/២៤ | ប្រភពទី១២ ទំព័រ២១ |
| សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់(២០០២-២០០៧) | ៨.៥%នៃសមាជិកក្រុមប្រឹក្សាទាំងអស់ | ប្រភពទី១២ ទំព័រ២១ |
| មន្ត្រីរាជការ | ៩%នៃមន្ត្រីរាជការទាំងអស់ (មន្ត្រីទាំងអស់គឺ ១៦៩០០០ នាក់) | ប្រភពទី១២ ទំព័រ២១ |
| ចៅក្រមជាស្ត្រី : | | |
| - ១ នាក់ : នៅសាលាឧទ្ធរណ៍ | | |
| - គ្មានស្ត្រីនៅតុលាការកំពូល | ១២/១២៤ | |
| ៧.២៧% នៃចៅក្រមទាំងអស់ | ប្រភពទី១៣ | |
| ព្រះរាជអាជ្ញា (នៅសាលាឧទ្ធរណ៍) | ១/៦៨ | ប្រភពទី១៣ |
| កម្លាំងពលកម្មក្នុងវិស័យកសិកម្ម | ៦០% នៃកម្លាំងពលកម្មទាំងអស់ | ប្រភពទី៩ |
| កម្លាំងពលកម្មក្នុងវិស័យជំនួញ | ៨៥% នៃកម្លាំងពលកម្មទាំងអស់ | ប្រភពទី៩ |
| កម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្ម | ៧០% នៃកម្លាំងពលកម្មទាំងអស់ | ប្រភពទី៩ |
| កម្លាំងពលកម្មក្នុងវិស័យសេវា | ៦០% នៃកម្លាំងពលកម្មទាំងអស់ | ប្រភពទី៩ |
| នាយកគ្រប់គ្រង និង អ្នកគ្រប់គ្រងរដ្ឋបាល | ១៣.៨%នៃកម្លាំងពលកម្មទាំងអស់ | ប្រភពទី១០ |
| កម្លាំងពលកម្មជំនាញ និងបច្ចេកទេស | ៣២.៦%នៃកម្លាំងពលកម្មទាំងអស់ | ប្រភពទី១០ |
| ប៉ាន់ប្រមាណចំណូលរបស់ស្ត្រី (PPP US$) | ៣២.៦ ដុល្លារអាមេរិក | ប្រភពទី១០ |
| ធៀបចំណូលរបស់ស្ត្រីនឹងចំណូលរបស់បុរស | ០/៧៧ | ប្រភពទី១០ |
| ស្ត្រីរកស៊ីផ្លូវភេទដោយការបង្ខំ ឬ ដោយការឆបោក (ស្ថិតិឆ្នាំ ២០០២) | ៦០%នៃស្ត្រីរកស៊ីផ្លូវភេទ (ស្ត្រីរកស៊ីផ្លូវភេទមានប្រមាណ៥០.០០០នាក់) | ប្រភពទី១១ |

[៨៨] ប្រភពទី ៩: A report from the US State Department: "Country Reports on Human Rights Practices - Cambodia" Released by the Bureau of Democracy, Human Rights, and Labor, 2004, Available at: http://www.state.gov/g/drl/rls/hrvrpt/2004/41638.htm (released on February 25, 2004, visited: April 27, 2005).

ប្រភពទី ១០: របាយការណ៍ អភិវឌ្ឍន៍មនុស្សឆ្នាំ ២០០៤ ដោយអង្គការ UNDP (UNDP: *HDR 2004)*

ប្រភពទី ១១: A report from the US State Department: "Country Reports on Human Rights Practices - Cambodia" Released by the Bureau of Democracy, Human Rights, and Labor, 2002 Available at: http://www.state.gov/g/drl/rls/hrrpt/2002/18238.htm (visited: April 27, 2005)

ប្រភពទី ១២: របាយការណ៍ អង្គការ ADHOC ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ ២០០៤។

ប្រភពទី ១៣: ក្រសួងយុត្តិធម៌: តារាងបញ្ជីឈ្មោះចៅក្រម និងព្រះរាជអាជ្ញានៅព្រះរាជាណាចក្រកម្ពុជា , ភ្នំពេញ ២០០២

### អំពីជនជាតិដើមភាគតិច និងជនជាតិភាគតិច[៨៩]

និយាយអំពីដើមកំណើតនៃជនជាតិ ប្រជាពលរដ្ឋកម្ពុជាមាន ៩០ ទៅ ៩៥% ជាជនជាតិខ្មែរ ហើយមានប្រហែល ៥-១០% ជនជាតិភាគតិច[៩០] ដូចជាជនជាតិចាមកាន់សាសនាឥស្លាម[៩១] ជនអន្តោប្រវេសន៍ពីបុព្វជនមក មានដូចជាជនជាតិចិន ដែលជាជនជាតិភាគតិចមានចំនួនច្រើនជាងគេនៅក្នុងប្រទេស ជនជាតិវៀតណាម និងជនជាតិឡាវ ព្រមទាំងជនជាតិដើមភាគតិចផងដែរ។

ជនជាតិដើមភាគតិច ឬត្រូវបានហៅថាជាប្រជាពលរដ្ឋរស់នៅតាមតំបន់ខ្ពង់រាប "ខ្មែរលើ" ឬ "កុលសម្ព័ន្ធភ្នំ" គឺជាជនជាតិដែលមិនមែនជាជាតិសាសន៍ខ្មែរ ហើយក្រុមនេះរួមមានដូចជា ទំពួន កួយ ចារាយ ភ្នង គ្រឹង កាវ៉ែត ព្រៅ ស្ទៀង លុន និងក្រុមផ្សេងៗទៀត[៩២]។ មិនមានតួលេខច្បាស់លាស់ពីចំនួនជនជាតិដើមភាគតិចនៅក្នុងប្រទេសទេ។ តាមការសិក្សាស្រាវជ្រាវខ្លះបានប៉ាន់ស្មានថាពួកគេសរុបមានប្រហែលជា ១២០.០០០នាក់ ប្រហែលស្មើនឹង ១% នៃប្រជាពលរដ្ឋទាំងអស់ ដែលភាគច្រើនប្រមូលផ្តុំគ្នារស់នៅក្នុងខេត្តមួយចំនួន[៩៣]។ ជនជាតិដើមភាគតិច មានចំនួនភាគច្រើននៅក្នុងខេត្តរតនៈគីរី (៦៧.៩៤%) និងខេត្តមណ្ឌលគីរី (៥៩.៣៣%) ហើយពួកគេនិយាយភាសារបស់ពួកគេផ្ទាល់[៩៤]។

---

៨៩ សូមមើល : Center for Advanced Study: *Interdisciplinary Research on Ethnic Groups in Cambodia. Final Draft Reports*. Phnom Penh: CAS, 1996; ADB: Indigenous Peoples/Ethnic minorities and poverty reduction Cambodia. Manila: ADB, 2002; Ehrentraut, Stefan: *The Theory of Multiculturalism and Cultural Diversity in Cambodia*. Postdam: University of Postdam, 2004; Minority Rights Group International: *Minorities in Cambodia*. UK: Manchester Free Press, 1995.

៩០ មិនមានព័ត៌មានច្បាស់លាស់ទេអំពីជនជាតិភាគតិចនៅកម្ពុជា។ គេហទំព័រផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា (http://www.cambodia.gov.kh/unisql1/egov/english/country.population.html, (KC website) បង្ហាញថា "៩០% ជាជនជាតិខ្មែរ ៥%នៃក្រុមនីមួយៗនៃជនជាតិចិន ជនជាតិវៀតណាម និងចំនួនតិចតួចនៃកុលសម្ព័ន្ធភ្នំ (ចាម និងភូមា)"។ ទីភ្នាក់ងាររបស់រដ្ឋាភិបាលមួយទៀត គឺគណៈកម្មការជាតិសម្រាប់វប្បធម៌ និងព័ត៌មាន បានបង្ហាញថា ខ្មែរមានចំនួនដល់ទៅ ៩០-៩៥% នៃប្រជាពលរដ្ឋទាំងអស់ ហើយជនជាតិភាគតិចមាន ៥%។ (http://www.moi-coci.gov.kh/profile/default.htm, (*NCOCI website*). របាយការណ៍មួយរបស់ធនាគារពិភពលោកបានលើកឡើង ពីរបាយការណ៍របស់រដ្ឋាភិបាលចំនួនពីរ ដែលមួយធ្វើឡើងដោយនាយកដ្ឋានជនជាតិភាគតិច (១៩៩២) ដែលបានបញ្ចូលក្រុមជនជាតិភាគតិចចំនួន ៣៥ ក្រុម ហើយបានប៉ាន់ស្មានចំនួនសរុបរបស់ពួកគេថាមានប្រហែល ៤% នៃប្រជាពលរដ្ឋទាំងអស់។ មួយទៀតធ្វើឡើងដោយក្រសួងមហាផ្ទៃ (១៩៩៥) បានផ្តល់នូវភាគរយដូចគ្នា។ សូមមើល : World Bank: *Cambodia - Rural Investment and Local Governance Project: indigenous peoples plan- RILGP, Vol. 2. March 2003*. (Available at: http://www-wds.worldbank.org/servlet/WDSContentServer/WDSP/IB/2003/02/15/000094946_03020504014850/Rendered/INDEX/multi0page.txt; (*WB-RILGP*).

៩១ "ជនជាតិចាមរស់នៅកម្ពុជាសព្វថ្ងៃ ជាបច្ឆាញាតិបន្តមកពីជនភៀសខ្លួននៃអាណាចក្រចម្ប៉ា ដែលធ្លាប់គ្រប់គ្រងមួយភាគធំ នៃប្រទេសវៀតណាម ដោយរាប់ចាប់ពីតំបន់ Gao Ha ប៉ែកខាងជើង រហូតដល់តំបន់ Bien Hoa ប៉ែកខាងត្បូង។ ជនជាតិចាមជាទូទៅរស់នៅជាក្រុមក្នុងចំណោមជនជាតិខ្លួន ដែលនៅតាមមាត់បឹង ទន្លេ ឬលើកោះ។ មូលហេតុដែល ពួកគេតាំងទីលំនៅនៅតាមមាត់ទឹកព្រោះ ពួកគេងាយស្រួលប្រកបរបរនេសាទ និងដាំបន្លែ។ ជនជាតិចាមរស់នៅតាម ដីកោះ ពួកគេរកស៊ីចិញ្ចឹមជីវិតដោយមធ្យោបាយផ្សេងៗ ជាពិសេសជាជាងដែក និងអ្នកខ្លះទៀតសំលាប់សត្វពាហនៈ" សូមមើល : គេហទំព័រ *NCOCI*

៩២ សូមមើល : គេហទំព័រ *NCOCI*

៩៣ សូមមើល : *WB RILGP 2003*

៩៤ សូមមើលតារាងខាងក្រោម : ធនាគារអភិវឌ្ឍន៍អាស៊ីមានកំណត់ចំនួនភាគរយនៃជនជាតិដើមភាគតិចខុសគ្នាបន្តិច "ជនជាតិដើមភាគតិចរស់នៅខេត្តមណ្ឌលគីរី = ៦៦ %, រតនៈគីរី = ៧១%, ស្ទឹងត្រែង =៧% និងក្រចេះ =៨% នៃចំនួនប្រជាពលរដ្ឋនៅក្នុងខេត្តនីមួយៗ ។ ADB: *Indigenous Peoples, Ethnic Minorities and Poverty Reduction, Regional Report*, prepared by under the ADB Regional Technical Assistance No.5953: Capacity Building for Indigenous Peoples/Ethnic Minority Issues and Poverty Reduction, Manila: ADB, 2002. (ចាប់ពីពេលនេះទៅត្រូវសរសេរ : ឯកសារ *ADB 2002*).

ជនជាតិដើមភាគតិចមានអត្តសញ្ញាណវប្បធម៌ ភាសា និងជំនឿផ្ទាល់ខ្លួនរបស់គេ។ ពួកគេភាគច្រើនរស់នៅក្នុងភូមិបណ្តោះអាសន្នដាច់ៗពីគ្នា ហើយជាធម្មតាត្រូវបានដឹកនាំដោយចាស់ទុំក្នុងសហគមន៍ ឬដោយមេកន្ត្រាញ[៩៥]។ នៅក្នុងសហគមន៍របស់ពួកគេ ពួកគេមានការរៀបចំសង្គម ការអនុវត្តវប្បធម៌ និងសង្គម-សេដ្ឋកិច្ច ផ្ទាល់ខ្លួនគេ (រួមទាំងកសិកម្មពនេចរ) វិធាន និងនីតិវិធីទំនៀមទម្លាប់ក្នុងការគ្រប់គ្រងជីវិតក្នុងសង្គម និងដោះស្រាយវិវាទផ្សេងៗ។

សូម្បីតែនៅក្នុងខេត្តដែលជនជាតិដើមភាគតិចមានចំនួនភាគច្រើនក្តី ក៏រចនាសម្ព័ន្ធអំណាចគ្រប់គ្រងសហគមន៍មិនមានតំណាងជាជនជាតិដើមភាគតិចច្រើនឡើយ។ រដ្ឋបាលមូលដ្ឋាន និងសេវាសាធារណៈ មិនត្រូវបានសម្របទៅតាមទម្រង់នៃការរៀបចំរបស់ជនជាតិដើមភាគតិច ដើម្បីឱ្យស្ថាប័នរដ្ឋទាំងនោះមានភាពគ្រប់គ្រាន់ មានទំនុកចិត្ត និងមានប្រសិទ្ធិភាពនោះឡើយ។ ជាឧទាហរណ៍ នៅកម្រិតថ្នាក់ឃុំ ជនជាតិដើមភាគតិចមានក្រុមប្រឹក្សាចាស់ទុំ ដែលជាអ្នកធ្វើសេចក្តីសម្រេចរបស់សហគមន៍សំខាន់ៗ យោងតាមបែបផែនផ្សេងៗតាមការប្រឹក្សាយោបល់។ ពួកគេជាអាជ្ញាធរដែលមានទំនុកចិត្ត សម្រាប់សហគមន៍ជនជាតិដើមភាគតិច។ ហើយសហគមន៍ត្រួតពិនិត្យការអនុវត្តអំណាចរបស់ចាស់ទុំតាមរូបភាពផ្សេងៗ។ ផ្ទុយទៅវិញ មេភូមិត្រូវបានតែងតាំងដោយអ្នកខាងក្រៅ ហើយគាត់មិនបានឆ្លើយតបទៅនឹងផលប្រយោជន៍ចាំបាច់របស់ភូមិទេ។ ក្រុមប្រឹក្សាឃុំដែលត្រូវបានបោះឆ្នោតតាមបញ្ជីគណបក្សនយោបាយ ដូចនេះសមាជិកក្រុមប្រឹក្សាត្រូវធ្វើតាមគណបក្សនយោបាយ ដែលខ្លួនជាសមាជិក។ សូម្បីតែសមាជិកក្រុមប្រឹក្សាខ្លះ ដែលជាជនជាតិដើមភាគតិចក្តី ក៏ពួកគេមិនបានឆ្លើយតបទៅនឹងសហគមន៍ជនជាតិដើមភាគតិច ឬក៏ត្រូវបានគ្រប់គ្រងដោយពួកគេឡើយ។ ប្រភពផ្លូវច្បាប់របស់មេភូមិ និងក្រុមប្រឹក្សាឃុំ ឋិតនៅខាងក្រៅរចនាសម្ព័ន្ធរបស់ជនជាតិដើមភាគតិច។ ហេតុដូច្នេះ ដំណើរការវិមជ្ឈការមិនបានសម្របសម្រួលប្រព័ន្ធអាជ្ញាធររបស់ជនជាតិដើមភាគតិចជាមួយនឹងរដ្ឋអំណាចមូលដ្ឋាន ហើយរចនាសម្ព័ន្ធនៅមូលដ្ឋាន មិនបានពង្រឹងការត្រួតពិនិត្យពីក្រោមដល់លើផ្អែកទៅតាមរចនាសម្ព័ន្ធរបស់ជនជាតិដើមភាគតិចឡើយ។

ជាទូទៅ ការផ្តល់សេវាសាធារណៈមិនបានគិតទៅដល់វប្បធម៌ និងភាសារបស់ជនជាតិដើមភាគតិចទេ។ ជាលទ្ធផលវាមានការលំបាកសម្រាប់ជនជាតិដើមភាគតិច ក្នុងការទទួលបានសេវាសាធារណៈទាំងនោះ។ អត្រាភាព មិនចេះអក្សរក្នុងចំណោមជនជាតិដើមភាគតិច មានកម្រិតខ្ពស់ជាងប្រជាពលរដ្ឋផ្សេងៗទៀត។ កង្វះខាតនៃការអប់រំ អន្តរវប្បធម៌ដែលប្រើភាសាពីរ នាំទៅរកការបាត់បង់ភាសារបស់ជនជាតិដើមភាគតិច។

បន្ទាប់ពីផ្លូវថ្នល់ត្រូវបានកសាងរួចមក ការទន្ទ្រានយកដីសម្ភូហភាពរបស់ជនជាតិដើមភាគតិចបានក្លាយ ជាបញ្ហាធ្ងន់ធ្ងរមួយ។ ការបាត់បង់ដីសម្ភូហភាពរបស់ជនជាតិដើមភាគតិច បានគំរាមកំហែងដល់អត្ថិភាពរបស់ពួកគេ ក្នុងនាមជាប្រជាពលរដ្ឋ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ សហគមន៍ជនជាតិដើមភាគតិចបានបាត់បង់ដីធ្លីសម្ភូហភាពអស់មួយចំនួនធំ ហើយមិនមានការឆ្លើយតបសមស្របណាមួយ ដើម្បីបញ្ឈប់បាតុភូតនេះនៅឡើយទេ[៩៦]។ ការបាត់បង់ដីធ្លី នាំឱ្យមានការផ្លាស់ទីកន្លែង ភាពក្រីក្រជម្ងឺ ការបែកខ្ញែកគ្នា ហើយជាយថាហេតុធ្វើឱ្យបាត់បង់ក្រុមសហគមន៍ជនជាតិដើមភាគតិចតែម្តង នៅពេលដែលសមាជិកម្នាក់ៗកាន់តែក្រទៅៗ។

---

៩៥ សូមមើល : គេហទំព័រ *NCOCI*

៩៦ ការសិក្សាថ្មីៗចុងក្រោយនេះបានចងក្រងឯកសារស្តីពីការបាត់បង់ដីធ្លីរបស់ជនជាតិដើមភាគតិច។ សូមមើល : NGO Forum on Cambodia: *Land Alienation from Indigenous Minority Communities in Ratanakiri*. Phnom Penh: NGO Forum, 2004.

តារាង៖ ស្ដីពីជនជាតិដើមភាគតិចនៅកម្ពុជា យោងលើលទ្ធផលជំរឿនឆ្នាំ ១៩៩៨) [៩៧]

**ក-ចំនួនជនជាតិដើមភាគតិច កំណត់ដោយភាសានិយាយ**

| ក្រុមជនជាតិដើមភាគតិច | រតនះគិរី | ស្ទឹងត្រែង | មណ្ឌលគិរី | ព្រះវិហារ | ក្រចេះ | សរុប |
|---|---|---|---|---|---|---|
| ១. ព្រៅ | ៧១៣២ | ២០៧ | ១៤ | ៨ | ០ | ៧៣៦១ |
| ២. ចារ៉ាយ | ១៥៦៦៩ | ១៦ | ១១៦ | ០ | ០ | ១៥៨០១ |
| ៣.កាចក់ | ២០៥៤ | ២ | ០ | ០ | ០ | ២០៥៦ |
| ៤. ឃ្មឿង | ០ | ១ | ០ | ០ | ០ | ១ |
| ៥. ក្រោល | ០ | ០ | ៣២០ | ០ | ២៦៣៥ | ២៩៥៥ |
| ៦. កាវ៉ែត | ១៧២៦ | ២២០៥ | ០ | ០ | ០ | ៣៩៣១ |
| ៧. គ្រឹង | ១៤៨៧៧ | ១៥៩ | ៥ | ០ | ០ | ១៥០៤១ |
| ៨. គួយ | ០ | ១ | ០ | ៤៥៣៦ | ៥៤៦ | ៥០៨៣ |
| ៩. លុន | ០ | ២៧៣ | ០ | ០ | ០ | ២៧៣ |
| ១០. មិល | ០ | ០ | ០ | ០ | ១២៦០ | ១២៦០ |
| ១១. ភ្នង | ៣៦៧ | ៣៨៨ | ១៨០៣៦ | ៣៩ | ៣១៦៦ | ២១៩៩៦ |
| ១២. ព័រ | ០ | ០ | ០ | ៣១៦ | ០ | ៣១៦ |
| ១៣. រដែ | ០ | ០ | ១០ | ០ | ០ | ១០ |
| ១៤. រុង | ០ | ០ | ៥ | ០ | ០ | ៥ |
| ១៥. ស្ទៀង | ០ | ០ | ៥៣៦ | ១ | ១៦១២ | ២១៤៩ |
| ១៦. ទំពួន | ២២១២៨ | ១៣ | ៧០ | ០ | ០ | ២២២១១ |
| ១៧. ធ្នូន | ០ | ០ | ៩៥ | ០ | ៦១៩ | ៧១៤ |
| ១៨. ផ្សេងៗទៀត | ៨៤ | ៥ | ២២ | ៣ | ៧ | ១២១ |
| **សរុប** | **៦៤០៣៧** | **៣២៧០** | **១៩២២៩** | **៤៩០៣** | **៩៨៤៥** | **១០១២៨៤** |
| **ខ-ប្រជាពលរដ្ឋសរុប/ខេត្ត** | ៩៤២៤៣ | ៨១០៧៤ | ៣២៤០៧ | ១១៩២៦១ | ២៦៣១៧៥ | |
| **គ-ភាគរយជនជាតិដើមភាគតិច នៅក្នុងខេត្ត (%)** | **៦៧,៩៤%** | **៤,០៣%** | **៥៩,៣៣%** | **៤,១១%** | **៣,៧៤%** | |

៩៧ តារាងនេះផ្អែកលើឯកសារ

ក- *ADB 2002*: ជនជាតិដើមភាគតិចដែលត្រូវបានកំណត់ដោយភាសានិយាយ

ខ- ទិន្នន័យស្ដីពីចំនួនប្រជាពលរដ្ឋនៅក្នុងខេត្តនីមួយៗ ប៉ាន់ស្មាននៅក្នុងឆ្នាំ២០០២ ដោយដកស្រង់ចេញពីលទ្ធផលជំរឿនធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនៅឆ្នាំ១៩៩៨ គ-ភាគរយនេះគឺជាការប្រៀបធៀបរវាងទិន្នន័យរបស់ធនាគារអភិវឌ្ឍន៍ អាស៊ី (ADB) ស្ដីពីចំនួនជនជាតិដើមភាគតិចនៅកម្ពុជាជាមួយនឹងទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ ស្ដីពីការប៉ាន់ប្រមាណចំនួនប្រជាពលរដ្ឋសរុបនៅឆ្នាំ ២០០២។ លទ្ធផលនេះមានលក្ខណៈល្មៀងគ្នាបន្តិចជាមួយរបាយការណ៍របស់ *ADB* ឆ្នាំ ២០០២ ត្រង់ទំព័រទី៥។

## ២. ធាតុផ្សំ ឬបញ្ហានាំឱ្យមានតម្រូវការយុត្តិធម៌ក្នុងសង្គមកម្ពុជា

តម្រូវការយុត្តិធម៌ក្នុងសង្គមដោយអ្នកក្រីក្រនៅតាមតំបន់ជនបទ គឺតំណាងឱ្យតម្រូវការភាគច្រើនរបស់ប្រជាពលរដ្ឋ។ ក្រៅពីភាពក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ជារឿយៗតែងទទួលរងនូវអំពើហិង្សាផ្នែកយេនឌ័រ និងការរើសអើងជាតិពន្ធុ។ រឿងនេះធ្វើឱ្យតម្រូវការយុត្តិធម៌របស់គេមានភាពជាក់លាក់។ ការសិក្សានេះវិភាគពីតម្រូវការយុត្តិធម៌ក្នុងសង្គមសម្រាប់អ្នកក្រីក្រជាទូទៅ និងតម្រូវការយុត្តិធម៌ជាក់លាក់ ដែលមានឡើងចំពោះស្ត្រី និងជនជាតិដើមភាគតិច[៥៨]។

អ្នកចូលរួមក្នុងសិក្ខាសាលា និងអ្នកដែលត្រូវបានគេសម្ភាស បានប្រាប់ពីបញ្ហាវិវាទ និងជម្លោះខុសៗគ្នា ដែលពួកគេមាន។ បញ្ហាវិវាទ និងជម្លោះទាំងនោះ គឺជាតម្រូវការយុត្តិធម៌ក្នុងសង្គម ដោយសារថារឿងទាំងនោះ បានឆ្លុះបញ្ចាំងពីសេចក្តីត្រូវការក្នុងសង្គមរបស់ប្រជាពលរដ្ឋ។ ផ្អែកលើគោលការណ៍សិទ្ធិមនុស្ស បញ្ហាទាំងនេះរួមមាន *ព្រឹត្តិការណ៍ទាំងឡាយដែលអាចជារឿងក្តីបាន* ហើយអាចប្តឹងដើម្បីរកដំណោះស្រាយ និងការការពារសិទ្ធិ។ ផ្ទុយទៅវិញ មិនមែនគ្រប់រឿងទាំងអស់សុទ្ធតែបានក្លាយជារឿងក្តីទេ នៅពេលប្រជាពលរដ្ឋមិនបានដឹងពីសិទ្ធិរបស់ខ្លួន (ទោះបីពួកគេបានដឹងពីសេចក្តីត្រូវការរបស់ពួកគេក្តី) ឬពួកគេមិនអាចរកស្ថាប័ន ដែលគាត់ទុកចិត្តបាន ដើម្បីប្តឹងរឿងទាំងនោះ។ សេចក្តីត្រូវការក្នុងសង្គមចម្បងៗ ដែលអ្នកចូលរួមក្នុងសិក្ខាសាលា និងអ្នកត្រូវ បានគេសម្ភាស ត្រូវបានលើកយកមកបង្ហាញមានដូចខាងក្រោមនេះ :

ក- ជម្លោះ : ជម្លោះត្រូវបានចាត់ទុកថាជា *ព្រឹត្តិការណ៍ដែលអាចជារឿងក្តីបាន* ដោយអ្នកចូលរួមក្នុង សិក្ខាសាលា។ ប្រភេទនៃជម្លោះបែបនេះ ត្រូវបានប្តឹងទៅអាជ្ញាធរនានា។

ខ- ការរំលោភអំណាច ដូចជាអំពើពុករលួយ ឬការរំលោភសិទ្ធិមនុស្ស : ប្រជាពលរដ្ឋអាចកំណត់ រឿងទាំងនេះថាជា *ព្រឹត្តិការណ៍ដែលអាចជារឿងក្តីបាន* ប៉ុន្តែមិនបានគិតថាធ្វើពាក្យបណ្តឹងទៅកាន់អាជ្ញាធរផ្លូវច្បាប់ទេ ដោយសារតែការគ្មានទំនុកចិត្តលើស្ថាប័ននានាក្នុងការដោះស្រាយរឿងទាំងនេះទេ ឬភ័យខ្លាចចំពោះការសងសឹក។

គ- បញ្ហាសង្គមទាក់ទងនឹងសិទ្ធិសង្គម : ប្រជាពលរដ្ឋបានរាយឈ្មោះបញ្ហាសង្គមពាក់ព័ន្ធ ដូចជា ភាពក្រីក្រ ការខ្វះខាតឱកាសសម្រាប់ទទួលការអប់រំ លំនៅដ្ឋាន ជីវភាពរស់នៅសមរម្យ និងសុខភាពជាដើម។ អ្នកទទួលរងរឿងទាំងនេះភាគច្រើនមិនបានកំណត់ថាជា*រឿងក្តី* ទេ។ ប៉ុន្តែយោងតាមច្បាប់និងសិទ្ធិមនុស្ស ដែលបានទទួលស្គាល់រួចហើយដោយរដ្ឋ សេចក្តីត្រូវការសង្គមទាំងនោះ បង្ហាញពីកង្វះការអនុវត្តសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌។ ដោយមនុស្សភាគច្រើន មិនបានបកស្រាយសេចក្តីត្រូវការសង្គមជាសិទ្ធិ ពួកគេបែរជាយល់ថាបញ្ហាទាំងនោះគ្រាន់តែជាស្ថានភាពមិនស្មើភាពទាក់ទងនឹងភាពក្រីក្រ គឺមិនសមជាការដែលត្រូវប្តឹងទាមទារនោះទេ។

---

[៥៨] ការសិក្សានេះមិនបានបញ្ចូល តម្រូវការនានាដែលលើកឡើងដោយប្រជាពលរដ្ឋនៅទីក្រុង ជនជាតិភាគតិច (ដែលខុសពីជន ជាតិដើមភាគតិច) ឬក៏យុវជនឡើយ។

តារាងទីពីរៈ ធាតុផ្សំនៃតម្រូវការយុត្តិធម៌ក្នុងសង្គមនៅប្រទេសកម្ពុជា

| សេចក្តីត្រូវការក្នុងសង្គម | ភាគីពាក់ព័ន្ធ | មាតិកា |
|---|---|---|
| **១- វិវាទដែលកើតមាន នៅក្នុងសង្គម** | រវាងបុគ្គល<br>- ស្មើភាពគ្នា | ១- វិវាទនៅមូលដ្ឋានៈ វិវាទដោយសារអន្តរទំនាក់ទំនងប្រចាំថ្ងៃ រវាងគូភាគី ដែលមានឋានៈស្មើគ្នា |
| | - អតុល្យភាព នៃទំនាក់ ទំនងរវាង ភាគី | ១- អំពើហិង្សាផ្អែកយេនឌ័រ<br>២- ការប្រមូលផ្តុំដីដោយអ្នកមានអំណាច<br>៣- បទល្មើសព្រហ្មទណ្ឌ និងបញ្ហាផ្សេងៗនៅក្នុងសង្គម<br>៤- ការរើសអើងជាតិពន្ធុ |
| **២- ការរំលោភអំណាច នាំឱ្យមានការ រំលោភសិទ្ធិបុគ្គល** | អំណាចរដ្ឋ- ឯកជន អាជ្ញាធរ | ១- ការរំលោភកម្លាំងសាធារណៈ ដែលនាំឱ្យមានការរំលោភសិទ្ធិបុគ្គល<br>២- ការរំលោភនីតិវិធីច្បាប់<br>៣- អំពើពុករលួយនៅក្នុងនីតិវិធីច្បាប់ |
| **៣-កង្វះអភិបាលកិច្ចល្អ និងអំពើពុករលួយ នាំឱ្យមានការ រំលោភសិទ្ធិសង្គម** | បុគ្គល-សេវា សាធារណៈ | ១-កង្វះការទទួលបានសិទ្ធិសង្គម ដោយសារបរាជ័យក្នុង ការចំណាយរបស់រដ្ឋលើសង្គម<br>២- កង្វះការទទួលបានសិទ្ធិសង្គម ដោយសារអំពើពុករលួយ ក្នុងការផ្តល់សេវាសាធារណៈ<br>៣- ការរំលោភសិទ្ធិសង្គម ដោយសារគ្មានតម្លាភាពនៅក្នុង ការគ្រប់គ្រងធនធាន សាធារណៈ (សម្បទាន ការបណ្តេញចេញដោយបង្ខំ ។ល។) |

## ៣. វិវាទដែលកើតមាននៅក្នុងសង្គម

វិវាទដែលកើតមាននៅក្នុងសង្គម គឺជារឿងធម្មជាតិសម្រាប់អន្តរទំនាក់ទំនងនៅក្នុងសង្គម ហើយវាជារឿងធម្មតាចំពោះសង្គមនីមួយៗ។ បើគិតទៅតាមសមុដ្ឋានសាស្ត្រ (ការសិក្សាពីមូលហេតុ) របស់វិវាទទាំងនោះ វិវាទដែលកើតមាននៅក្នុងសង្គមនៅកម្ពុជា អាចត្រូវបានបែងចែកតាមបាតុភូតខាងក្រោមនេះ : វិវាទនៅតាមមូលដ្ឋាន អំពើហិង្សាផ្អែកយេនឌ័រ វិវាទទាក់ទងដីធ្លី ការរើសអើងជាតិពន្ធុ និងបទល្មើសព្រហ្មទណ្ឌ។

- វិវាទនៅតាមមូលដ្ឋាន ទាក់ទងនឹងទំនាក់ទំនងក្នុងសង្គមប្រចាំថ្ងៃជាមួយអ្នកជិតខាង និងសមាជិកគ្រួសារ។ វិវាទកើតឡើងជាញឹកញាប់ ប៉ុន្តែជាធម្មតាមិនមានលក្ខណៈធ្ងន់ធ្ងរទេ ហើយអាចគ្រប់គ្រងដោះស្រាយនៅមូលដ្ឋានបាន ពិសេសនៅពេលដែលគូភាគីមានអំណាចក្នុងការចរចាស្មើគ្នា។

ផ្ទុយទៅវិញ មានវិវាទមួយចំនួនទៀត ដែលបានកើតឡើងក្នុងបរិបទមួយ ដែលឈរលើស្ថានភាពសង្គមមិនស្មើគ្នា ដូចជាអំពើហិង្សាយេនឌ័រ វិសមភាពផ្អែកសេដ្ឋកិច្ច និងការរើសអើងជាតិពន្ធុ។ វិវាទទាំងនេះ ទាមទារឱ្យមានការឆ្លុះបញ្ចាំងលក្ខណៈមីក្រូ (Micro) ក៏ដូចជាត្រូវការការវិភាគតាមបែបម៉ាក្រូ (Macro)។

- វិវាទដីធ្លីធំៗ ដែលគូភាគីមានអំណាចចរចាមិនស្មើគ្នា ដូចជាក្រុមហ៊ុន កងកម្លាំងប្រដាប់អាវុធ មន្ត្រីថ្នាក់ខ្ពស់ៗ ឬអ្នកមានអំណាច ក៏ដូចជាការទន្ទ្រានយកដីរបស់ជនជាតិដើមភាគតិច តាមរយៈអ្នកគួកជេរ។ ប្រភេទវិវាទដីធ្លីបែបនេះ ដែលត្រូវបានចាត់ទុកថាជាបញ្ហាធ្ងន់ធ្ងរបំផុតមួយរបស់ប្រទេស មានការពិបាកក្នុងការដោះស្រាយ ហើយខ្លះទៀតបានធ្វើឱ្យកើតមានបញ្ហាសង្គមផ្សេងៗទៀត រួមទាំងអំពើហិង្សាផងដែរ។
- អំពើហិង្សាផ្អែកយេនឌ័រ និងការរំលោភបំពានលើកុមារៈ អំពើហិង្សាក្នុងគ្រួសារ គឺជាបញ្ហាសង្គមមួយ ក្នុងចំណោម

បញ្ហាសង្គមដែលមានសភាពធ្ងន់ធ្ងរ ហើយកើតឡើងញឹកញាប់នៅក្នុងប្រទេស។ អំពើហិង្សាក្នុងគ្រួសារ និងកង្វះការទទួលខុសត្រូវរបស់ឪពុក បាននាំទៅរកការលែងលះ។ ការរំលោភផ្លូវភេទលើស្ត្រី និងកុមារកើតឡើងផងដែរក្នុងក្របខ័ណ្ឌនៃអំពើហិង្សាយេនឌ័រ។

- ការរើសអើងជាតិពន្ធុ ដែលប៉ះពាល់ដល់ក្រុមជនជាតិភាគតិច ក៏ដូចជាជនជាតិដើមភាគតិច។
- បទល្មើសព្រហ្មទណ្ឌ និងរឿងផ្សេងៗទៀតនៅក្នុងសង្គម : រឿងព្រហ្មទណ្ឌដែលប៉ះពាល់ដល់ ក្រុមគោលដៅរួមមានបទល្មើសលហុ បទល្មើសធ្ងន់ធ្ងរមួយចំនួន និងសកម្មភាពក្រុមបងធំ។ ភាពខ្វះខាតឱកាសធ្វើការងារព្រមទាំងការផឹកស្រានិងការប្រើប្រាស់គ្រឿងញៀន ជារឿយៗគឺជា ផ្នែកមួយនៃមូលហេតុធ្វើឱ្យមានបទល្មើសដែលប្រព្រឹត្តដោយក្រុមបងធំ។

នៅក្នុងផ្នែកនៃការសិក្សាស្រាវជ្រាវនេះ យើងបានពិភាក្សាជាមួយអ្នកចូលរួមក្នុងសិក្ខាសាលានៅខេត្ត កំពង់ឆ្នាំង កំពង់ស្ពឺ និងមណ្ឌលគិរី ក៏ដូចជាអ្នកដែលបានចូលរួមក្នុងវេទិកាថ្នាក់ជាតិនៅភ្នំពេញ អំពីអ្វីដែលគេបាន ចាត់ទុកថាជាបញ្ហាចម្បងៗ។ សិក្ខាសាលានៅមូលដ្ឋានទាំងបីត្រូវបានធ្វើឡើងនៅតំបន់ជនបទ ស្ថានភាពបញ្ហាដែលអ្នកចូលរួមបានពិភាក្សា ឆ្លុះបញ្ចាំងពីតថភាពនៅតាមតំបន់ជនបទនានានៅក្នុងប្រទេស។

**តារាង: វិវាទចម្បងៗដែលលើកឡើងដោយអ្នកចូលរួមក្នុងសិក្ខាសាលាថាជា *ព្រឹត្តិការណ៍ដែលអាចជារឿងក្តី***

| បញ្ហាចម្បងៗ | | ប្រភេទនៃវិវាទ |
|---|---|---|
| **ក-វិវាទនៅតាមមូលដ្ឋាន** | កើតឡើងញឹកញាប់ តែមិនមានសភាពធ្ងន់ធ្ងរ | - វិវាទតូចតាចលើអចលនវត្ថុនានា<br>- វិវាទទាក់ទងនឹងដំណាំ និងសត្វពាហនៈ<br>- ជម្លោះជាមួយអ្នកជិតខាង និងក្នុងគ្រួសារ<br>- បំណុល<br>- រឿងក្តីរដ្ឋប្បវេណីផ្សេងៗទៀត |
| **ខ-អំពើហិង្សាប្រឆាំងនឹងស្ត្រី** | កើតឡើងញឹកញាប់ហើយធ្ងន់ធ្ងរ។ កើតឡើងម្តងហើយម្តងទៀត។ | - អំពើហិង្សាក្នុងគ្រួសារ និងការលែងលះ<br>- ការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ<br>- ការជួញដូរមនុស្ស |
| **គ-វិវាទលើដីធ្លីធំៗ និងធនធានធម្មជាតិ** | ធ្ងន់ធ្ងរ ហើយមានការពិបាកក្នុងការដោះស្រាយ | - វិវាទទាក់ទងនឹងដីសម្បទាន និងក្រុមហ៊ុន<br>- វិវាទជាមួយអ្នកមានទ្រព្យសម្បត្តិ<br>- យោធា<br>- វិវាទជាមួយរដ្ឋបាលព្រៃឈើ ឬអង្គភាពរដ្ឋផ្សេងៗទៀត<br>- ដីរបស់សហគមន៍ជនជាតិដើមភាគតិច |
| **ឃ-បញ្ហារឿងព្រហ្មទណ្ឌ និងករណីផ្សេងៗទៀត** | | - ក្រុមបងធំ<br>- ចោរកម្ម និងអំពើប្លន់<br>- ការវាយតប់ និងបង្ករបួសស្នាម<br>- សម្លាប់មនុស្សដោយចេតនា<br>- បង្កអសន្តិសុខដោយហ្វូងមនុស្ស<br>- គ្រោះថ្នាក់ចរាចរ និងបញ្ហាផ្សេងៗ |

## ៣.១. វិវាទនៅតាមមូលដ្ឋាន

វិវាទនៅតាមមូលដ្ឋាន មានទាក់ទងនឹងរឿងហេតុដែលកើតជារៀងរាល់ថ្ងៃ ចេញពីអន្តរទំនាក់ទំនងក្នុង សង្គមនៅតំបន់ជនបទ ដូចជាព្រំដី សត្វស៊ីដំណាំរបស់អ្នកដទៃ ជម្លោះ ។ល។ វិវាទបែបនេះមានលក្ខណៈជាបុគ្គល រវាងអ្នកភូមិគ្នាឯង និងខ្លះទៀតមានលក្ខណៈសាធារណៈ ទាក់ទងនឹងការប្រើប្រាស់ដីសាធារណៈ និងស្រះជាដើម ។

វិវាទទាក់ទងនឹងការប្រើប្រាស់អណ្តូងសាធារណៈ

*"ខ្ញុំចង់ប្តឹងពីរឿងអណ្តូងនៅផ្ទះឈ្មោះ XX ដែលនៅភូមិត្រពាំងជ្រៃ ។ បញ្ហាគឺថាឈ្មោះ XX មិនព្រមឱ្យអ្នកភូមិប្រើអណ្តូង ហើយគាត់បានចាក់សោមិនឱ្យគេប្រើឡើយ ។ ដូចដែលខ្ញុំបានជម្រាបជូនខាងលើ ខ្ញុំសូមសំណូមពរឱ្យលោកមេឃុំជួយដោះស្រាយរឿងនេះផង (...)"* ។

បណ្តឹងនៅមុខក្រុមប្រឹក្សាឃុំ ក្នុងខេត្តកំពង់ឆ្នាំង ថ្ងៃទី ២៨ មករា ២០០៣[៩៩] ។

វិវាទលើដីសាធារណៈរបស់ភូមិ

*នៅឆ្នាំ ១៩៨៦ ប្រជាពលរដ្ឋនៅក្នុងភូមិបានកសាងសាលាបុណ្យរួមនៅលើដីសាធារណៈ សម្រាប់ឱ្យប្រជាពលរដ្ឋប្រារព្ធពិធីបុណ្យព្រះពុទ្ធសាសនាជារៀងរាល់ឆ្នាំ ។ ហើយនៅឆ្នាំនោះដែរ គ្រួសារលោក SS បានរើមកនៅក្នុងភូមិនេះ ហើយគ្មានដីរស់នៅ ។ ជំនួសមុខឱ្យភូមិ មេភូមិបានអនុញ្ញាតឱ្យគ្រួសារនេះ រស់នៅជាបណ្តោះអាសន្ននៅក្នុងសាលាបុណ្យនោះ ។ នៅឆ្នាំ ១៩៩០ លោក SS បានប្រគល់ផ្ទះ នោះទៅឱ្យអ្នកទីបី គឺលោក DD ដោយគ្មានការអនុញ្ញាតពីអ្នកភូមិឡើយ ។*

*នៅថ្ងៃទី ១០ ឧសភា ២០០៣ អ្នកភូមិទាំងអស់ តំណាងដោយមេភូមិបានដាក់ពាក្យបណ្តឹងសុំទាមទារឱ្យប្រគល់ដីមកឱ្យអ្នកភូមិវិញ ដើម្បីកសាងសាលាបុណ្យឡើងវិញ សម្រាប់ប្រារព្ធពិធីបុណ្យ តាមព្រះពុទ្ធសាសនា ។* (បណ្តឹងដោយអ្នកភូមិ នៅចំពោះមុខមេភូមិ និងក្រុមប្រឹក្សាឃុំ ក្នុងខេត្តកំពង់ស្ពឺ ឆ្នាំ២០០៣[១០០]) ។

បណ្តឹងរវាងគ្រួសារ និងអ្នកជិតខាង ក៏កើតឡើងញឹកញាប់ដែរ ។

*នៅរសៀលថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០២ ខ្ញុំបានឮកូនប្រុសខ្ញុំឈ្មោះ PP អាយុ ៣ឆ្នាំ កំពុងយំ ហើយខ្ញុំឃើញឈ្មោះ LL បានដើរចេញពីកន្លែងនោះ ។ បន្ទាប់មកខ្ញុំក៏ទៅ និងយកកូនប្រុសខ្ញុំ ហើយនិយាយទៅកាន់ឈ្មោះនោះថា "ហេតុអ្វីបានជាសំឡុតកូនខ្ញុំ អ្នកមិនដឹងថាក្មេងវាខ្លាចទេអី?" បន្ទាប់មកខ្ញុំក៏នាំកូនប្រុសខ្ញុំមកផ្ទះ និងឱ្យកូនប្រុសច្បងត្រលប់មកផ្ទះ ហើយបានស្រែកឱ្យវាថាហេតុអ្វីបានជាមិនមើលប្អូន ។ ភ្លាមនោះឈ្មោះ LL បានស្រែកជេរឱ្យខ្ញុំដោយប្រើពាក្យអាក្រក់ជាច្រើន និងជេរបងថ្លៃស្រីរបស់ខ្ញុំផងដែរ ។ ខ្ញុំសូមសំណូមពរឱ្យលោកមេឃុំអញ្ជើញឈ្មោះខាងលើ ដើម្បីដោះស្រាយជម្លោះ ហើយខ្ញុំសុំប្តឹងពីឈ្មោះ LL[១០១] ។*

ជម្លោះខ្លះអាចប្រែក្លាយទៅជាការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ។ ជម្លោះមួយចំនួនអាចឈានដល់ការចោទប្រកាន់ពីអំពើអាបធ្មប់ និងបរិហារកេរ្តិ៍ ។

---

៩៩ សូមមើល រឿងក្តីលេខ B5 នៅក្នុងឧបសម្ព័ន្ធ ២ ។

១០០ សូមមើល រឿងក្តីលេខ E16 នៅក្នុងឧបសម្ព័ន្ធ ២ ។

១០១ សូមមើលរឿងក្តីលេខ A10 នៅក្នុងឧបសម្ព័ន្ធ២

*"លោក TT បានយកអុសដែលខ្ញុំបានអារ ហើយបានជេរខ្ញុំ នៅពេលដែលខ្ញុំហាមឃាត់គាត់មិនឱ្យយកអុសរបស់ខ្ញុំ"។ ឈ្មោះ TT បានឆ្លើយថាពាក្យបណ្ដឹងនេះពន្លើស ត្រង់គាត់មិនបានជេរទេ។ គាត់បានយកអុសទៅទុកនៅកន្លែងដើមវិញហើយ។ សាក្សីរបស់ដើមបណ្ដឹង ដែលនៅលើផ្ទះបាននិយាយថា : "TT ពិតជាបានជេរ និងបានគំរាមកំហែងរកវាយអ្នកស្រី SS មែន"។ (...) អ្នកស្រី SS ដែលជាដើមបណ្ដឹង បាននិយាយថា គាត់មិនយល់ព្រមតាមចុងចោទទេ ពីព្រោះចុងចោទបានជេរមែន តែគាត់ប្រកែកថាមិនជេរ។ ដូចនេះគាត់សុំប្ដឹងទាមទារសំណង ៥00.000៛។ លោក TT ដែលជាចុងចោទឆ្លើយថា មិនអាចសងដល់ចំនួនប៉ុណ្ណឹងទេ។ គាត់អាចសងត្រឹម ៣0.000៛ ប៉ុណ្ណោះ។ ភាគីទាំងពីរព្រមព្រៀងជានានឹងគ្នាវិញ ហើយសន្យាថាឈប់ជេរបញ្ចោរគ្នាទៀត"។*
*កំណត់ហេតុសម្រុះសម្រួល [១០២]*

ជម្លោះលើច្រកចេញចូលផ្ទះ

*លោក AA លោក BB និងលោក CC រស់នៅជាប់របងគ្នានៅភូមិត្រពាំងព្រលិត ឃុំស្គុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ផ្ទះរបស់ឈ្មោះ AA នៅពីក្រោយផ្ទះរបស់ BB និង CC។ ច្រកចូលផ្ទះលោក AA ត្រូវចូលតាមផ្លូវចន្លោះដីរបស់ BB និង CC ហើយផ្លូវចូលអាចឱ្យរទេះគោចេញចូលបាន។ BB និង CC បានរំលោភយកដីមួយម៉ែត្រម្នាក់ចូលច្រកចេញចូលនេះ។ ពួកគេបានធ្វើរបងបិទផ្លូវចេញចូល។ លោក AA មិនសប្បាយចិត្តនឹងលោក BB និង CC ហើយគាត់បានប្ដឹងទៅមេឃុំ។ បណ្ដឹងត្រូវអស់លុយគាត់ ៥.000៛។*

*នៅថ្ងៃទី ៣ មិថុនា ២00៤ លោក AA លោក BB និង លោក CC បានអញ្ជើញទៅសាលាឃុំ ដើម្បីសម្រុះសម្រួល។ នៅពេលធ្វើការសម្រុះសម្រួល លោក AA បានទាមទារថាគាត់ធ្លាប់ប្រើផ្លូវចូលទៅផ្ទះគាត់។ ដូច្នេះការបិទផ្លូវគឺជាការរំលោភលើសិទ្ធិរបស់គាត់។ លោក BB បានតវ៉ាថា កាលពីគាត់នៅក្មេងផ្លូវនេះពុំមានទេ។ ពីមុនផ្ទះលោក AA ចេញចូលតាមច្រកផ្សេង។ លោក CC និយាយថាគាត់មិន បានដឹងពីសាច់រឿងពីមុនទេ។ គាត់គ្រាន់តែធ្វើតាម BB ដែលបានបិទផ្លូវនោះប៉ុណ្ណោះ។ មេឃុំបានពន្យល់ប្រាប់ថា ដីលោក AA តូច ហើយគាត់ចេញចូលផ្ទះគាត់តាមផ្លូវនេះច្រើនឆ្នាំហើយ។ គាត់និយាយថាលោក CC និង BB គួររុះរបងចេញដើម្បីឱ្យលោក AA អាចចូលផ្ទះគាត់ដោយរទេះគោបានវិញ។ លោក CC និង BB យល់ព្រមរុះរបងចេញ និងបើកច្រកផ្លូវឡើងវិញ។*
(បទសម្ភាសន៏ជាមួយក្រុមប្រឹក្សាឃុំ ក្នុងខែតុលា ២00៤)

ជម្លោះរវាងអ្នកជិតខាង លើរឿងព្រំដី

*អ្នកភូមិម្នាក់មកពីឃុំមហាឫស្សី (ខេត្តកំពង់ស្ពឺ) ដែលជាដើមបណ្ដឹង បានដាំបង្គោលលើព្រំដីរបស់គាត់ ក្រោយពីដីបានវាស់វែងដោយប្រធានភូមិ។ អ្នកជិតខាងគាត់បានដកបង្គោលទាំងនោះចេញ ដោយគ្មានការព្រមព្រៀងពីគាត់សោះ។ ដើមបណ្ដឹងប្ដឹងនៅមុខមេភូមិ បន្ទាប់មកប្ដឹងទៅក្រុមប្រឹក្សាឃុំ [១០៣]។*

មានបទល្មើសព្រហ្មទណ្ឌដោយឡែកៗ និងបញ្ហាធ្ងន់ធ្ងរផ្សេងៗដែលគួរឱ្យកត់សំគាល់ ដូចជាបញ្ហាក្រុមបងធំជាដើម។ បញ្ហាពាក់ព័ន្ធនឹងរឿងបំណុល ក៏ជាឧទាហរណ៏សំខាន់មួយនៃវិវាទនៅតាមមូលដ្ឋានដែរ។

---

[១០២] សូមមើល រឿងក្ដីលេខ B7 ក្នុងឧបសម្ព័ន្ធ ២។

[១០៣] សូមមើល រឿងក្ដីលេខ F17 ក្នុងឧបសម្ព័ន្ធ ២។

បំណុល

តាមរយៈការស្ទង់មតិរបស់ IRL ទាំងស្ត្រី ទាំងអាជ្ញាធរផ្លូវការ និងអាជ្ញាធរឃុំ បានចាត់ទុកថា បំណុលគឺជាបញ្ហាសង្គមមួយដ៏សំខាន់ដែរ។ ប្រាក់កម្ចីត្រូវបានរកពីទីផ្សារហិរញ្ញវត្ថុក្រៅផ្លូវការ ដោយសារតែភាពក្រីក្រនៅតាមជនបទ និងភាពខ្វះខាតមធ្យោបាយដើម្បីទៅរកទីផ្សារហិរញ្ញវត្ថុផ្លូវការ។ ប្រជាពលរដ្ឋភាគច្រើនមិនមាន ប័ណ្ណកម្មសិទ្ធិលើដីធ្លីរបស់ខ្លួន ឬប្រាក់ចំណូលទៀងទាត់នោះទេ ពួកគេមិនអាចសុំខ្ចីប្រាក់ពីស្ថាបន័ហិរញ្ញវត្ថុផ្លូវការបានឡើយ( ធនាគារ)។ នៅក្នុងស្ថាប័នហិរញ្ញវត្ថុផ្លូវការអត្រាការប្រាក់លើកម្ចីទាបជាងនៅតាមទីផ្សារហិរញ្ញវត្ថុក្រៅផ្លូវការ។ នៅពេលដែលឪពុកម្តាយត្រូវការលុយដើម្បីទ្រទ្រង់ក្រុមគ្រួសាររបស់គេ ពួកគេសុំខ្ចីប្រាក់ពីអ្នកជិតខាងដែលមានទ្រព្យសម្បត្តិច្រើនជាង ហើយមានអត្រាការប្រាក់ខ្ពស់ (៥ទៅ១០ដងខ្ពស់ជាងអត្រាការប្រាក់ដែលចែងដោយច្បាប់)។ ពេលខ្លះកូនបំណុលមិនអាចមានលទ្ធភាពសងវិញទេ ដោយសារតែអត្រាការប្រាក់ខ្ពស់ពេក។ ប្រាក់កម្ចីក្លាយទៅជាប្រភពនៃវិវាទជាច្រើននៅមូលដ្ឋាន។ ជារឿយៗ បញ្ហាសង្គមបែបនេះក៏បានក្លាយទៅជា *ព្រឹត្តិការណ៍ដែលអាចជារឿងក្តីបាន* ដែលត្រូវបានម្ចាស់បំណុលដាក់ពាក្យប្តឹងទៅអាជ្ញាធរឃុំ ឬនគរបាល ឬតុលាការ ឱ្យដោះស្រាយ ដោយថាគឺជា រឿងរំលោភលើកិច្ចសន្យា ឬជាបទល្មើសឆបោកក៏មាន។

ពេលខ្លះមានអ្នកធានាជួយអ្នកជិតខាង ដែលក្រក្នុងការសុំខ្ចីបុលពីអ្នកមានដែរ។ ករណីនេះប្រសិនបើកូន បំណុលមិនអាចបង់ការប្រាក់ ឬបំណុលវិញទេ បញ្ហារឿងក្តីនឹងកើតឡើង។ នៅពេលចំនួនប្រាក់ច្រើន កិច្ចសន្យាត្រូវ បានចុះហត្ថលេខានៅចំពោះមុខអាជ្ញាធរមូលដ្ឋាន ឬជួនពេលខ្លះនៅមុខនគរបាល។

> *"កិច្ចសន្យានេះធ្វើឡើងរវាងម្ចាស់បំណុល GG និងកូនបំណុល NN ។ NN បានព្រមសងប្រាក់មួយតម្លឹងមាសទៅឱ្យ GG ។ ប៉ុន្តែឆ្នាំនេះ NN អាចឱ្យបានតែ ៥ជីមាស ហើយប្រាក់ដែលនៅសល់នឹងសងនៅខែមេសា ឆ្នាំ២០០១។ ហេតុដូច្នេះ សូមអាជ្ញាធរភូមិ និងឃុំសម្រេច។ គូភាគីទាំងពីរសុខចិត្តផ្តិតមេដៃទុកជាចំណាំ [១០៤]"* ។

ចុងក្រោយ ម្ចាស់បំណុលតែងធ្វើសកម្មភាពដោយខ្លួនឯង ក្នុងការទាមទារប្រាក់កម្ចីមកវិញ។ ឧទាហរណ៍ដូចជា បុគ្គលម្នាក់ដោយមានអំណាចនយោបាយផងនោះ បានរឹបយកដីរបស់កូនបំណុល នៅពេលដែលកូនបំណុលមិនអាចសងប្រាក់ដែលបានខ្ចីនោះមកវិញ។

> **រឿងក្តីបំណុលនៅក្នុងខេត្តកំពង់ស្ពឺ** [១០៥]
>
> *អ្នកភូមិម្នាក់បានសុំខ្ចី (៥០.០០០រៀល) ពីអ្នកជិតខាងម្នាក់ដែលមានការគាំទ្រនយោបាយពីគណបក្សនយោបាយមួយ ហើយក្រោយមកបានក្លាយទៅជាសមាជិកក្រុមប្រឹក្សាឃុំ។*
>
> *នៅពេលដែលកូនបំណុលមិនអាចសងវិញ ដោយសារអត្រាការប្រាក់ខ្ពស់ពេក ម្ចាស់បំណុលបានរឹបអូសដីយកពីកូនបំណុល។ ម្ចាស់បំណុលបានកាន់កាប់ដីរបស់កូនបំណុលអស់ពេល ៣ ឆ្នាំហើយ។ កូនបំណុលបានសំណូមពរជាច្រើនលើកឱ្យផ្ទេរដីគាត់មកវិញ ប៉ុន្តែគាត់មិនបានទទួលដីមកវិញទេ ដោយសារម្ចាស់បំណុលមានអំណាចនយោបាយ។*

---

[១០៤] សូមមើល រឿងក្តីលេខ G1 ក្នុងឧបសម្ព័ន្ធ ២។

[១០៥] តាមរយៈដំណើរការទស្សនកិច្ចសិក្សា ក្រុមការងារសិក្សាស្រាវជ្រាវបានកត់សំគាល់អំពីករណីនេះ ហើយក្រោយមកចៅក្រមបានបញ្ជាក់បន្ថែមអំពីករណីនេះ

ទីបំផុត កូនបំណុលបានដាក់ពាក្យប្តឹងទៅតុលាការដើម្បីទាមទារដីរបស់គាត់វិញ។ រឿងក្តីនេះ កំពុងរង់ចាំការកាត់ក្តីនៅតុលាការខេត្ត។

តារាង: ទស្សនៈរបស់អ្នកចូលរួមសិក្ខាសាលា ស្តីអំពីវិវាទចម្បងៗនៅមូលដ្ឋាន និងរឿងក្តីព្រហ្មទណ្ឌ

| បញ្ហាចម្បងៗ | ប្រភេទនៃវិវាទ | ខ្លឹមសារ |
|---|---|---|
| **វិវាទនៅតាមមូលដ្ឋានគ្រប់ប្រភេទរវាងអ្នកភូមិ** | វិវាទតូចតាចលើអចលវត្ថុនានា | - វិវាទលើព្រំដី<br>- ការទាមទារជាន់គ្នាលើដី (ភាគច្រើនដីដែលមិនទាន់ចុះបញ្ជី)<br>- វិវាទលើការប្រើប្រាស់ស្រះ/អណ្តូង<br>- វិវាទលើច្រកចេញចូលផ្ទះ/ដីរួម |
| | វិវាទទាក់ទងនឹងដំណាំ និងសត្វពាហនៈ | - ដំណាំដែលបំផ្លាញដោយសត្វពាហនៈ<br>- ដំណាំដាំដុះនៅក្នុងទ្រព្យសម្បត្តិអ្នកដទៃ<br>- វិវាទទាក់ទងនឹងសត្វចិញ្ចឹម |
| | ជម្លោះជាមួយអ្នកជិតខាង និងក្នុងគ្រួសារ | - ជម្លោះនឹងអ្នកជិតខាង ការបរិហារកេរ្តិ៍/ការនិយាយដើម ការចោទប្រកាន់ថាមានសាហាយស្មន់<br>- ការចោទប្រកាន់ពីអំពើអាបធ្មប់ |
| | បំណុល | - ប្រជាពលរដ្ឋខ្លះបានសុំខ្ចីលុយពីអ្នកជិតខាងដែលជាអ្នកមាន ដោយមានអត្រាការប្រាក់ខ្ពស់។ បន្ទាប់មក កូនបំណុលមិនអាចសងវិញបានដោយសារតែអត្រាការប្រាក់។ ក្នុងរឿងខ្លះ ម្ចាស់បំណុលប្រើទម្រង់ នៃសំពាធផ្សេងៗ រួមទាំងការចោទប្រកាន់ពីបទឆបោកថែមទៀត។ |
| | រឿងក្តីរដ្ឋប្បវេណីផ្សេងៗ | - ការរំលោភលើកិច្ចសន្យាខាងពាណិជ្ជកម្ម<br>- ការបែងចែកទ្រព្យសម្បត្តិជាកេរ្តិ៍មរតក និងគ្រួសារ<br>- រឿងក្តីរដ្ឋប្បវេណីផ្សេងៗទៀត |
| | បទល្មើសព្រហ្មទណ្ឌ | ដោះស្រាយនៅថ្នាក់មូលដ្ឋាន |

## ៣.២. វិវាទទាក់ទិននឹងដីធ្លី

យោងទៅលើការស្ទង់មតិរបស់ IRL ក្រុមគោលដៅទាំងអស់យល់ថាវិវាទទាក់ទិននឹងដីធ្លី គឺជាបញ្ហាចម្បងក្នុងសង្គម។ ៨៥%នៃប្រជាពលរដ្ឋទាំងអស់រស់នៅតាមតំបន់ជនបទ សិទ្ធិប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ គឺជារឿងសំខាន់ក្នុងការចិញ្ចឹមជីវិត។ វិវាទដីធ្លី គឺជាវិវាទមួយក្នុងចំណោមវិវាទដែលកើតឡើងញឹកញាប់ជាងគេ។ ភាពខ្វះខាតការធានាតាមផ្លូវច្បាប់លើអចលនវត្ថុ ដោយសារកង្វះខាតប័ណ្ណកម្មសិទ្ធិផ្តល់ជូនភោគីភាគច្រើននោះ (ប្រហែល ៨០%) គឺជាប្រភពចម្បងនៃវិវាទ។ បញ្ហាសិទ្ធិកាន់កាប់ ដីធ្លីនេះជាមូលហេតុនៃវិវាទជាច្រើនរួមទាំង: វិវាទតូចតាចទាក់ទងនឹងព្រំដី ការប្រើប្រាស់ស្រះ ការកាប់ឆ្កាលើដីអ្នកដទៃ និងការផ្ទេរកម្មសិទ្ធិដីធ្លី)ជាដើម។ នៅប៉ុន្មានឆ្នាំចុងក្រោយថ្មីៗនេះ មានបញ្ហាទាក់ទិននឹងសិទ្ធិកាន់កាប់នេះនៅក្នុងប្រទេសកាន់តែធ្ងន់ធ្ងរឡើងៗ។ ប្រជាពលរដ្ឋមករកអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយវិវាទទាំងឡាយដែលកើតមាននៅក្នុងមូលដ្ឋាន។ នេះក៏ជាអ្វី មួយដែលធ្លាប់បានកើតនៅក្នុងនីតិវិធីពីអតីតកាលផងដែរ។ អាជ្ញាធរមូលដ្ឋានមិនទាន់មានបទពិសោធន៍ និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីដោះស្រាយស្ថានភាព និងបញ្ហាថ្មីៗទាំងឡាយនេះនៅឡើយទេ ដែលបញ្ហាទាំងនោះមានដូចជា: បញ្ហាទាក់ទងនឹងប័ណ្ណ កម្មសិទ្ធិដីធ្លី សកម្មភាពក្រុមហ៊ុន ការបាត់បង់ភោគៈនៃគ្រួសារមួយចំនួនធំ ដោយសារការធ្វើសម្បទានដីធំៗ

ការចាប់យកដីពីសំណាក់អ្នកមានអំណាច ឬអ្នកទិញដើម្បីកេងចំណេញ និងការបណ្តេញចេញដោយបង្ខំ ជាពិសេសការទន្ទ្រានយកដីសមូហភាពរបស់ជនជាតិដើមភាគតិច ដោយអ្នកខាងក្រៅ គឺជារឿងមួយធ្ងន់ធ្ងរ ។

តារាង: ទស្សនៈរបស់អ្នកចូលរួមសិក្ខាសាលា ស្តីអំពីវិវាទដីធ្លីធំៗ

| | ប្រភេទវិវាទ | ខ្លឹមសារ |
|---|---|---|
| **វិវាទលើដីធ្លីធំៗ និងធនធានធម្មជាតិ រវាងអ្នកភូមិ និង ភាគីមានអំណាច** | វិវាទទាក់ទងនឹងដីសម្បទាន និងក្រុមហ៊ុន | - ការរឹបអូស និងការកាន់កាប់ដោយអាជ្ញាធរព្រៃឈើ និងក្រុមហ៊ុនដទៃទៀត ។<br>- ការបណ្តេញអ្នកភូមិចេញដោយបង្ខំ ដោយសារមានសម្បទានលើដីដែលមិនទាន់បានចុះបញ្ជី ។<br>- ការរឹបអូសថ្មីៗ និងការកាន់កាប់ដីឋិតនៅក្បែរផ្លូវ ។<br>- ការបំពុលបរិស្ថានដោយក្រុមហ៊ុននានា ។ |
| | យោធា | ការរឹបអូសយកដីធ្វើឡើងដោយយោធា ។ |
| | វិវាទជាមួយអ្នកមានទ្រព្យសម្បត្តិ | ការចោទប្រកាន់ថាបានរំលោភចូលដោយខុសច្បាប់ និងការកាន់កាប់លើអចលនទ្រព្យឯកជន ធ្វើឡើងដោយអ្នកមានទ្រព្យសម្បត្តិប្រឆាំងនឹងអ្នកភូមិ ។ |
| | ដីរបស់សហគមន៍ជនជាតិដើមភាគតិច | - ការទន្ទ្រានយកដីរបស់ជនជាតិដើមភាគតិចដោយអ្នកខាងក្រៅ<br>- បញ្ហារឹបអូសយកដីដែលមានពេលបច្ចុប្បន្ន កំពុងរង់ចាំការដោះស្រាយនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ដោយសារតែកង្វះខាតប័ណ្ណកម្មសិទ្ធិ ។<br>- ការការពារទ្រព្យសម្បត្តិរួមរបស់ជនជាតិដើមភាគតិច នៅក្នុងច្បាប់ភូមិបាលមិនទាន់ត្រូវបានគេអនុវត្តនៅឡើយ ។ |

បញ្ហាកើតឡើងដោយសារការផ្លាស់ប្តូរច្បាប់គ្រប់គ្រងដីធ្លី

មានការផ្លាស់ប្តូរជាច្រើន និងខ្លាំងក្លានៅក្នុងប្រព័ន្ធច្បាប់គ្រប់គ្រងដីធ្លីនៅក្នុងទសវត្សរ៍កន្លងមកនេះ ហើយសង្គ្រាមបានបំផ្លាញយន្តការរដ្ឋក្នុងការគ្រប់គ្រងការប្រើប្រាស់ដីធ្លី នាំឱ្យកើតមាននូវភាពគ្មានសុវត្ថិភាពផ្លូវច្បាប់លើកម្មសិទ្ធិអចលនវត្ថុ ។

ចាប់ពីឆ្នាំ១៩៧៥ ដល់១៩៨៩ ច្បាប់មិនទទួលស្គាល់ទ្រព្យសម្បត្តិឯកជនទេ ។ ដីទាំងអស់ត្រូវបានប្រកាសថាជាសម្បត្តិរបស់រដ្ឋ ។ ក្រោយពួកខ្មែរក្រហមឡើងកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ ពួកគេបានដកហូតទ្រព្យសម្បត្តិទាំងអស់ ដូចជាដីធ្លីជាដើមដាក់ជាសម្បត្តិរួម ។ គេបានបំផ្លាញឯកសារដីធ្លីស្ទើរតែទាំងអស់ និងបណ្តេញប្រជាពលរដ្ឋទាំងអស់ចេញពីដីកេរ្តិ៍របស់ពួកគេ ។ ប្រជាពលរដ្ឋត្រូវធ្វើការនៅក្នុងវាលស្រែ ដោយគ្មានកម្មសិទ្ធិអ្វីទាំងអស់លើដីធ្លី ។ នៅក្នុងទសវត្សរ៍បន្ទាប់ (១៩៧៩-១៩៨៩) ដីទាំងអស់នៅតែជាសម្បត្តិរបស់រដ្ឋ ។ ក្រោយការចាកចេញរបស់កងទ័ពវៀតណាមនៅឆ្នាំ១៩៨៩ រដ្ឋបានបដិសេធកម្មសិទ្ធិដែលមានមុនឆ្នាំ១៩៧៥ ប៉ុន្តែបានសើរើកែប្រែទស្សនៈលើសិទ្ធិកម្មសិទ្ធិឯកជន ។ ក្រោយពីរបបសមូហភាពបានកន្លងផុតទៅ រដ្ឋចាប់ផ្តើមបែងចែកដីធ្លីទៅឱ្យគ្រួសារនានា នៅតាមជនបទឡើងវិញ ប៉ុន្តែពួកគេមិនបានទទួលប័ណ្ណកម្មសិទ្ធិនោះទេ ។

វិសោធនកម្មរដ្ឋធម្មនុញ្ញក្នុងឆ្នាំ១៩៨៩ បានបង្កើតនូវការចាប់ផ្តើមប្រព័ន្ធទ្រព្យសម្បត្តិឯកជន។ តែទោះជាយ៉ាងណាក្តី កម្មសិទ្ធិលើដីក្រៅពីលំនៅដ្ឋានមិនត្រូវបានអនុញ្ញាតទេ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១ បាននាំមកនូវបែបផែនថ្មីក្នុងការប្រើប្រាស់ និងការចាត់ចែងដីធ្លី។ ទសវត្សរ៍ឆ្នាំ៩០ បានជួបប្រទះនូវបញ្ហាប្រជាពលរដ្ឋមានស្ថានភាពមិនច្បាស់លាស់ ដោយមានការវិលត្រលប់មកពីជំរុំជនភៀសខ្លួនជាច្រើន ការបើកសេដ្ឋកិច្ចទីផ្សារ ភាពខ្វះសុវត្ថិភាពលើដីធ្លី ការចាប់យកដីធ្លី និងវិវាទលើដីធ្លីជាច្រើន ដោយគ្មានមធ្យោបាយតាមផ្លូវស្ថាប័នប្រកប ដោយប្រសិទ្ធិភាពណាមួយ អាចធ្វើការដោះស្រាយរឿងទាំងនេះបានឡើយ។ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ ច្បាប់ភូមិបាលត្រូវបានអនុម័ត ហើយវាបានគ្របដណ្តប់លើសិទ្ធិទ្រព្យសម្បត្តិឯកជនលើដីធ្លី។ ទោះជាយ៉ាងណាក្តី មានប្រជាពលរដ្ឋភាគច្រើនមិនទាន់បានទទួលនូវការផ្តល់ដីធ្លីជាផ្លូវការ ឬប័ណ្ណកម្មសិទ្ធិលើដីធ្លីនៅឡើយទេ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តក្នុងឆ្នាំ១៩៩៣ បានផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចទីផ្សារ ដោយទទួលស្គាល់ទ្រព្យសម្បត្តិរដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់ ពោលគឺកម្មសិទ្ធិឯកជន និងកម្មសិទ្ធិរួម។ នៅក្នុងខែសីហា ឆ្នាំ២០០១ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តច្បាប់ភូមិបាលថ្មីមួយ។ ច្បាប់នេះមានគោលបំណងដោះស្រាយនូវរឿងក្តីដែលមិនបានគ្រប់គ្រងពីមុនមក ដូចជាការជួលអចលនវត្ថុ ដីសម្បទាន សហកម្មសិទ្ធិករ ដីសហគមន៍ជនជាតិដើមភាគតិច សម្រង់សុរិយោដី ការចុះបញ្ជីនិងប័ណ្ណកម្មសិទ្ធិដីធ្លី និងការដោះស្រាយវិវាទទាក់ទងនឹងដីធ្លី។ តែទោះជាយ៉ាងនេះក្តី ច្បាប់នេះតម្រូវឱ្យមានអនុក្រឹត្យជាច្រើនទៀត ដើម្បីឱ្យបញ្ញត្តិរបស់ច្បាប់អាចអនុវត្តមានប្រសិទ្ធិភាពពេញលេញ។

**សាវតានៃក្របខ័ណ្ឌច្បាប់:**

| ឆ្នាំ | បញ្ញត្តិច្បាប់ | បញ្ហា |
|---|---|---|
| ១៩៧៥-១៩៧៩ | គ្មាន | គ្មានកម្មសិទ្ធិករ ដូច្នេះគ្មានវិវាទ |
| ១៩៧៩-១៩៨៩ | ពុំមានច្បាប់ចែងពីទ្រព្យសម្បត្តិឯកជន | ដីទាំងអស់ត្រូវបានប្រកាសថា ជាទ្រព្យសម្បត្តិរបស់រដ្ឋ |
| ២២ មេសា ១៩៨៩ | អនុក្រឹត្យស្តីពីការប្រគល់កម្មសិទ្ធិលើដីលំនៅដ្ឋាន ដល់ប្រជាពលរដ្ឋកម្ពុជា | មិនអនុញ្ញាតឱ្យមានកម្មសិទ្ធិ លើដីលំនៅដ្ឋាន។ |
| ១៣ តុលា ១៩៩២ | *ច្បាប់ភូមិបាល*<br>ច្បាប់នេះបានបន្ថែមសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ ឯកជន លើដីធ្លី | ប្រជាពលរដ្ឋភាគច្រើនពុំបានទទួលប័ណ្ណកម្មសិទ្ធិឡើយ។ |
| ២១ កញ្ញា ១៩៩៣ | រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ (វិសោធនកម្មឆ្នាំ១៩៩៩)<br>មាត្រា ៤៤ : ជនណាក៏ដោយ ទោះបីជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជា ខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ | ផ្តល់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ តែភាគច្រើនពុំមានប័ណ្ណកម្មសិទ្ធិ |
| ៣០ សីហា ២០០១ | *ច្បាប់ភូមិបាល (ថ្មី)*<br>- ច្បាប់នេះមានគោលដៅចែងបំពេញនូវភាពខ្វះចន្លោះ នៃច្បាប់ក្នុងវិស័យមួយចំនួន ដូចជាការជួលដីសម្បទានដីសហគមន៍ជនជាតិដើមភាគតិច សហកម្មសិទ្ធិករ សម្រង់សុរិយោដី ការចុះបញ្ជី និងប័ណ្ណកម្មសិទ្ធិដីធ្លី និងការដោះស្រាយវិវាទទាក់ទងនឹងដីធ្លី។ | មានប្រសិទ្ធិភាពទាបក្នុងការអនុវត្តន៍ច្បាប់ ដោយហេតុថា ខ្វះបទបញ្ញត្តិផ្សេងៗទៀតដែលចាំបាច់ និងខ្វះខាតនូវមធ្យោបាយ ដើម្បីអនុវត្តច្បាប់ ។<br>- នៅតែខ្វះប័ណ្ណកម្មសិទ្ធិ ក៏ដូចជាការបែងចែកប្រភេទផ្សេងៗនៃដីធ្លី ។ |

កង្វះខាតនៃប័ណ្ណកម្មសិទ្ធិដីធ្លី

ជាង ៨០% នៃដីធ្លីក្នុងប្រទេសកម្ពុជាមិនទាន់ត្រូវបានចុះបញ្ជីដីធ្លីនៅឡើយទេ ហើយអ្នកកាន់កាប់ (ភោគី) មិនទាន់មានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវនៅឡើយទេ។ វាជារឿងមិនធម្មតាទៅវិញសម្រាប់ម្ចាស់ទ្រព្យសម្បត្តិ ក្នុងការមានប័ណ្ណកម្មសិទ្ធិដីធ្លីតាមច្បាប់នោះ។ កង្វះខាតសុវត្ថិភាពផ្លូវច្បាប់នៃការកាន់កាប់ (ភោគៈ) គឺជាប្រភពនៃវិវាទគ្រប់ជំពូកទាំងរឿងតូច និងរឿងធំ។

មាត្រា ២៣៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១ តម្រូវឱ្យមាន "ផែនទីសុរិយោដី" ដែលត្រូវបានធ្វើឡើងចំពោះ គ្រប់អចលនទ្រព្យទាំងអស់នៅកម្ពុជា។ ប៉ុន្តែមានក្បាលដីភាគច្រើនណាស់នៅកម្ពុជា មិនទាន់ត្រូវបានចុះបញ្ជី ឬមិនទាន់បានកំណត់ព្រំប្រទល់ច្បាស់លាស់នៅឡើយទេ ជាពិសេសដីស្រែ និងដីកសិកម្មនៅតាមតំបន់ដាច់ស្រយាល។ មានវិធីពីររបៀបក្នុងការចុះបញ្ជីដីធ្លីនៅកម្ពុជាៈ ១-ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ២-ការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ។ ការចុះបញ្ជីតាមបែបទីមួយ គឺជាយន្តការរបស់រដ្ឋក្នុងការចុះបញ្ជីប័ណ្ណកម្មសិទ្ធិទូទាំងប្រទេស ដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងធ្វើការជ្រើសរើសតំបន់អាទិភាព ដើម្បីចុះបញ្ជីដំបូងគេក្រោមការចំណាយរបស់រដ្ឋ។ ការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ គឺសំដៅដល់នីតិវិធី ដែលម្ចាស់ដីនានាទៅចុះបញ្ជីដីធ្លីរៀងៗខ្លួន ដែលជារឿយៗគេតម្រូវឱ្យមានប័ណ្ណកម្មសិទ្ធិដីធ្លី សម្រាប់ការខ្ចីប្រាក់ពីធនាគារ ឬគោលដៅអាជីវកម្ម។ រឿងចុះបញ្ជីដាច់ដោយដុំនេះ បង្កឱ្យមានវិវាទដីធ្លីលើព្រំដី និងការកាន់កាប់ក្បាលដី ព្រមទាំងការចាប់យកដីធ្លីដោយអ្នកមាន និងអ្នកមានអំណាចផងដែរ។

ឧទាហរណ៍ខាងក្រោមនេះ បង្ហាញអំពីវិវាទមួយប្រភេទ ដែលកើតឡើងដោយសារការមិនមាន ប័ណ្ណកម្មសិទ្ធិ និងវិវាទលើរឿងព្រំដីនៅថ្នាក់មូលដ្ឋាន។ អាជ្ញាធរមូលដ្ឋានបានផ្តល់សិទ្ធិប្រើប្រាស់ដីដល់អ្នកកាន់កាប់ថ្មី ហើយបន្ទាប់មកភោគីមុនបានប្តឹងទាមទារវិញ។ ទំហំដីដែលបានទាមទារ (មានមិនលើសពី ៥ម៉ែត្រការ៉េ) ឬតម្លៃនៃបណ្តឹង (២ទៅ៥ដុល្លារអាមេរិក) ហាក់ដូចជាតិចតួចណាស់ ប៉ុន្តែវាមិនតិចតួចទេសម្រាប់អ្នកដែលពាក់ព័ន្ធក្នុងរឿងក្តី បើគិតដល់ចំណូលប្រចាំថ្ងៃនៅឯជនបទ ដែលមានប្រហែលតែមួយដុល្លារក្នុង១ថ្ងៃនោះ។

***ការដោះស្រាយវិវាទដោយគណៈកម្មការភូមិសម្រាប់ដោះស្រាយវិវាទ ភូមិទួលច័ន្ទ ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០០៤ [១០៦] ។***

*លោកស្រី WW ជាស្ត្រីមេម៉ាយដែលមានកូនប្រុសម្នាក់ ហើយរស់នៅក្នុងភូមិទួលច័ន្ទ ឃុំតាំងក្រសាំង។ នៅក្នុងឆ្នាំ ២០០៣ លោកស្រី WW បានលួសឆាយកាប់ឆ្ការលើដី ដែលមិនបានប្រើប្រាស់នៅក្នុងភូមិដើម្បីធ្វើស្រែចំការ ហើយគាត់បានបង្កបង្កើនផលលើដីនោះដោយសុខស្រួលអស់ពេល ២ឆ្នាំ។ នៅក្នុងខែមករា ២០០៥ លោក MM ដែលរស់នៅក្នុងភូមិ ជាមួយគ្នានោះបានមកមើលហើយបានទាមទារថា ដីមួយចំណែកដែលបានសំអាតដោយ WW គឺជាដីរបស់គាត់ ដោយបានអះអាងថាដីនោះ ត្រូវបានអាជ្ញាធរឃុំប្រគល់ឱ្យគាត់ក្នុងកំឡុងទសវត្សរ៍ ៨០ ហើយបន្ទាប់មកគាត់ក៏មកធ្វើរបងលើដីមួយចំណែកនោះ។*

*WW កើតទុក្ខមិនសុខចិត្ត នឹង MM ហេតុដូចនេះ គាត់ក៏ដាក់ពាក្យមកមេភូមិ ដែលជាប្រធានគណៈកម្មការភូមិសម្រាប់ដោះស្រាយវិវាទផងដែរ។ គណៈកម្មការសម្រាប់ដោះស្រាយវិវាទ ត្រូវបានបង្កើតឡើងនៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០០៥។ សមាជិករបស់គណៈកម្មការសម្រាប់ ដោះស្រាយវិវាទគ្រប់រូបជាបុរស។ ក្រោយពីទទួលពាក្យបណ្តឹងមក មេភូមិបានកំណត់យកថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០០៥ ធ្វើការដោះស្រាយវិវាទ និងកោះអញ្ជើញគូភាគី។*

[១០៦] ក្រុមការងារសិក្សាស្រាវជ្រាវ បានសង្កេតរឿងក្តីនេះនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៤។ នេះជាករណីជាក់ស្តែង (រឿងពិត) តែឈ្មោះភាគីពាក់ព័ន្ធមិនត្រូវបានបញ្ចេញឡើយ ដើម្បីការពារភាពឯកជនដល់ភាគី។ សូមមើលរឿងក្តីលេខ D10 ក្នុងឧបសម្ព័ន្ធ ២។

នៅថ្ងៃទី១៧ កុម្ភៈ ២០០៥ គូភាគី និងសមាជិកគណៈកម្មការភូមិទាំងបួនរូប មានវត្តមាននៅផ្ទះមេភូមិ ដើម្បីធ្វើការប្រជុំសម្រុះសម្រួល។ មេភូមិបានប្រាប់គូភាគីពីសិទ្ធិរបស់ពួកគេ ក្នុងការជ្រើសរើសអ្នកសម្រុះសម្រួល។ ww បានជ្រើសរើសលោក vc មេភូមិជាអ្នកសម្រុះសម្រួល ហើយ MM បានជ្រើសរើសលោក DD បន្ទាប់មកអ្នកសម្រុះសម្រួល ដែលបានជ្រើសតាំងបានជ្រើសរើសលោក PP ជាលេខាកត់ត្រាក្នុងដំណើររឿង។ បន្ទាប់មកការសម្រុះសម្រួលបានចាប់ផ្តើម។ ជាបឋមលោក vc បានស្នើសុំឱ្យគូភាគីនិយាយប្រាប់ពី មូលហេតុដើមទងនៃវិវាទ និងអ្វីដែលពួកគេចង់ធ្វើការដោះស្រាយ។

ww បាននិយាយថា គាត់បានប្រឹងកាប់ឆ្ការជាមួយកូនប្រុសគាត់លើដីនេះ ហើយគាត់មិនអាចប្រគល់ដីនេះ ដោយគ្មានកំរៃអ្វីសោះទៅ MM ទេ។ គាត់និយាយថា គាត់បានសុំការអនុញ្ញាតពីមេភូមិ មុនពេលគាត់ទៅកាប់ឆ្ការនៅលើដីនោះ។ គាត់អាចប្រគល់ដីនោះទៅ MM ប្រសិនបើគាត់បាន ធ្វើស្រែចំការលើដីនោះបាន ៥ឆ្នាំទៀត។
MM បាននិយាយថា គាត់មិនបន្ទោស ww ថាលួចដីគាត់ទេ។ គាត់គ្រាន់តែសុំឱ្យ ww· ប្រគល់ដីនេះ មកគាត់វិញ ហើយគាត់អាចបង់កំរៃពលកម្មដែល ww បានធ្វើលើដីនោះ ជាជាងការទទួលបានមកវិញនៅក្នុង ៥ឆ្នាំទៀត។ គាត់មិនបានទាមទារដីទាំងអស់ ដែលស្ត្រីនោះបានកាប់ឆ្ការនោះទេ គឺត្រឹមតែមួយចំណែកប៉ុណ្ណោះ ប្រហែល ៥ ម៉ែត្រការ៉េ។

អ្នកសម្រុះសម្រួលម្នាក់បាននិយាយថា: "ឥឡូវនេះ យើងបានដឹងពីមូលហេតុនៃវិវាទហើយ។ យើងគឺជាអ្នកជិតខាងគ្នា ដូច្នេះយើងគួរតែស្រុះស្រួលគ្នាទៅដើម្បីបញ្ចប់វិវាទ។ វាមិនមែនជាបញ្ហាធ្ងន់ធ្ងរទេ។ MM ស្គាល់ ww ច្បាស់ណាស់ ហើយយើងគួរជួយគាត់ពីព្រោះគាត់ជាស្ត្រីមេម៉ាយ ហើយទន់ខ្សោយទៀត"។
ជាការឆ្លើយតប ww បានទាមទារ ២០.០០០ រៀល (៥ ដុល្លារ) សម្រាប់ការងាររបស់គាត់លើដីនោះ។ "ប្រសិនបើ MM ព្រមបង់ជូនខ្ញុំនូវតម្លៃប៉ុណ្ណឹង ខ្ញុំនឹងសងដីនោះវិញ"។ តែ MM បាននិយាយថា "ចំនួននេះច្រើនពេកហើយសម្រាប់ខ្ញុំ។ ប្រសិនបើខ្ញុំត្រូវបង់សងប៉ុណ្ណឹង ខ្ញុំសុខចិត្តប្រគល់ដីនោះវិញល្អជាង"។

បន្ទាប់មកអ្នកសម្រុះសម្រួលម្នាក់ បានសំណូមពរគូភាគីមកត្រឹម ១០.០០០ រៀល (២.៥ ដុល្លារ)។ ww បានយល់ព្រមលើសំណើនេះ ប៉ុន្តែ MM បដិសេធ និងស្នើសុំត្រឹម ៧.០០០ រៀល (១.៧៥ ដុល្លារ)។ ww បាននិយាយថា : "៧.០០០រៀល ថោកពេកសម្រាប់ការងាររបស់ខ្ញុំ"។ ដោយគូភាគីមានការរាំងស្ទះលើការចរចា អ្នកសម្រុះសម្រួលបានស្នើ ៨.០០០ រៀល (២ដុល្លារ) សម្រាប់គូភាគី បន្ទាប់មក ww និង MM បានយល់ព្រម។
ក្រោយគូភាគីបានយល់ព្រមលើសំណូមពរនោះ គណៈកម្មការបានរៀបចំកិច្ចសន្យាមួយសម្រាប់គូភាគី និងសាក្សីដើម្បីចុះហត្ថលេខា។

## កង្វះខាតការបែងចែកប្រភេទដី

ច្បាប់ភូមិបាល (ឆ្នាំ២០០១) បានបែងចែកដីនៅកម្ពុជាជាប្រភេទផ្សេងៗដូចខាងក្រោមនេះ : ដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ដីឯកជន ដីវត្ត និងអចលនទ្រព្យរបស់ជនជាតិដើមភាគតិច។ ដើម្បីអនុវត្តច្បាប់ភូមិបាលបានអនុក្រឹត្យសំខាន់ៗមួយចំនួនត្រូវតែបានអនុម័តដូចជា *បទបញ្ញត្តិ និងនីតិវិធី នៃការគ្រប់គ្រង ទ្រព្យសម្បត្តិរដ្ឋ* និង*ដីសហគមន៍*។ ដោយសារអនុក្រឹត្យទាំងអស់នេះមិនទាន់បានអនុម័ត ក៏ដូចជាការចុះបញ្ជី និងការចុះវាស់វែងឱ្យបានត្រឹមត្រូវនោះ រដ្ឋនៅតែមិនអាចបែងចែកប្រភេទដីនៅកម្ពុជាបានឡើយ។ លទ្ធផលនាំឱ្យមានបញ្ហាធ្ងន់ធ្ងរជាច្រើន ដូចជាការផ្តល់សម្បទានដីលើដី ដែលកំពុងត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ នៅតាមមូលដ្ឋាន ការបណ្តេញចេញប្រជាពលរដ្ឋនៅមូលដ្ឋានដោយអាជ្ញាធររបស់រដ្ឋ ដូចជាកងទ័ព

ឬមន្ត្រីរដ្ឋបាលព្រៃឈើ ដែលបានអះអាងថាដីទាំងនោះជាដីរដ្ឋ និងការទន្ទ្រានយកដីសម្ភូហភាពរបស់ជនជាតិដើមភាគតិច ដោយអ្នកខាង ក្រៅជាដើម។

ការធ្វើសម្បទានៈ

សម្បទានដីធ្លី បានក្លាយទៅជាចំណុចចម្បងមួយសម្រាប់វិវាទនៅតាមជនបទ យោងតាមរបាយការណ៍របស់អង្គការសហប្រជាជាតិ [១០៧] ។

នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ៩០ គោលនយោបាយសម្បទានព្រៃឈើឱ្យទៅក្រុមហ៊ុនធំៗ ដែលផ្តួចផ្តើមគំនិតដោយរដ្ឋាភិបាលមុនៗ នាំឱ្យមានការផ្ទេរដីធ្លីប្រហែលមួយភាគបី នៃដីផលិតកម្មទាំងអស់របស់ប្រទេសទៅឱ្យក្រុមហ៊ុនទាំងនោះ។ វិសាលភាពនៃសម្បទានទាំងនេះធ្វើឡើងហួសពីអ្វី ដែលបានអនុញ្ញាតដោយច្បាប់។ សហគមន៍នៅតាមជនបទត្រូវបានគេបណ្តេញចេញពីដីទាំងនេះ ឬមិនត្រូវបានអនុញ្ញាតក្នុងការប្រើប្រាស់ ដើម្បីប្រមូលផល ឬធនធានធម្មជាតិដទៃទៀត ដែលពួកគាត់ធ្លាប់បានប្រើប្រាស់ជាប្រពៃណីនោះទេ។ ច្បាប់ទំនៀមទម្លាប់ ដែលទាក់ទងនឹងការប្រើប្រាស់ធនធានធម្មជាតិ មិនត្រូវបានគេអើពើសោះឡើយ។ ស្ថានភាពនេះបានបង្កើតឱ្យមានបញ្ហាចាប់យកដី ការបណ្តេញចេញដោយបង្ខំ ភាពគ្មានទីជម្រក និងការកើនឡើងនូវវិវាទ និងពាក្យបណ្តឹង [១០៨] ។

> "ព្រៃឈើ និងសម្បទាននានាមានទំហំស្មើនឹង ២,៧ លានហិចតានៃផ្ទៃប្រទេសកម្ពុជាទាំងមូលដែលមាន ១៨,១ លានហិចតា។ ការវាយតម្លៃជាអន្តរជាតិច្បាស់លាស់លើវិស័យព្រៃឈើ រួមជាមួយនឹងការរិចរិលនៃធនធាន ដែលបន្តជាប់រហូតបែបនេះ បាននាំមកនូវការធ្លាក់ចុះនូវតួលេខ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ទី៩០ នៅពេលដែលមួយភាគបីនៃដីផលិតកម្មភាគច្រើនរបស់ប្រទេស បានធ្លាក់ទៅក្នុងកណ្តាប់ដៃក្រុមហ៊ុនឯកជន។ សម្ពាធខាងប្រជាសាស្ត្រ និងការកើនឡើងស្របគ្នានូវតម្រូវការដីធ្លី ដោយការកើនឡើងនូវអត្ថប្រយោជន៍ មានន័យថាបញ្ហាដែលទាក់ទងនឹងដីធ្លីនៅតែបន្តមាន ហើយកើនឡើងជាលំដាប់ (...)។ នៅឆ្នាំ ២០០១ កម្ពុជាបានអនុម័តច្បាប់ភូមិបាលថ្មីមួយ។ ក្នុងចំណោមបញ្ហាជាច្រើន ច្បាប់នេះបានចែងពីទំហំសម្បទានដែលគួរត្រូវបានកម្រិតត្រឹម ១០.០០០ ហិចតា។ នៅពេលជាមួយគ្នានោះដែរ មានសម្បទានចំនួន ១២ ដែលបានផ្តល់ហួសពីកម្រិតនេះទៅហើយ។ សម្បទានដែលធំជាងគេគ្រប់គ្រងដោយ ក្រុមហ៊ុនភាគីមីុច ដែលមានផ្ទៃដីទាំងអស់ប្រមាណ ៣១៥.០២៨ហិចតា នៅក្នុងខេត្តពោធិសាត់ និងកំពង់ឆ្នាំង។ រហូតមកដល់ខែធ្នូ ឆ្នាំ២០០៣ គ្មានសម្បទានណាមួយ ទាំងសម្បទានខាងលើនេះក្តី ដែលចំនួនដែលលើសនោះ ត្រូវបានគេកាត់បន្ថយទំហំកំណត់ដោយច្បាប់វិញទេ។ លើសពីនេះ តំបន់មួយទំហំ ១០០.៨៥២ ហិចតា ត្រូវបានផ្តល់ទៅឱ្យក្រុមហ៊ុន Green Sea Industrial Co. Ltd នៅបីខែក្រោយពីច្បាប់ភូមិបាលបានចូលជាធរមាន ហើយដោយរំលោភយ៉ាងធ្ងន់ធ្ងរទៅលើមាត្រា ៥៩ (...)។ ការធ្វើសម្បទានទាំងនោះ បានជះឥទ្ធិពលយ៉ាងខ្លាំង មកលើសិទ្ធិរបស់សហគមន៍ ដែលរស់នៅក្នុងតំបន់ ឬក្បែរតំបន់នោះ។ ជារឿយៗ មិនមានការពិភាក្សាជាមួយនឹងសហគមន៍ឱ្យបានច្បាស់លាស់ជាមុនទេ។ សិទ្ធិប្រើប្រាស់ធនធានធម្មជាតិ ត្រូវបានគេបដិសេធ ឬហាមឃាត់។

[១០៧] តំណាងពិសេស បានចុះទៅទស្សនកិច្ចនៅក្រុមហ៊ុនសម្បទានជាច្រើន រួមទាំងចំការកៅស៊ូរបស់រដ្ឋមួយផងដែរ (ក្រុមហ៊ុនទាំងនោះមានដូចជា Haining Cie, Flour Manufacturing Cie, C.J. Cambodia Cie and the State-owned Tumring rubber plantation) ជាកន្លែងដែលគាត់បានកត់សំគាល់ឃើញស្ថានភាពដូចដែលបានរៀបរាប់មកតាំងពីដំបូង។ នៅក្រុមហ៊ុន C.J. Cambodia ប្រជាពលរដ្ឋចំនួន ១១ នាក់ត្រូវបានគេបដិសេធន៍មិនឱ្យចូលទៅក្នុងដីដែលពួកគេធ្លាប់ប្រើប្រាស់កន្លងមកដោយក្រុមហ៊ុននេះជីកជាប្រឡាយទឹកជារនាំង។ ពាក្យបណ្តឹងដែលបានប្តឹងទៅអាជ្ញាធរគឺមានលទ្ធផលតិចបំផុត" UN Commission on Human Rights: *Advisory service and technical cooperation in the field of Human Rights. Situation of human rights in Cambodia.* E/CN.4/2004/105, December 19 2003. (par. 41-47). (ចាប់ពីពេលនេះទៅត្រូវសរសេរ : E/CN.4/2004/105).

[១០៨] UN: A/RES/58/191, ទំព័រទី ៣

ដើមជ័រចុង (Resin trees) ដែលជាប្រភពពីបូរមបុរាណនៃចំណូលដ៏សំខាន់របស់គ្រួសារ នៅមូលដ្ឋាននោះត្រូវបានកាប់អស់។ វិវាទលើដីធ្លីបានកើតឡើង ហើយបរិយាកាសអស្ថេរភាពបានកើតឡើង ដោយក្រុមហ៊ុនសម្បទានិក បានជួលអ្នកយាមប្រដាប់ដោយអាវុធ ដែលជូនកាលបានគំរាមកំហែង និងសំឡុតដល់អ្នកភូមិនៅទីនោះ។

នៅក្នុងសិក្ខាសាលា អ្នកចូលរួមជាច្រើននាក់បានពិភាក្សាពីរឿងក្តីបណ្តេញចេញដោយបង្ខំ ដោយសារការឱ្យសម្បទានដីដែលចំតំបន់ដែលមានគ្រួសារជាច្រើនធ្លាប់បានរស់នៅ។

ច្បាប់ភូមិបាលបច្ចុប្បន្ន (ឆ្នាំ២០០១) បានចែងពីគណៈកម្មការសុរិយោដីនៅថ្នាក់ស្រុក ខេត្ត និងថ្នាក់ជាតិ ក្នុងការដោះស្រាយវិវាទលើដីធ្លីមិនទាន់ចុះបញ្ជី និងផ្តល់ឱ្យទៅតុលាការលើរឿងក្តី សម្រាប់ដីធ្លីដែលបានចុះបញ្ជីរួចហើយ។ គណៈកម្មការសុរិយោដីកំពុងឋិតនៅក្នុងដំណើរការកសាងស្ថាប័ន ហើយសមត្ថភាពរបស់គណៈកម្មការនៅមានកម្រិតនៅឡើយ ក្នុងការទទួលនិងដំណើរការលើវិវាទ ជាពិសេសនៅពេលដែលមានស្ថានភាពខុសគ្នាផ្នែកសេដ្ឋកិច្ច ឬផ្នែកនយោបាយរវាងគូភាគីវិវាទ។ នៅក្នុងខេត្តមួយចំនួន ដូចជានៅក្នុងខេត្តមណ្ឌលគិរី និងរតនៈគិរី គណៈកម្មការសុរិយោដីមិនមានការិយាល័យនៅគ្រប់ស្រុកទេ។ គណៈកម្មការសុរិយោដីកំពុងប្រឹងប្រែង ផ្សព្វផ្សាយព័ត៌មានស្តីពីច្បាប់ភូមិបាល តាមរយៈការបោះពុម្ពឯកសារនិងខ្សែវីដេអូ។ នៅមានការងារជាច្រើនទៀត ដែលត្រូវបំពេញ។ កង្វះខាតការយល់ដឹងច្បាប់និងសិទ្ធិ មានឥទ្ធិពលដោយផ្ទាល់លើភាពខ្វះខាតនៃតម្រូវការយុត្តិធម៌។ នៅក្នុងខេត្តមណ្ឌលគិរី និងរតនៈគិរី តម្រូវការយុត្តិធម៌នៅចំពោះមុខគណៈកម្មការសុរិយោដីមានកម្រិតទាប ជាងនៅតាមបណ្តាខេត្តផ្សេងៗ ទៀត[១០៩]។

## ៣.៣. តម្រូវការយុត្តិធម៌ជាក់លាក់របស់ស្ត្រីៈ អំពើហិង្សាខាងយេនឌ័រ និងការរើសអើង

នៅក្នុងការស្ទង់មតិរបស់ IRL សម្រាប់ស្ត្រី បន្ទាប់ពីភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារជាបញ្ហាចម្បង របស់សង្គមដែលពួកគេបានជួបប្រទះ។ គេបានបញ្ជាក់ថា បញ្ហាជាក់លាក់នានាដែលស្ត្រីជួបប្រទះ មានដូចតទៅៈ ១- ភាពក្រីក្រ ២- អំពើហិង្សាក្នុងគ្រួសារ ៣- បញ្ហាសុខភាព ៤- ការលែងលះ ៥- ការអប់រំបានតិចជាងបុរស ៦- សំពាធពីបុរស ឬអ្នកមានអំណាច ៧- ការលំបាកក្នុងការស្វែងរកការងារ។ បញ្ហាទាំងអស់ខាងលើនេះ អាចត្រូវបានបំបែកទៅជាពីរប្រភេទៈ ក- ប្រភេទដែលកើតចេញពីភាពក្រីក្រ ខ- ប្រភេទដែលកើតចេញពីហិង្សាខាងផ្លូវភេទ។ កង្វះខាតការទទួលបានសេវាសុខភាព ការអប់រំ និងការងារល្អមានទំនាក់ទំនងនឹងភាពក្រីក្រ។ លក្ខខណ្ឌនៃភាពក្រីក្រមានសភាពធ្ងន់ធ្ងរ ដោយសារតែការរើសអើងផ្លូវភេទ ពីព្រោះស្ត្រីកាន់តែច្រើនឡើងរងគ្រោះពីភាពក្រីក្រច្រើនជាងបុរស។ ទម្រង់ជាក់លាក់នៃអំពើហិង្សាផ្លូវភេទ រួមមាន អំពើហិង្សាក្នុងគ្រួសារ និងការគាបសង្កត់គ្រប់រូបភាព ឬការប្រើកម្លាំងដោយបុរស។

---

១០៩ តារាងនៃគណៈកម្មការសុរិយោដីដែលមាននៅខាងក្រោម។

តារាង៖ ការស្ទង់មតិរបស់ IRL: បញ្ហាចម្បងៗដែលស្ត្រីជួបប្រទះ

**បញ្ហាជាចម្បងប្រឈមដោយស្ត្រី**

| | |
|---|---|
| - ភាពក្រីក្រ : | ៨៥% |
| - វិវាទ ឬអំពើហិង្សាក្នុងគ្រួសារ : | ៥៣% |
| - ជម្ងឺ-សុខភាពរបស់អ្នកនិងគ្រួសារអ្នក : | ៤៦% |
| - ការលែងលះ : | ២៣% |

- បញ្ហាផ្សេងៗទៀត
- ចំណេះដឹងរបស់ស្ត្រីទាប/មានកម្រិតទាប
- ស្ត្រីតែងទទួលសម្ពាធពីអ្នកមានឋានៈខ្ពស់/អ្នកមានអំណាច
- ស្ត្រីជួបការលំបាកក្នុងការស្វែងរកការងារ

ការស្ទង់មតិរបស់ IRLទំព័រ ៩៧

សិទ្ធិសង្គម៖

ស្ត្រីនាំគ្នាយល់ឃើញថា កង្វះខាតលើការទទួលបាន ការថែទាំផ្នែកវេជ្ជសាស្ត្រ ការអប់រំ ការងារ និងជីវភាពរស់នៅល្អ សមរម្យថាជាបញ្ហាសង្គម ប៉ុន្តែពួកគេមិនបានដឹងថាការទទួលបាននូវសេវាទាំងនោះ គឺជា សិទ្ធិដែលបានផ្តល់ឱ្យដោយរដ្ឋធម្មនុញ្ញ ដល់ស្ត្រីដែលត្រូវការនៅឯតំបន់ជនបទនោះឡើយ (មាត្រា ៤៦): "..... រដ្ឋ និង សង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេស-នារីជនបទ ដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជម្ងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ"។ ក៏មានផងដែរនូវបទបញ្ញត្តិជាក់លាក់ដែលពាក់ព័ន្ធនឹងការឧបត្ថម្ភដល់កុមារ (មាត្រា ៧៣): "រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារី ដែលមានកូនច្រើនក្នុងបន្ទុកហើយឥតទីពឹង"។ ការអនុវត្តសិទ្ធិសង្គមទាំងនេះ គឺជាអ្វីមួយដែលត្រូវធ្វើឱ្យបាន ព្រោះមិនទាន់ត្រូវបានគេអនុវត្តនៅឡើយ។

អំពើហិង្សាខាងយេនឌ័រ

ស្ត្រីប្រឈមមុខនឹងបញ្ហាមួយចំនួន ដោយសារអំពើហិង្សាផ្នែកយេនឌ័រ ដែលរួមមានអំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈនិងការបំពានផ្លូវភេទ ព្រមទាំងការជួញដូរមនុស្ស។ រឿងក្តីដែលកើតមានញឹកញាប់មាន អំពើហិង្សាក្នុងគ្រួសារ និងការបំពានផ្លូវភេទ។ ជារឿយៗ អំពើហិង្សាក្នុងគ្រួសារឈានទៅរកការលែងលះ។

តារាង៖ ទស្សនៈរបស់អ្នកចូលរួមសិក្ខាសាលា ស្ដីអំពីហិង្សាប្រឆាំងស្ត្រី

| | ប្រភេទនៃវិភាគ | មាតិកា |
|---|---|---|
| **អំពើហិង្សាប្រឆាំងនឹងស្ត្រី** | **អំពើហិង្សាក្នុងគ្រួសារ** | រឿងក្ដីអំពើហិង្សាក្នុងគ្រួសារ ត្រូវបានគេយល់ថាកើតមានញឹកញាប់ ។ ស្ត្រី និងកុមារគឺជាអ្នករងគ្រោះញឹកញាប់ ។<br>ទោះបីជនរងគ្រោះមិនបានរាយការណ៍ប្រាប់នូវគ្រប់រឿង អំពើហិង្សាក្នុងគ្រួសារ វាគឺជារឿងមួយដែលកើតឡើងញឹកញាប់ជាងគេ នៅចំពោះមុខនគរបាល អាជ្ញាធរមូលដ្ឋាន និងអ្នកផ្សះផ្សាក្នុងសហគមន៍ ។ |
| | **ការលែងលះ** | អំពើហិង្សាក្នុងគ្រួសារ និងការមិនបានបំពេញតួនាទីជាឪពុក ជាមូលហេតុទៅរកការផ្ដាច់សង្វាសនិងការលែងលះគ្នា ។ ស្ត្រីច្រើនជាដើមចោទក្នុងរឿងផ្ដាច់សង្វាស និងរឿងលែងលះនៅចំពោះមុខអាជ្ញាធរមូលដ្ឋាន ក៏ដូចជានៅចំពោះមុខតុលាការដែរ ។<br>រឿងលែងលះគឺជារឿងក្ដីរដ្ឋប្បវេណីដែលកើតឡើងញឹកញាប់ជាងគេ ដែលគេបានប្ដឹងទៅតុលាការ ។ |
| | **ការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ** | ញាតិសណ្ដាន និងអ្នកជិតខាងច្រើនប្រព្រឹត្តបទល្មើសទាំងនេះ ក្នុងន័យនេះ ការរំលោភសេពសន្ថវៈគឺជាទម្រង់មួយទៀត នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី នៅក្នុងទំនាក់ទំនងគ្រួសារ ។ |
| | **ការជួញដូរមនុស្ស** | រឿងក្ដីមួយចំនួនត្រូវបានគេរាយការណ៍ ។ វាហាក់ដូចជាឃើញថា រឿងនេះមានការពាក់ព័ន្ធជាមួយនឹងពេស្យាចារដោយបង្ខំ ។ |

ក. អំពើហិង្សាក្នុងគ្រួសារ

អំពើហិង្សាក្នុងគ្រួសារ រួមមានការរំលោភបំពានលើរូបរាងកាយ ពាក្យសម្ដី ឬផ្លូវចិត្ត ប្រឆាំងនឹងស្ត្រី កុមារ ឬបុគ្គលណាមួយតាមគ្រប់រូបភាព នៅក្នុងបរិស្ថានសង្គមគ្រួសារ ។ វាគឺជាបញ្ហាមួយដែលកើតមានឡើងនៅគ្រប់ទីកន្លែង ដូចដែលបានរៀបរាប់នៅក្នុងបទសម្ភាសន៍ និងសិក្ខាសាលាពិគ្រោះយោបល់ដែលយើងបានធ្វើសម្រាប់ការសិក្សាស្រាវជ្រាវនេះ ក៏ដូចជាក្នុងការសិក្សាផ្សេងៗទៀត និងរបាយការណ៍សិទ្ធិមនុស្សនានា[១១០] ។ អំពើហិង្សាក្នុងគ្រួសារមានទាក់ទងនឹងសុរា ល្បែង ជម្លោះក្នុងគ្រួសារ ការប្រច័ណ្ឌ និងអាកប្បកិរិយាត្រួតត្រាផ្សេងៗទៀតរបស់បុរស ក៏ដូចជាដោយសារកត្តាសង្គម និងវប្បធម៌ផ្សេងៗទៀតផងដែរ[១១១] ។

---

១១០ សូមមើល៖ *"ចំណែកស្មើភាព សម្រាប់នារី ។ ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា"* កិច្ចសហការរវាង UNIFEM, World Bank, ADB, UNDP and DFID/UK និងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន, ភ្នំពេញ៖ UNIFEM et al., (ចាប់ពីពេលនេះទៅត្រូវសរសេរ ៖ UNIFEM et al., 2004) ។ សមាគម ADHOC: របាយការណ៍សិទ្ធិមនុស្សឆ្នាំ ២០០៤, ជំពូក ៤៖ សិទ្ធិស្ត្រី និងកុមារ, ទំព័រ ៖ ២១-២៦ (ចាប់ពីពេលនេះទៅត្រូវសរសេរ ៖ ADHOC: Report 2004) ។ របាយការណ៍របស់អង្គការ LICADHO: *"A brief on the situation of women in Cambodia"* ឆ្នាំ២០០៤ និងប្រភពមួយផ្សេងទៀតគឺ ៖ Kirjavainen 1999 ។

១១១ UNIFEM et al. ២០០៤ , ទំព័រ ១១៤ បានលើកឡើងនូវទស្សនៈដូច Kirjavainen ១៩៩៩ , ទំព័រ ៨ ដែរ ។ តែតាមរបាយការណ៍របស់អង្គការ LICADHO ២០០៤ , ទំព័រ ៨ "ស្ថិតិដែលគួរឱ្យភ្ញាក់ផ្អើលនោះគឺ ៦៥.៧% នៃស្ត្រីរងរបួសស្នាមដោយអំពើហិង្សាក្នុងគ្រួសារ បានលើកឡើងថា ស្រាជាមូលហេតុចម្បង ។

*ប្ដីចូលចិត្តលេងល្បែង និងផឹកស្រា។ គាត់បានប្រព្រឹត្តអំពើហិង្សានៅក្នុងគ្រួសារជាញឹកញាប់។ អាជ្ញាធរឃុំបានហៅគាត់មកព្រមាន និងអប់រំម្ដងរួចហើយ ឱ្យបញ្ឈប់អំពើហិង្សា។ គាត់ថែមទាំងបានធ្វើកិច្ចសន្យានៅមុខអាជ្ញាធរថា នឹងឈប់ប្រព្រឹត្តអំពើហិង្សាទៀតហើយ។ តែគាត់នៅតែមិនបញ្ឈប់អំពើហិង្សា។ ក្រោយការសម្រុះសម្រួលគ្នា គ្មានការព្រមព្រៀងលែងលះបានធ្វើឡើងទេ។ ប្រពន្ធបានទាមទារលែងលះ ប៉ុន្តែប្ដីបានប្រកែក។ ក្រុមប្រឹក្សាមិនអាចធ្វើសេចក្ដីសម្រេចបានទេ ទោះបីជាមានសំណូមពរយ៉ាងទទូចយ៉ាងណាពីខាងភរិយាក្ដី។*

*កំណត់ហេតុសម្រុះសម្រួលបានធ្វើនៅថ្ងៃទី ១៨ មិថុនា ឆ្នាំ២០០៣ [១១២]។*

ការសិក្សាស្រាវជ្រាវខ្លះបានឱ្យដឹងថា អំពើហិង្សាក្នុងគ្រួសារកំពុងមានការកើនឡើង[១១៣]។ របាយការណ៍ មួយបានឱ្យដឹងថា "អំពើហិង្សាក្នុងគ្រួសារបានក្លាយទៅជារឿងមួយកាន់តែធ្ងន់ធ្ងរ និងកាន់តែសាហាវឡើងនៅក្នុងប្រទេសកម្ពុជា ពីមួយឆ្នាំទៅមួយឆ្នាំ ជួនកាលរួមមានទាំងការធ្វើទារុណកម្ម ដូចជា ការប្រើទឹកអាស៊ីត ការវាយដំធ្ងន់ធ្ងរ ដែលឈានទៅដល់ការរលូតកូន និងស្លាប់ទាំងម្ដាយទាំងកូន ព្រមទាំងរឿងក្ដីប្ដីប្រពន្ធមួយចំនួនទៀត ដែលប្ដីចងព្យួរជើងប្រពន្ធរបស់ខ្លួនដាក់ក្បាលចុះក្រោម និងបានធ្វើទារុណកម្មជាច្រើនបែបលើរូបស្ត្រីជាប្រពន្ធ" [១១៤]។

អំពើហិង្សាក្នុងគ្រួសារ និងការបរាជ័យនៃការប្រៀនប្រដៅរបស់ឪពុកម្ដាយ ហាក់ដូចបីដូចជាកំអែលនៃសង្គ្រាម និងអំពើហិង្សាដែលមានពីមុន។ ឪពុកម្ដាយបច្ចុប្បន្នមិនបានទទួលការថែទាំល្អត្រឹមត្រូវពីឪពុកម្ដាយរបស់ខ្លួនទេ កាលពីពួកគាត់នៅក្មេង[១១៥]។ អំពើហិង្សាក៏ជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃ ហើយវាមិនត្រូវបានគេបដិសេធនោះឡើយ។ ការស្រាវជ្រាវដែលធ្វើឡើង ក្នុងឆ្នាំ ១៩៩៦ បានប៉ាន់ស្មានថាស្ត្រីដែលចេញពីក្នុងកំឡុងសម័យខ្មែរក្រហម (អ្នកដែលមានអាយុចន្លោះពី ៣៦ ទៅ ៥០ឆ្នាំ) ត្រូវបានគេរាយការណ៍ថាមានអត្រារំលោភបំពានក្នុងគ្រួសារខ្ពស់គួរឱ្យចាប់អារម្មណ៍ជាងគេ។ ការសិក្សានេះបានបង្ហាញថា "មានទំនាក់ទំនងយ៉ាងខ្លាំង រវាងវិវាទហិង្សាក្នុងសង្គម និងអំពើហិង្សានៅក្នុងផ្ទះ"[១១៦]។

អំពើហិង្សាក្នុងគ្រួសារ ត្រូវបានគេរាយការណ៍ថាជាបាតុភូតដ៏ធំមួយក្នុងចំណោមស្ត្រីនៅតាមតំបន់ជនបទ និងទីប្រជុំជន ហើយមានស្ថានភាពសង្គម-សេដ្ឋកិច្ចខុសៗគ្នា។ ម្យ៉ាងទៀត ស្ថានភាពនឹងកាន់តែធ្ងន់ធ្ងរថែមទៀត នៅពេលដែលស្ត្រីនៅឆ្ងាយពីសាច់ញាតិ និងពេលពួកគេមានកម្រិតអប់រំទាប[១១៧]។ កត្តាធ្ងន់ធ្ងរមួយទៀត គឺភាពទ្រាំទ្រដែលមានក្នុងសង្គមដោយស្ត្រីខ្លួនឯង

---

១១២ សូមមើល រឿងក្ដីលេខ E2 នៅក្នុងឧបសម្ព័ន្ធ ២។

១១៣ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB): Participatory Poverty Assessment: Cambodia. Manila: ADB, ២០០១ ដែលបានដកស្រង់ដោយ UNIFEM et al. ២០០៤ ទំព័រ ១១៤។

១១៤ ADHOC ២០០៤ ទំព័រ ២៥។

១១៥ "អំពើហិង្សាអាចទទួលរងនូវឥទ្ធិពលនៃលក្ខខណ្ឌសង្គម ដែលឪពុកម្ដាយធ្លាប់រង និងប្រឈមក្នុងទសវត្សរ៍ឆ្នាំ១៩៧០ នៅពេលដែលប្រជាពលរដ្ឋនៅពេលនោះរស់នៅក្នុងស្ថានភាពមួយដោយភាពអត់ឃ្លាន និងភ័យខ្លាច ព្រមទាំងបែកខ្ញែកគ្រួសារ បងប្អូនកូនចៅ។ មានកត្តាជាច្រើនទៀត ដែលជះឥទ្ធិពលលើការ ការពារកូនចៅនៅក្នុងបន្ទុកក្នុងសង្គមកម្ពុជា ដោយឪពុកម្ដាយទាំងនោះ បានបាត់បង់នូវការថែរក្សាការពារប្រកបដោយគុណភាព និងបាត់បង់ផលិតផល និងខ្វះខាតនូវការថែទាំ និងការគាំទ្រសុខភាព (ដកស្រង់ចេញពីឯកសារ UNICEF ឆ្នាំ ១៩៩៥)" ដែលបានដកស្រង់ដោយ Kirjavainen ឆ្នាំ ១៩៩៨, ត្រង់ទំព័រ ៨។

១១៦ LICADHO ២០០៤ ទំព័រ ៨។

១១៧ "មានភាពខុសគ្នាបន្តិចរវាងស្ត្រីដែលរស់នៅជនបទដាច់ស្រយាលនឹងស្ត្រីរស់នៅទីប្រជុំជន ឬដោយលក្ខខណ្ឌការងារ ទោះបីជាស្ថានភាពនេះ មានលក្ខណៈប្រសើរជាងសម្រាប់ស្ត្រី ដែលបានរៀនបញ្ចប់ថ្នាក់មធ្យមសិក្សា និងស្ត្រីដែលមានសាច់ញាតិនៅជិតខ្លួនក៏ដោយ"។ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនបានរៀបចំនូវសេចក្ដីព្រាង ផែនការសកម្មភាពថ្នាក់ជាតិ សម្រាប់អនុវត្តច្បាប់ ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ។ ដកស្រង់ចេញពី UNIFEM et al. ឆ្នាំ ២០០៤, ត្រង់ទំព័រ ១១៤។

ចំពោះការប្រើអំពើហិង្សាដោយបុរសប្រឆាំងនឹងស្ត្រី និងកុមារ។ កត្តារួមចំណែកមួយទៀត គឺការពឹងពាក់លើផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីទៅលើបុរស។ ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ជារឿយៗតែងមានការពិបាកក្នុងការសម្រេចចិត្តផ្តាច់ទំនាក់ទំនងបែបនេះ។

***អង្គហេតុមួយចំនួន អំពីអំពើហិង្សាក្នុងគ្រួសារ***

- មួយភាគបួន (២៣%) នៃស្ត្រីដែលបានរៀបការហើយ និងអ្នកដែលមានអាយុពី ១៥-៤៩ ធ្លាប់រងបទពិសោធន៍នូវអំពើហិង្សាលើរូបរាងកាយ នៅពេលណាមួយមុនពេលអាយុបាន១៥ឆ្នាំ។
- មួយភាគប្រាំពីរនៃស្ត្រី (១៥%) ធ្លាប់ទទួលរងអំពើហិង្សានៅក្នុងឆ្នាំដែលបានចុះស្ទង់មតិ។
- មួយភាគបីនៃស្ត្រី (៣៥%) ទទួលថាយ៉ាងហោចមានមូលហេតុមួយ ដែលនាំឱ្យប្តី វាយប្រពន្ធ។
- ទាំងបុរសនិងទាំងស្ត្រីត្រឹមតែនិយាយថា ការវាយប្រពន្ធជារឿងដែលមិនអាចទទួលយកបានទេ ប្រសិនបើនាងមានរបួសធ្ងន់ធ្ងរ (មានន័យថាវាអាចជារឿងដែលទទួលយកបាន ប្រសិនបើរបួសមិនមានសភាពធ្ងន់ធ្ងរនោះ)។
- ពីរភាគប្រាំនៃស្ត្រី (២/៥) នឹងមិនមានអ្នកដែលអាចជួយផ្គត់ផ្គង់ខាងហិរញ្ញវត្ថុដល់ពួកគាត់ទេ ប្រសិនបើពួកគេចង់ចេញពីទំនាក់ទំនងដែលមានការរំលោភបំពាននេះ។
- មានតិចជាងមួយភាគបីនៃស្ត្រី (២៨%) ប៉ុណ្ណោះ ដែលមានទ្រព្យសម្បត្តិដែលគេអាចលក់ដូរដោយមិនចាំបាច់មានការយល់ព្រមពីប្តី។

UNIFEM, World Bank, ADB, UNDP និង DFID/UK ដោយមានកិច្ចសហការជាមួយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន *A Fair Share for Women. Cambodia Gender Assessment.* ភ្នំពេញ UNIFEM et al., ឆ្នាំ ២០០៤ ទំព័រ ១១៤។

អំពើហិង្សាក្នុងគ្រួសារ គឺជាប្រភេទនៃការរំលោភបំពានមានលក្ខណៈជាប្រព័ន្ធ ដែលមានរយៈពេលយូរទៅនឹងការកាត់បន្ថយសមត្ថភាពរបស់ជនរងគ្រោះ ក្នុងការសុំឱ្យគេជួយដើម្បីបំបែកវដ្តដ៏ធ្ងន់ធ្ងរនៃអំពើហិង្សា។

ការស្ទង់មតិរបស់ IRL បានបង្ហាញថា ក្នុង២៥%នៃរឿងក្តី ស្ត្រីដែលមានវិវាទជាមួយបុរសសុខចិត្តនៅស្ងៀមស្ងាត់ និងបោះបង់ចោលស្ថានភាពរបស់ខ្លួន នៅពេលដែលមានជាងពាក់កណ្តាលទៀត (៥១%) មានបំណងចង់ចរចាដោយសង្ឃឹមថាស្ថានភាពនឹងបានធូរស្រាល។ មានត្រឹមតែមួយភាគប្រាំនៃរឿងក្តីប៉ុណ្ណោះ ដែលចង់ការពារសិទ្ធិរបស់ពួកគេ (២០%) ហើយត្រឹមតែ ៣% ដែលចង់រកអាជ្ញាធរមេភូមិឬមេឃុំ (២%) ឬរកនគរបាល (១%)។ បញ្ហានេះមានលក្ខណៈទូទៅ ដោយយោងទៅលើវិវាទគ្រប់ប្រភេទ ដោយរាប់ទាំងអំពើហិង្សាក្នុងគ្រួសារដែរ។ ទោះជាយ៉ាងណាក្តី វាបានបង្ហាញពីឥរិយាបទទូទៅរបស់ស្ត្រីទាក់ទងនឹងរឿងក្តី ជាមួយបុរស។ អំពើហិង្សាក្នុងគ្រួសារ គឺជារឿងមួយក្នុងចំណោមរឿងបែបនេះ។ ដោយយោងទៅលើចម្លើយលើអំពើហិង្សាក្នុងគ្រួសារ យើងអាចសន្និដ្ឋានបានថា រឿងក្តីភាគច្រើននៃអំពើហិង្សាក្នុងគ្រួសារ (៩៧%) នៅតែមិនត្រូវបានគេដឹងឡើយ។ រឿងនេះត្រូវបានបញ្ជាក់ដោយមានភស្តុតាងជាច្រើន។ ដោយមានរឿងក្តី ជាច្រើនដែលមិនត្រូវបានគេរាយការណ៍នោះនៅមានរឿង "the black cipher of criminality – គម្លាត ឬភាពខុសគ្នារវាងបទល្មើសជាក់ស្តែង និងរបាយការណ៍ផ្លូវការ" [១១៨]។

[១១៨] នៅក្នុងឧក្រិដ្ឋកម្មវិទ្យា ពាក្យថា "black cipher of criminality" ឬ "dark number" គឺសំដៅលើភាពខុសគ្នា ឬគម្លាតរវាងបទល្មើសកើតមានជាក់ស្តែងធៀបទៅនិងរបាយការណ៍ផ្លូវការរបស់វា។ សូមមើល : Gomes, Luiz Flávio: "A Impunidade No Brasil: De quem é a culpa? (Esboço de um Decálogo dos filtros da impunidade)", in: R. CEJ, Brasilia, n. 15, Sept.- Dec. 2001. p. 35-50.

តារាង៖ ការស្ទង់មតិរបស់ IRL តើស្ត្រីធ្វើអ្វីនៅពេលមានវិវាទជាមួយបុរស?

| តើស្ត្រីធ្វើអ្វី ពេលមានវិវាទជាមួយបុរស | |
|---|---|
| ចរចារដើម្បីបានលទ្ធផលល្អប្រសើរ | ៣៥% |
| ការពារសិទ្ធិរបស់ពួកគេ | ៣១% |
| នៅស្ងៀមស្ងាត់ និងមិននិយាយអ្វីទាំងអស់ | ២២% |
| បដិសេធ | ៥% |
| លះបង់ និងសុខចិត្តចុះចាញ់តាមស្ថានភាពនោះ | ៤% |
| ប្តឹងទៅមេឃុំ/មេភូមិ | ២% |
| ប្តឹងទៅនគរបាល | ១% |

| តើអ្នកធ្វើអ្វី ពេលមានវិវាទជាមួយបុរសម្នាក់ | |
|---|---|
| ចរចារដើម្បីបានលទ្ធផលល្អប្រសើរ | ៥១% |
| ការពារសិទ្ធិរបស់ពួកគេ | ២១% |
| នៅស្ងៀមស្ងាត់ និងមិននិយាយអ្វីទាំងអស់ | ១៨% |
| លះបង់ និងសុខចិត្តចុះចាញ់តាមស្ថានភាពនោះ | ៣% |
| បដិសេធ | ៣% |
| ប្តឹងទៅមេឃុំ/មេភូមិ | ២% |
| ប្តឹងទៅនគរបាល | ១% |

***ការស្ទង់មតិរបស់*** IRL **ទិន្នន័យ និងការប៉ាន់ស្មានស្ត្រី** ទំព័រ ១០១

រដ្ឋធម្មនុញ្ញបានផ្តល់នូវសិទ្ធិស្មើភាពគ្នារវាងស្ត្រី និងបុរស ហើយមនុស្សគ្រប់រូបត្រូវបានផ្តល់ឱ្យនូវបូរណភាពរូបកាយ និងផ្លូវចិត្តរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី បុរសខ្លះតាមការយល់ឃើញរបស់ខ្លួនថា ពួកគាត់មាន "សិទ្ធិ" ក្នុងការប្រៀនប្រដៅប្រពន្ធ និងកូនរបស់ខ្លួនដោយប្រើអំពើហិង្សា។ ដូចគ្នានេះផងដែរ អំពើហិង្សាក្នុងគ្រួសារនៅតែត្រូវបានមនុស្សជាច្រើន រួមទាំងអាជ្ញាធរមូលដ្ឋាននិងនគរបាលផងដែរចាត់ទុកថាជា "រឿងឯកជន" គឺមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ លើកលែងតែរបួសស្នាមមានសភាពធ្ងន់ធ្ងរ។ ក្នុងរឿងក្តីមួយចំនួននៃអំពើហិង្សា ក្នុងគ្រួសារ សាច់ញាតិ អាជ្ញាធរមូលដ្ឋាន អ្នកផ្សះផ្សា ប្រើសម្ពាធថែមទៀតទៅលើស្ត្រី ក្នុងការឱ្យរួមរស់ ឬ បន្តរស់នៅក្នុងទំនាក់ទំនងដែលមានការរំលោភបំពាននេះតទៅទៀត។ ប្រសិនបើអំពើហិង្សាក្នុងគ្រួសារត្រូវបានគេយល់ថាជា "រឿងក្នុងគ្រួសារ" បែបនេះអ្នកដទៃមិនអាចលូកដៃចូលបានទេ។ ស្ថានភាពបែបនេះអាចកាត់បន្ថយសមត្ថភាពរបស់ស្ត្រី ចំពោះតម្រូវការយុត្តិធម៌ ឬក៏មិនហ៊ានសុំជំនួយផងដែរ។

រឿងក្តីខាងក្រោមនេះត្រូវបានធ្វើការអង្កេតដោយក្រុមស្រាវជ្រាវ និងជាឧទាហរណ៍នៃគំនិតដែលថាអំពើហិង្សាក្នុងគ្រួសារ គឺគ្រាន់តែជារឿងឯកជនប៉ុណ្ណោះ។ គំនិតនេះនៅតែមានឥទ្ធិពលនៅឡើយនៅតាមសហគមន៍។

ដំណោះស្រាយវិវាទដោយគណៈកម្មាធិការដោះស្រាយវិវាទ ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ ថ្ងៃទី ១៧ មិនា ២០០៥ [១១៩]

**អង្គហេតុដែលបានលើកឡើងដោយគូភាគី**

គូភាគីរស់នៅក្នុងភូមិតាម៉ែន ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ ។ រឿងក្តីនេះ ត្រូវបានដាក់ពាក្យប្តឹងទៅមុខមេភូមិដោយ លោក HH ដែលជាអ្នកចោទប្រកាន់លើលោក BB ដែលជាប្អូនថ្លៃថាបានដាល់ខ្លួន ។

តាមសក្តីកម្មនានា HH ចូលចិត្តផឹកស៊ី ហើយពេលគាត់ស្រវឹង គាត់ប្រព្រឹត្តអំពើហិង្សាទៅលើប្រពន្ធគាត់ (លោកស្រី WW) និងកូនស្រីគាត់ ។ វាបានកើតឡើងនៅថ្ងៃទី ១៦ មិនា ឆ្នាំ២០០៥ ។ នៅពេល HH បានធ្វើបាបលើប្រពន្ធខ្លួន BB (ប្អូនប្រុសរបស់ WW) បានមកដល់ ហើយក៏ចង់បញ្ឈប់គាត់ ។ HH មិនព្រមឈប់ និងថែមទាំងព្យាយាមចង់វាយទៅលើ BB ។ ឃើញដូច្នេះ BB ក៏ដាល់ HH ចំភ្នែកស្តាំ ។ នៅពេលរសៀលថ្ងៃដដែល HH បានទៅរកលោកមេឃុំ និងបានដាក់ពាក្យប្តឹង BB ថាបានវាយតប់គាត់ ។ ក្រោយពីលោកមេឃុំបានទទួលពាក្យបណ្តឹងរួចមក គាត់ក៏សរសេររបាយការណ៍ទៅប្រធានគណៈកម្មាធិការឃុំដោះស្រាយវិវាទ ដើម្បីធ្វើការដោះស្រាយវិវាទនេះ ។ នៅថ្ងៃទី១៧ មិនា ឆ្នាំ២០០៥ HH (ប្តី) BB (ប្អូនប្រុស) WW (ប្រពន្ធ) និងកូនស្រីបានមកបង្ហាញខ្លួននៅផ្ទះរបស់ប្រធានគណៈកម្មការ ដើម្បីដោះស្រាយវិវាទ ។ សមាជិកទាំងអស់នៃគណៈកម្មាធិការក៏មានវត្តមានផងដែរ ។

**ដំណើរការសម្រុះសម្រួល**

នៅពេលចាប់ផ្តើមការសម្រុះសម្រួល សមាជិកគណៈកម្មការម្នាក់ដែលបានតែងតាំងធ្វើជាលេខា បានឡើងអានរបាយការណ៍របស់មេឃុំ និងឱ្យគូភាគីដឹងថាពួកគេត្រូវបង់ប្រាក់ ១០០ បាត (ប្រហែល ១ម៉ឺនរៀល) ក្នុងម្នាក់ដល់សេវារបស់គណៈកម្មការ ក្នុងការជួយដោះស្រាយរឿងក្តី ។

ប្រធានបានសួរទៅ HH ថាគាត់ចង់បានអ្វីពីការប្តឹង ។ គាត់បានតបថា គាត់ស្នើសុំ ១៥.០០០ បាត (ប្រហែល ១.៥០០.០០០ រៀល) សម្រាប់ការខូចខាតពី BB ។ ប្រធានបានសួរ HH ថាតើគាត់ អាចចុះខ្លះបានទេ ព្រោះចំនួនដែលទារនេះច្រើនពេកហើយ BB ក៏ជាប្អូនប្រុសរបស់ប្រពន្ធគាត់ដែរ ។ HH បាននិយាយថា គាត់ចង់បានលុយ **ដើម្បីសងលើរបួស និងសេចក្តីថ្លៃថ្នូរ** ហើយប្រសិនបើគាត់មិនបានចំនួនលុយប៉ុណ្ណឹងទេ គាត់នឹងទៅប្តឹងអាជ្ញាធរមានសមត្ថកិច្ច (នគរបាល-តុលាការ) ។ គាត់បាននិយាយថា ទោះបីគាត់បានវាយដំប្រពន្ធ និងកូនគាត់ វាគឺជា **រឿងក្នុងគ្រួសារគាត់** ។ អ្នកខាងក្រៅមិនគួរនឹងលូកដៃនោះទេ ។

ប្រធានបានសួរ BB អំពីការទាមទាររបស់ HH ។ BB បាននិយាយថាគាត់គ្រាន់តែចង់ការពារខ្លួនប៉ុណ្ណោះ ហើយគាត់លូកដៃចូលរឿងគ្រួសាររបស់ HH ពីព្រោះ HH បានវាយធ្វើបាបបងស្រីគាត់ និងក្មួយស្រី ញឹកញាប់ណាស់ពេលគាត់ស្រវឹង ។ គាត់បាននិយាយថា គាត់គ្មានប្រាក់នឹងបង់លុយច្រើនបែបនេះដូចដែល HH បានទាមទារទេ ហើយគាត់សុំទោស HH ចំពោះ "កំហុសរបស់គាត់" ។

---

[១១៩] ក្រុមសិក្សាស្រាវជ្រាវ រួមដំណើរដោយសមាជិកម្នាក់មកពីក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានសង្កេតមើល ដំណើរការដោះស្រាយរឿងក្តី ។ នេះជារឿងពិត តែឈ្មោះមិនត្រូវបានបញ្ចេញ ដើម្បីរក្សានូវភាពឯកជនដល់ពួកគេ ។

ប្រធានបាននិយាយទៅកាន់ BB ថា : "ឥឡូវអ្នកត្រូវរកផ្លូវសម្របសម្រួល ពីព្រោះអ្នកឯងបានវាយ HH ។ អ្នកមិនអាចគ្រាន់តែនិយាយថា អ្នកឯងគ្មានលុយនោះទេ ពីព្រោះប្រសិនបើរឿងនេះទៅដល់ទគរបាល និងតុលាការ អ្នកឯងអាចជាប់គុក"។ BB បានទទួចថា គាត់គ្មានប្រាក់ច្រើនបែបនេះទេ ហើយគាត់មិនយល់ទាស់នឹងការជាប់គុកទេ។ គាត់និយាយថា គាត់អាចបង់ឱ្យត្រឹម ៥០០បាត ។

សមាជិកគណៈកម្មការម្នាក់ទៀតបាននិយាយទៅកាន់ BB ថា " ប្រសិនបើអ្នកឯងចង់ជាប់គុក ស្រេចលើអ្នកឯង ប៉ុន្តែអ្នកឯងមិនអាចចៀសផុតពីការបង់សងលុយខ្លះទៅឱ្យ HH នោះទេ ពីព្រោះអ្នកឯងពិតជាបានវាយគាត់មែន"។

ប្រពន្ធរបស់ HH បាននិយាយកាត់ថា ប្រសិនបើ BB ជាប់គុក នាងសុខចិត្តជាប់គុកជំនួសប្អូនវិញ ពីព្រោះ BB បានធ្វើដូចនេះក៏ព្រោះតែចង់ជួយនាង និងកូនរបស់នាងប៉ុណ្ណោះ ។

សមាជិកគណៈកម្មការម្នាក់ទៀត បានព្យាយាមបញ្ចុះបញ្ចូលគូភាគី ដើម្បីឈានទៅរកការស្រុះស្រួលគ្នា ដើម្បីបញ្ចប់វិវាទ "ពីព្រោះអ្នកទាំងពីរជាបងប្អូនថ្លៃ"។ គាត់បាននិយាយទៅកាន់ HH ថា : " BB ពិតជាបានវាយអ្នកមែន តែអ្នកឯងក៏បានវាយប្រពន្ធ និងកូនអ្នកឯងដែរ។ អ្នកទាំងពីរខុសដូចគ្នា ដូច្នេះអ្នកឯងគួរតែស្រុះស្រួលគ្នាបញ្ចប់រឿងវិវាទនេះទៅ"។

HH បាននិយាយថា ប្រសិនបើ BB បានគិតថាគាត់ជាបងប្រុស BB មិនគួរដាល់គាត់ឱ្យមានរបួសធ្ងន់ធ្ងរបែបនេះទេ។ BB បានសុំទោសម្តងទៀតសម្រាប់កំហុសខ្លួន ហើយបានទទួចថា គាត់ពិតជាគ្មានប្រាក់កាសអ្វីបន្ថែមទៀតទេ។ បន្ទាប់មក HH ក៏បានបន្ថយការទាមទារមកត្រឹម ១០.០០០ បាត ហើយ BB បាននិយាយថាគាត់មិនមានលុយលើសពី ១.០០០ បាតទេ ។

គណៈកម្មការបានស្នើសុំឱ្យគូភាគីចរចាតទៅទៀត។ បន្ទាប់មក HH បានបញ្ចុះការទាមទារ មកត្រឹម ៥.០០០បាត ប៉ុន្តែ BB នៅទ្រឹងត្រឹម ១.០០០បាត។ ប្រាំនាទីក្រោយមក HH យល់ព្រមទទួលត្រឹម ១.០០០បាត ពី BB ប៉ុន្តែគាត់តម្រូវឱ្យ BB បង់ភ្លាមៗ។ BB និង WW យល់ស្របតាម។ បន្ទាប់ពីនោះ គណៈកម្មការបានរៀបចំកិច្ចសន្យាឱ្យគូភាគីចុះហត្ថលេខា។
ការសម្រុះសម្រួលបានធ្វើឡើងអស់រយៈពេល ៩០ នាទី ដើម្បីឈានដល់ការស្រុះស្រួលគ្នា។

សូម្បីតែនៅពេលអំពើហិង្សាក្នុងគ្រួសារមានលក្ខណៈជាប្រព័ន្ធក្តី ស្ត្រីមិនត្រូវបានលើកទឹកចិត្តឱ្យចាកចេញពីបរិស្ថានមិនល្អនេះទេ ព្រមទាំងត្រូវបានគេដាក់សម្ពាធឱ្យ "ធ្វើការសម្រុះសម្រួល" ថែមទៀត។

"ខ្ញុំមិនសុខចិត្តនឹងប្តីខ្ញុំទេ ពីព្រោះគាត់ធ្លាប់ប្រើអំពើហិង្សាមកលើខ្ញុំ។ គាត់បានវាយខ្ញុំពីរលើក។ លើកទីពីរនៅថ្ងៃអង្គារ ទី១៥ តុលា ២០០២។ គាត់បានវាយខ្ញុំនឹងដំបងឈើ។ ជាសំណាងល្អដែលខ្ញុំបានគេចផុត។ គាត់បានវាយចំភ្លៅ និងជើងខ្ញុំ រហូតខ្ញុំមិនអាចដើរបានទេ។ ខ្ញុំអាចដើរបានក្រោយពីពេទ្យបានចាក់ថ្នាំឱ្យ។ ខ្ញុំនៅមានស្លាកស្នាមពីរបួសទាំងនេះ"។

ដើមបណ្ដឹងបានសំណូមពរឱ្យមេឃុំអញ្ជើញប្ដីរបស់គាត់មក ដើម្បីបានទទួលការប្រឹក្សាអប់រំ។ នៅពេលសម្រុះសម្រួល គូភាគីបានព្រមរួមរស់នៅជាមួយគ្នាវិញ[១២០]។

នេះគឺជារឿងក្ដីមួយទៀតនៃអំពើហិង្សាក្នុងគ្រួសារ ដែលកើតឡើងពីរឿងប្ដីមានប្រព័ន្ធពីរ និងភាពខ្វះការទទួលខុសត្រូវរបស់មាតាបិតា។ សូម្បីក្នុងករណីបែបនេះក្ដី ក៏មានសម្ពាធគ្រួសារយ៉ាងខ្លាំងមកលើស្ត្រីដែរ។

ស្ត្រីម្នាក់បានដាក់ពាក្យប្ដឹងនៅមុខក្រុមប្រឹក្សាឃុំ ដោយសារតែប្ដីប្រើអំពើហិង្សាក្នុងគ្រួសារ លេងល្បែង និងមានប្រពន្ធចុងដែរ។ ប្រពន្ធចង់ប្ដឹងលែងលះ។ ម្ដាយមីងរបស់ប្ដីបានដាក់សម្ពាធលើប្រពន្ធមិនឱ្យលែងលះ។

*ប្រពន្ធ(និយាយថា): "ខ្ញុំចង់លែងលះ ខ្ញុំមិនអាចរស់នៅជាមួយគាត់បានតទៅទៀតទេ ពីព្រោះមានអំពើហិង្សាក្នុងគ្រួសារ"។ លោកស្រី OO ដែលជាម្ដាយមីងរបស់ប្ដី(និយាយថា) គាត់នឹងអប់រំ លោក PP (ប្ដីរបស់ដើមបណ្ដឹង) ឱ្យឈប់ប្រើអំពើហិង្សា និងឱ្យគាត់លែងលះជាមួយប្រពន្ធចុង។ (ប្រពន្ធនិយាយថា): "ខ្ញុំសុខចិត្តរស់នៅជាមួយគាត់ ប៉ុន្តែខ្ញុំមិនចង់ឱ្យមានអំពើហិង្សាម្ដងទៀតទេ"។ ភាគីប្ដី (និយាយ): "ខ្ញុំមិនចង់លែងលះទេ ហើយខ្ញុំចង់រស់នៅជាមួយប្រពន្ធឈ្មោះTT ចាប់ពី ថ្ងៃនេះតទៅ ហើយសន្យាថាខ្ញុំឈប់មានទំនាក់ទំនងជាមួយ នាងប្រពន្ធចុងទៀតហើយ ចាប់ពីថ្ងៃនេះទៅ។ បើខ្ញុំក្បត់ពាក្យសន្យា ខ្ញុំសុខចិត្តចុះចេញពីផ្ទះ ដោយមិនទាមទារអ្វីទាំងអស់"។ ម្ដាយមីងរបស់ប្ដីឈ្មោះ OO (បាននិយាយថា): "ខ្ញុំសំណូមពរឱ្យភាគីទាំងពីររួមរស់ជាមួយគ្នាវិញ។ ខ្ញុំសន្យាថា នឹងអប់រំវាឱ្យឈប់ទាក់ទងនឹងប្រពន្ធចុង និងឈប់ប្រើអំពើហិង្សាក្នុងគ្រួសារតទៅទៀត។ ខ្ញុំសុខចិត្តឱ្យ PP ទទួលស្គាល់កំហុសខ្លួន និងគោរពតាមពាក្យសន្យា"។ ក្រោយពីការសម្រុះសម្រួល គូភាគីបានព្រមព្រៀងរួមរស់ជាមួយគ្នាវិញ និងសន្យាកែប្រែ និងគោរពគ្នាទៅវិញទៅមក។*

កំណត់ហេតុសម្រុះសម្រួលធ្វើនៅថ្ងៃទី ៦ មេសា ២០០៤[១២១]។

ស្ត្រីទៅប្ដឹងនគរបាល តែក្នុងករណីរបួសស្នាមមានសភាពធ្ងន់ធ្ងរ។ រឿងក្ដីភាគច្រើននៃអំពើហិង្សាក្នុងគ្រួសារ ត្រូវបាន "សម្រុះសម្រួល"នៅចំពោះមុខនគរបាលឬអាជ្ញាធរមូលដ្ឋាន (មេភូមិ មេឃុំ អភិបាលស្រុក)។ ការសិក្សាមួយដោយផ្អែកលើរឿងក្ដីចំនួន ៤៦៣ បានបង្ហាញថា "៦០%នៃរឿងក្ដីអំពើហិង្សាក្នុងគ្រួសារចំនួន ៤៦៣ នេះ ត្រូវបានដោះស្រាយតាមរយៈការផ្សះផ្សានៅថ្នាក់ឃុំ និងស្រុក។ ការសម្រុះសម្រួលនេះក៏ត្រូវបានធ្វើឡើង នៅក្នុងរឿងក្ដីធ្ងន់ធ្ងរផងដែរ" [១២២]។

ស្ត្រីហាក់ដូចជាបានដឹងពីសិទ្ធិរបស់ពួកគេ ដោយសារតែយុទ្ធនាការផ្សេងៗបង្ហាញពីសិទ្ធិទាំងនេះ។ ស្ត្រីត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យបណ្ដឹង។ អំពើហិង្សាក្នុងគ្រួសារ គឺជារឿងក្ដីមួយក្នុងចំណោមរឿងក្ដីដែលបានទទួលញឹកញាប់ជាងគេ ដោយអង្គការក្រៅរដ្ឋាភិបាល[១២៣] អាជ្ញាធរមូលដ្ឋានអ្នកផ្សះផ្សា និងនគរបាល។ នៅមានកិច្ចការជាច្រើនទៀត ដែលត្រូវធ្វើពាក់ព័ន្ធនឹងការយល់ដឹងសិទ្ធិស្ត្រី ក្នុងចំណោមស្ត្រី និងសង្គមជាទូទៅដើម្បីបង្កាការប្រើអំពើហិង្សាប្រឆាំងនឹងស្ត្រី។

---

[១២០] សូមមើល រឿងក្ដីលេខ A10 នៅក្នុងឧបសម្ព័ន្ធ ២។

[១២១] សូមមើល រឿងក្ដីលេខ C1 នៅក្នុងឧបសម្ព័ន្ធ ២។

[១២២] របាយការណ៍ ADHOC ឆ្នាំ ២០០៤:ទំព័រ ២៥។

[១២៣] អំពើហិង្សាក្នុងគ្រួសារមានចំនួនភាគច្រើនជាងគេ ដែលបានទទួលដោយអង្គការក្រៅរដ្ឋាភិបាលជាច្រើន។ ADHOC បានរាយការណ៍ថា មានអំពើហិង្សាកើតមានចំនួន ៤៦៣ ករណីនៅក្នុងឆ្នាំ២០០៤។ នៅក្នុងឆ្នាំ២០០៤ មានចំនួន ៧១ % នៃរឿងក្ដីទទួលដោយមជ្ឈមណ្ឌលស្ត្រីមានវិបត្តិនៅកម្ពុជា ទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ (១៣០០ករណី លើ ១៨២៣ ករណីទាក់ទងនឹងសិទ្ធិស្ត្រី)។ ស្ថិតិនេះដកស្រង់ចេញពី *របាយការណ៍ពិភពលោក* (ឆ្នាំ ២០០៤) របស់មជ្ឈមណ្ឌលស្ត្រី មានវិបត្តិនៅកម្ពុជា ត្រង់ទំព័រ ៣។(ចាប់ពីពេល នេះទៅត្រូវសរសេរ: *CWCC 2004*)

នៅក្នុងការស្ទង់មតិរបស់ IRL អំពើហិង្សាក្នុងគ្រួសារជារឿងក្តីដែលកើតឡើងញឹកញាប់បំផុត ដែលបានទទួលពិនិត្យដោយអាជ្ញាធរឃុំ (៤៨%)។




ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារត្រូវបានអនុម័តដោយរដ្ឋសភា កាលពីថ្ងៃទី១៨ កញ្ញា ២០០៥[១២៤]។ តុលាការពិនិត្យរឿងអំពើហិង្សាក្នុងគ្រួសារថាជារឿងក្តីព្រហ្មទណ្ឌ (នៅពេលមានរបួសដល់រូបកាយ ដែលជាផលនៃអំពើហិង្សាក្នុងគ្រួសារ) ឬតុលាការចាត់ទុកអំពើហិង្សាក្នុងគ្រួសារថាជារឿងក្តីរដ្ឋប្បវេណី ទាក់ទងនឹងការសុំលែងលះ។ ក្របខ័ណ្ឌច្បាប់មិនគ្រប់គ្រាន់ ថែមទាំងការយល់ដឹងច្បាប់មានកម្រិត បានរាំងខ្ទប់តម្រូវការយុត្តិធម៌ ក្នុងរឿងក្តីពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ។ តាមការអនុវត្តមិនមានរឿងក្តីច្រើនទេដែលពាក់ព័ន្ធនឹងការវាយតប់ និងការបង្ករបួសស្នាម ដែលត្រូវបានដាក់ពាក្យប្តឹងដោយស្ត្រី ដែលជាផលនៃអំពើហិង្សាក្នុងគ្រួសារនោះ។ ប៉ុន្តែមានចំនួនរឿងក្តីជាច្រើន ទាក់ទងនឹងរឿងលែងលះ។ ជាក់ស្តែងសព្វថ្ងៃនេះ មិនមានយន្តការណាផ្សេងទៀតក្នុងការបង្ការអំពើហិង្សា និងការពារសិទ្ធិស្ត្រី និងកុមារក្នុងរឿងអំពើហិង្សាក្នុងគ្រួសារទេ។

សេចក្តីព្រាងច្បាប់ថ្មីស្តីពីអំពើហិង្សាក្នុងគ្រួសារបានកំណត់និយមន័យ អំពើហិង្សាតាមន័យទូលាយជាងច្បាប់ព្រហ្មទណ្ឌបច្ចុប្បន្ន។ ច្បាប់អ៊ុនតាក់ (១៩៩២) គ្រាន់តែបានបញ្ចូលករណីវាយតប់បង្ករបួសស្នាមថា ស្ត្រីអាចស្នើសុំការការពារតាមផ្លូវយុត្តិធម៌មិនបាន តែក្នុងករណីដែលអំពើហិង្សាក្នុងគ្រួសារ បានបង្កឱ្យមានរបួសស្នាមលើរូបរាងកាយធ្ងន់ធ្ងរប៉ុណ្ណោះ។ សេចក្តីព្រាងក្រមព្រហ្មទណ្ឌ បានចែងថាអនីតិសង្វាស ឬ កិរិយាអាចជាជនរងគ្រោះ នៃករណីរឿង "អំពើហិង្សាដោយចេតនា" ប៉ុន្តែគ្រាន់តែបានអនុញ្ញាតឱ្យមានការដាក់ទោសពីរប្រភេទ (ដាក់ពន្ធនាគារ និងការផាកពិន័យ) ហើយមិនបានផ្តល់នូវការការពារដល់ជនរងគ្រោះទេ។

[១២៤] សូមមើល ឧបសម្ព័ន្ធ ១: បទបញ្ញត្តិស្តីពីអំពើហិង្សាក្នុងគ្រួសារ។ ដោយសារច្បាប់ទើបបានអនុម័តនៅពេលរបាយការណ៍ នេះបានបញ្ចប់ នៅក្នុងផ្នែកជាច្រើននៃរបាយការណ៍បានដាក់ថា "សេចក្តីព្រាងច្បាប់" ស្តីពីអំពើហិង្សាក្នុងគ្រួសារ។

ច្បាប់ថ្មីស្តីពីអំពើហិង្សាក្នុងគ្រួសារ បានព្យាយាមពង្រឹងសិទ្ធិទទួលបានយុត្តិធម៌ដោយ ក-បានកំណត់ និយមន័យអំពើហិង្សាក្នុងគ្រួសារក្នុងន័យទូលាយជាងច្បាប់ព្រហ្មទណ្ឌដែលមានបច្ចុប្បន្ន (ដោយចែងថា អំពើហិង្សាមិនគ្រាន់តែរាប់បញ្ចូលតែអំពើហិង្សាលើរូបកាយប៉ុណ្ណោះទេ តែថែមទាំងបានបញ្ចូលអំពើហិង្សាដល់ផ្លូវចិត្ត ចិត្តសាស្ត្រ និងអារម្មណ៍ថែមទៀត) ខ-បានបង្កើតអន្តរាគមន៍ក្នុងការបង្ការទុកជាមុន គ-គិតដល់អន្តរាគមន៍ សង្គមចំពោះជនរងគ្រោះ (ផ្តល់កន្លែងស្នាក់នៅ និង ការពន្យល់ពីសិទ្ធិ) និងមិនគ្រាន់តែចែងពីការដាក់ទោសជនល្មើសនោះទេ ឃ-បានរួមបញ្ចូលការងារបម្រើសហគមន៍ ជាទម្រង់ថ្មីមួយនៃការដាក់ទោសដល់ជនល្មើស និង ង-អនុញ្ញាតឱ្យអាជ្ញាធរមូលដ្ឋាន រួមទាំងមន្ត្រីក្រសួងកិច្ចការនារី ចុះធ្វើអន្តរាគមន៍ "ក្នុងការបង្ក្រាប និងទប់ស្កាត់ អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ"ផង (មាត្រា១១)។

ច្បាប់ថ្មីមិនមានភាពច្បាស់លាស់ នៅពេលដែលបានចែងថា "តុលាការធ្វើការផ្តន្ទាទោសជនមុខសញ្ញា តាមបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាធរមាន ដោយតម្រូវឱ្យជននោះធ្វើការងារសហគមន៍ តាមទំហំនៃទោសដែលបានកំណត់ក្នុងច្បាប់។ ការប្រតិបត្តិទោសលើជនជាមុខសញ្ញា ឬជនជាប់ចោទត្រូវអនុវត្តតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។" (មាត្រា៤០)។ ការយោងរបៀបនេះទៅនឹងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌដែលមាននៅពេលបច្ចុប្បន្ន គឺជារឿងដែលមិនស្របគ្នាទេ លុះត្រាតែបទបញ្ញត្តិច្បាប់ទាំងពីរផ្លាស់ប្តូរឱ្យស្របទៅតាមបទល្មើស "អំពើហិង្សាក្នុងគ្រួសារ" ដោយកំណត់ឱ្យទូលាយលើសពីការបង្ករបួសស្នាម និងដើម្បីអនុវត្តនូវទណ្ឌកម្មធ្វើការងារ បម្រើសហគមន៍ដែលមិនមានឡើយនៅពេលបច្ចុប្បន្ននេះ។

ការពង្រីកអំណាចដែលត្រូវផ្តល់ទៅឱ្យអាជ្ញាធរ និងឱ្យទៅមន្ត្រីក្រសួងកិច្ចការនារី ក្នុងកិច្ចបង្ការជាមុន រួមទាំង "ការដកហូតអាវុធ និងសម្ភារៈផ្សេងៗ" អាចឆ្លងចូលដល់មុខងាររបស់តុលាការ។ រឿងនេះអាចបង្កទៅជាការរំលោភបំពានសិទ្ធិ ប្រសិនបើមានអាជ្ញាធរមួយចំនួនប្រើអំណាច ដើម្បីគោលដៅរឿងនយោបាយ ឬមិនត្រឹមត្រូវតាមច្បាប់។ អំណាចដែលបានផ្តល់ឱ្យច្រើនជាងមុននេះ ត្រូវបានគេផ្តល់ឱ្យដោយមានអំណះអំណាងថា ប្រជាពលរដ្ឋជាញឹកញាប់ច្រើនខ្វះលទ្ធភាពទៅរកអាជ្ញាធរ។

មាត្រា ១៧ បានចែងថា "ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្តឹងទៅតុលាការខេត្ត-ក្រុង ដើម្បីចេញដីកាការពារ"។ មាត្រានេះមិនបានគិតដល់តថភាពជាក់ស្តែងនៅតាមជនបទ និងចម្ងាយដ៏ឆ្ងាយរវាងភូមិ និងតុលាការដែលនៅឯទីរួមខេត្តឡើយ។ រឿងពិតបញ្ជាក់ច្បាស់ណាស់ថា មានសេចក្តីត្រូវការក្នុងការធ្វើឱ្យអាជ្ញាធរផ្នែកតុលាការមាននៅជិតប្រជាពលរដ្ឋ។

បទបញ្ញត្តិទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ

| ច្បាប់ /ឆ្នាំ | "ខ" ចែង |
|---|---|
| ច្បាប់ UNTAC ឆ្នាំ ១៩៩២ | មាត្រា ៤១ : អំពើបង្កឱ្យរបួសស្នាមដោយចេតនា<br>១. ជនដែលមានចេតនានឹងវាយតប់ បណ្តាលឱ្យមានរបួស ដែលនាំឱ្យពិការភាពជាអចិន្ត្រៃយ៍ ឬពិការបណ្តោះអាសន្នលើសពី ៦ខែ ត្រូវទទួលកំហុសជាបទល្មើសរបួសដោយចេតនា ហើយត្រូវផ្តន្ទាទោស ឃុំឃាំងពី ១ឆ្នាំ ទៅ ៥ឆ្នាំ។<br>២. បើពិការភាពបណ្តោះអាសន្នតិចជាង ៦ ខែ ការផ្តន្ទាទោសដាក់គុកជននោះ ពី ៦ ខែ ដល់ ២ ឆ្នាំ<br>៣. បើគ្មានពិការភាពទេ ទោសដែលត្រូវផ្តន្ទាគឺដាក់គុក ពី ២ ខែ ទៅ ១ ឆ្នាំ។<br>៤. បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ កម្រិតទោសត្រូវទ្វេរមួយជាពីរ។ |

| | |
|---|---|
| សេចក្តីព្រាងក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០១ | មាត្រា ២២២-៦ : អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ២ ឆ្នាំ ដល់ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ ដល់ ១០.០០០.០០០ រៀល កាលបើអំពើហិង្សានេះត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ ស៊ីវិល ឬយោធា ក្នុងការបំពេញមុខងារ ឬនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន។ |
| សេចក្តីព្រាងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៣ | មាត្រា ៣ : អំពើហិង្សាក្នុងគ្រួសាររួមមានៈ ការប៉ះពាល់ដល់ជីវិត ការប៉ះពាល់ដល់បូរណភាពរូបកាយ ការធ្វើទារុណកម្ម ឬការធ្វើអំពើឃោរឃៅ ការឈ្លានពានខាងផ្លូវភេទ។<br>មាត្រា ៤ : អំពើប៉ះពាល់ដល់ជីវិតរួមមានៈ មនុស្សឃាតដោយគិតទុកជាមុន មនុស្សឃាតដោយចេតនា មនុស្សឃាតដោយអចេតនា បណ្តាលមកពីអំពើចេតនានៃជនល្មើស មនុស្សឃាតដោយអចេតនា។<br>មាត្រា ៥ : អំពើប៉ះពាល់ដល់បូរណភាពរូបកាយរួមមាន ការបំពារបំពានលើរូបកាយដោយឥតអាវុធ មានរបួស ឬគ្មានរបួស ការបំពារបំពានលើរូបកាយដោយប្រើអាវុធ ការធ្វើទារុណកម្ម ការធ្វើអំពើឃោរឃៅ។<br>មាត្រា ៦ : អំពើទារុណកម្ម ឬអំពើឃោរឃៅរួមមានៈ ការធ្វើទុក្ខបុកម្នេញបង្កឱ្យមាន ការឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍ បញ្ញាស្មារតីដល់រូបវន្តបុគ្គលក្នុងគ្រួសារ ការប៉ះទង្គិចលើផ្លូវចិត្តនិងលើរូបកាយ ដែលប្រព្រឹត្តហួសពីសីលធម៌ និងច្បាប់កំណត់។<br>មាត្រា ៧ : អំពើឈ្លានពានខាងផ្លូវភេទរួមមានៈ ការប្រើហិង្សាសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស ការធ្វើអាស្រូវភាស។<br>មាត្រា ១១ : ក្នុងកាលៈទេសៈអវត្តមាននៃមន្ត្រីទាំងឡាយ... ដែលបានទទួលនិតិសម្បទាជានគរបាលយុត្តិធម៌រួចហើយនោះមន្ត្រីសមត្ថកិច្ចដទៃទៀតដូចជា មន្ត្រីនគរបាល ភ្នាក់ងារនគរបាល កងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ ភូមិ រួមទាំងមន្ត្រីរបស់ក្រសួងកិច្ចការនារី ដែលបានធ្វើអន្តរាគមន៍ក្នុងការបង្ក្រាប និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ ត្រូវបានទទួលអំណាចពីច្បាប់នេះ ធ្វើកំណត់ហេតុជូនទៅតុលាការ ហើយកំណត់ហេតុនោះមានតម្លៃ ដូចជាកំណត់ហេតុដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ដែរ។<br>មាត្រា ១៣ : ដើម្បីទប់ស្កាត់អំពើហិង្សាដែលកំពុងតែកើត ឬជឿជាក់ថានឹងកើតឡើងអាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ដោយៈ<br>- បង្វែងជនរងគ្រោះ បើមានការស្នើសុំ ឬ ជនមុខសញ្ញាពីកន្លែងដែលអំពើហិង្សាបាន ឬ កំពុងកើតមាន ឬ នឹងអាចកើតមាន<br>- ផ្តល់ឱ្យជនរងគ្រោះ នូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្តល់កន្លែងជំរកបណ្តោះអាសន្ន ដែលអាចធានាសុវត្ថិភាពនិងផ្តល់នូវជំនួយសុខាភិបាលជាបន្ទាន់<br>- ពន្យល់ណែនាំជនរងគ្រោះអំពីសិទ្ធិរបស់ខ្លួន សម្រាប់ទប់ស្កាត់អំពើហិង្សាដែលមាននៅក្នុងមាត្រា ២១ នៃច្បាប់នេះ<br>- ឃាត់ទុកអាវុធ ឬ ឧបករណ៍ដែលជនមុខសញ្ញាបានប្រើប្រាស់ ឬ អាចនឹងប្រើប្រាស់ ដោយជនមុខសញ្ញា។<br>មាត្រា ១៧ : ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្តឹងទៅតុលាការខេត្ត-ក្រុងដើម្បីចេញដីកាការពារ។ ប្រធានតុលាការ ឬ ចៅក្រម ដែលទទួលការ ចាត់តាំងត្រូវចេញដីកាការពារដោយមានវត្តមាន ឬ ពុំចាំបាច់មានវត្តមានជនមុខសញ្ញា។<br>មាត្រា ៤០ : តុលាការធ្វើការផ្តន្ទាទោសជនមុខសញ្ញាតាមបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាធរមាន ដោយតម្រូវឱ្យជននោះធ្វើការងារសហគមន៍ តាមទំហំនៃទោសដែលបានកំណត់ក្នុងច្បាប់។ ការប្រតិបត្តិទោសលើជនជាមុខសញ្ញា ឬ ជនជាប់ចោទត្រូវអនុវត្តតាមនិតិវិធីព្រហ្មទណ្ឌជាធរមាន។ |

ខ-ការលែងលះ

អាជ្ញាធរឃុំនិយាយថាស្ត្រីមិនចង់លែងលះទេ ប៉ុន្តែនៅពេលដែលអំពើហិង្សាមានសភាពខ្លាំងក្លានោះ វានាំឱ្យមានការលែងលះ។

*មេឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ*

*"តាមការពិត ស្ត្រីមិនចង់លែងលះទេ។ គាត់មិនចង់រស់នៅឯកាទេ។ ប៉ុន្តែគាត់ចង់លែងលះ ពីព្រោះដោយសារតែអំពើហិង្សាក្នុងគ្រួសារដែលប្រព្រឹត្តឡើងដោយបុរសជាប្តី ដែលវាយធ្វើបាបគាត់ម្តងហើយម្តងទៀត។ ហេតុនេះហើយគាត់មិនចង់រួមរស់ជាមួយគ្នាវិញទេ ទោះបីជាយើងខិតខំទូន្មានគាត់យ៉ាងណាក្តី"។ (ខេត្តកំពង់ស្ពឺ បទសម្ភាសន៍នៅខែវិច្ឆិកា ២០០៤)*

អំពើហិង្សាក្នុងគ្រួសារ និងភាពខ្វះការទទួលខុសត្រូវរបស់ឪពុកម្តាយ គឺជាមូលហេតុចម្បងក្នុងរឿងលែងលះ បើតាមមតិរបស់ចៅក្រម។

***លោក អ៊ឹង សារុន ប្រធានតុលាការខេត្តកំពង់ឆ្នាំង :***

*"វាគឺជាការពិត អំពើហិង្សាក្នុងគ្រួសារជាហេតុផលមួយ ដែលឈានទៅដល់ការលែងលះ។ ហេតុផលផ្សេងទៀតរួមមានការមិនទទួលខុសត្រូវរបស់ប្តីនៅក្នុងផ្ទះ។ម្យ៉ាងវិញទៀតភាពក្រីក្រ និងជីវភាពរស់នៅ ក៏អាចជាមូលហេតុផងដែរ "*
*(សម្ភាសជាមួយប្រធានតុលាការខេត្តកំពង់ឆ្នាំង នៅខែវិច្ឆិកា ឆ្នាំ ២០០៤)*

រឿងនេះបានបង្ហាញឱ្យដឹងថា ហេតុអ្វីបានជាស្ត្រីគឺជាដើមបណ្តឹង នៅក្នុងរឿងលែងលះស្ទើរតែទាំងអស់ នៅមុខអាជ្ញាធរមូលដ្ឋាន និងតុលាការ។ ស្ត្រីសំណូមពរលែងលះដើម្បីបញ្ចប់ស្ថានភាពនៃការធ្វើទុក្ខទោស ហើយស្ត្រីប្តឹងសុំអាហារកិច្ច ឬការឧបត្ថម្ភជាលុយកាក់ និងការបែងចែកទ្រព្យសម្បត្តិ។ ក្នុងករណីមួយចំនួននៃរឿងក្តីលែងលះ គឺដោយសារតែប្តីបានទៅរៀបការជាមួយស្ត្រីម្នាក់ទៀត ឬចាប់ផ្តើមគ្រួសារថ្មីមួយទៀត។

*"ខ្ញុំបានរៀបការពេញច្បាប់ជាមួយគាត់នៅចំពោះមុខឪពុកម្តាយ ហើយឥឡូវគាត់បានចាកចោលខ្ញុំ ដើម្បីទៅរស់នៅជាមួយស្ត្រីឈ្មោះ XX ដែលរស់នៅក្នុងភូមិនេះ។ ខ្ញុំមានកូន៤នាក់ និងកូនមួយទៀតនៅក្នុងផ្ទៃ។ ឥឡូវគាត់ចង់បានទាំងពីរនាក់ ហើយខ្ញុំនឹងមិនព្រមជាដាច់ខាត។ គាត់ក៏បាននិយាយថា ប្រសិនបើខ្ញុំដាក់ពាក្យប្តឹងទៅឃុំ ដើម្បីរកដំណោះស្រាយ ពួកគេ (គាត់និងស្រីនោះ) នឹងរត់"។ ប្តីប្រពន្ធនេះ បានទទួលការប្រជុំសម្រុះសម្រួលជាច្រើនលើកហើយជាមួយមេភូមិ ប៉ុន្តែនៅតែមិនអាចឈានដល់ការ ព្រមព្រៀងបាន។ នៅថ្ងៃ ២៦ ខែមេសា ប្រពន្ធបានដាក់ពាក្យប្តឹងទៅមេឃុំ ដើម្បីឱ្យជួយដោះស្រាយវិវាទនេះ [១២៥]។*

ករណីរឿងក្តីមានប្រពន្ធពីរ :

*បុរសដែលបានរៀបការហើយម្នាក់ បានទៅរៀបការជាមួយស្ត្រីម្នាក់ទៀត។ ប្រពន្ធដើមបានដាក់ពាក្យប្តឹងថា ប្តីរបស់ខ្លួនបានធ្វើបាបគាត់ជាច្រើនលើកមកហើយ ហើយបានបង្ខំគាត់ព្រមឱ្យប្តីគាត់ រៀបការជាមួយស្រីនោះ។ "ខ្ញុំមិនអាចជាប្រពន្ធរបស់មនុស្សដែលមានប្រពន្ធច្រើនទេ ហើយគាត់បានវាយធ្វើបាបខ្ញុំ និងមានទាំងរបួសស្នាមទៀត។ គាត់បង្ខំខ្ញុំឱ្យយល់ព្រមឱ្យគាត់រៀបការម្តងទៀត។ បើមិនដូច្នោះទេ គាត់នឹងបោះបង់ខ្ញុំចោល។ ហេតុនេះ ខ្ញុំមិនអាចទ្រាំរស់នៅជាមួយគាត់បានតទៅទៀតទេ ដោយសារខ្ញុំខ្លាចគាត់វាយធ្វើបាបខ្ញុំទៀត"។ នៅពេលធ្វើការសម្រុះសម្រួល គូភាគីបានព្រមលែងលះ។ កិច្ចព្រមព្រៀងលើការលែងលះ និងការបែងចែកទ្រព្យសម្បត្តិរួម បានធ្វើឡើងនៅមុខអាជ្ញាធរឃុំ [១២៦]។*

---

១២៥ សូមមើល រឿងក្តីលេខ F2 នៅក្នុងឧបសម្ព័ន្ធ ២។

១២៦ សូមមើល រឿងក្តីលេខ F14 នៅក្នុងឧបសម្ព័ន្ធ ២។

ពាក្យបណ្តឹងលែងលះខ្លះ កើតឡើងដោយសារការបោះបង់ចោលរបស់ប្តី

*ពាក្យបណ្តឹងនេះបានធ្វើឡើងដោយប្រពន្ធលើប្តី ដោយសារការបោះបង់ចោល ។*

*"ខ្ញុំចង់ធ្វើពាក្យប្តឹងឈ្មោះ SK ដែលជាប្តីខ្ញុំ មានអាយុ ៣៧ឆ្នាំ រស់នៅក្នុងភូមិខ្លងពពក ។ គាត់បានចាកចោលផ្ទះអស់ ១៥ ថ្ងៃហើយ ។ មូលហេតុគឺយើងមានជម្លោះនឹងគ្នា ។ ប្តីខ្ញុំ SK បានយកគោចំនួនពីរក្បាល និងរទេះគោទៅស្នាក់នៅឯផ្ទះបងប្អូនគាត់ ។ គាត់មិនទាន់ត្រលប់មកវិញទេរហូតមកដល់ពេលឥឡូវនេះ ។ គាត់ថែមទាំងបានជេរខ្ញុំថែមទៀត"* [១២៧] ។

នៅពេលដែលស្ត្រីប្រឈមមុខនឹងស្ថានភាពលែងលះ ដោយសារការមិនទទួលខុសត្រូវរបស់ប្តី និងអំពើហិង្សាក្នុងគ្រួសារ ពួកគេភាគច្រើនខ្វះខាតធនធានក្នុងការគ្រប់គ្រងថែរក្សាគ្រួសារ ។ ដូច្នេះស្ត្រីជាធម្មតាត្រូវទទួលបន្ទុកលុយកាក់បន្ថែមទៀត ដើម្បីបានលែងលះ ។

*ប្រពន្ធចង់សុំដីកាដើម្បីបែងចែកទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ ក្រោយពីបានលែងលះ ។ ក្រោយពីមានជម្លោះខ្លាំងក្លាមក ប្តីប្រពន្ធបានផ្តាច់សង្វាស ហើយប្តីបានយកទ្រព្យសម្បត្តិទាំងអស់ ។ ប្រពន្ធឥឡូវកំពុងមានទម្ងន់ ។ នៅពេលធ្វើការសម្រុះសម្រួល ប្តីព្រមប្រគល់លុយប្រហែល ១០០ ដុល្លារ ទៅឱ្យប្រពន្ធ ហើយគូភាគីសន្យាថាមិនរករឿងគ្នាទៀតទេ* [១២៨] ។

ក្នុងករណីរឿងក្តីខ្លះ បុរសមិនចង់ចែកទ្រព្យសម្បត្តិទេ ហើយអាជ្ញាធរមូលដ្ឋានមិនអាចបង្ខំគាត់ ឱ្យធ្វើរឿងនេះទេ ។

*រឿងក្តីនេះ បង្កឡើងដោយអំពើហិង្សាក្នុងគ្រួសារ ដែលបានប្រព្រឹត្តដោយប្តី ។ ប្តីប្រពន្ធបានទទួលការសម្រុះសម្រួលជាច្រើនលើកមកហើយ ។ ចុងក្រោយប្រពន្ធបានដាក់ពាក្យសុំលែងលះ និងបែងចែកទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ នៅចំពោះមុខក្រុមប្រឹក្សាឃុំ ។ ប្តីបាននិយាយថា "ខ្ញុំមិនចង់បែងចែកទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ទេ ។ ខ្ញុំចង់ទុកទ្រព្យសម្បត្តិនេះឱ្យកូន ។ ប្រសិនបើប្រពន្ធខ្ញុំចង់លែងលះ នាងអាចចេញពីផ្ទះបាន* [១២៩] ។

ដើម្បីទទួលបានការលែងលះតាមផ្លូវច្បាប់ ប្រជាពលរដ្ឋត្រូវតែទៅតុលាការ ។ ក្រុមប្រឹក្សាឃុំអាចទទួលសំណូមពរសម្រាប់ការលែងលះ ប៉ុន្តែគេមានត្រឹមតែសិទ្ធិអំណាចក្នុងការផ្សះផ្សាប៉ុណ្ណោះ ។ អាពាហ៍ពិពាហ៍ភាគច្រើនមិនត្រូវបានគេចុះបញ្ជីទេ វាគឺជារឿងមិនច្បាស់លាស់មួយ ថាតើពួកគេត្រូវលែងលះ ឬ "ផ្តាច់សង្វាស" ហើយដោះស្រាយរឿងជួយឧបត្ថម្ភទំនុកបំរុង និងការបែងចែកទ្រព្យសម្បត្តិយ៉ាងណា ។ យោងទៅតាមច្បាប់អាពាហ៍ពិពាហ៍ នឹងត្រូវបានចាត់ទុកថាត្រឹមត្រូវតាមច្បាប់ នៅពេលដែលកិច្ចព្រមព្រៀងលើអាពាហ៍ពិពាហ៍ ត្រូវបានគេចុះបញ្ជីដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋាន ប្តីប្រពន្ធទាំងពីរនាក់ និងសាក្សីដែលមានសមត្ថភាព ផ្លូវច្បាប់ចំនួនពីររូបថែមទៀត (ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ មាត្រា ១៤) ។ ច្បាប់បានចែងថា អាពាហ៍ពិពាហ៍នឹងមានប្រសិទ្ធិភាពតាមផ្លូវច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមបទដ្ឋានដែលមានចែងក្នុងច្បាប់ (ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ មាត្រា ៣) ។ ក្នុងការអនុវត្តជាក់ស្តែងមានគូស្រករជាច្រើនអនុវត្តតាមដំណាក់កាលទីមួយនៃនីតិវិធី (ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅឃុំ/សង្កាត់ ហើយរៀបចំធ្វើពិធី) ប៉ុន្តែពួកគេមិនបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍របស់ពួកគេ ក្រោយរៀបចំធ្វើពិធីដើម្បីធ្វើឱ្យអាពាហ៍ពិពាហ៍របស់ពួកគេ ត្រឹមត្រូវពេញលេញស្របទៅតាមច្បាប់នោះទេ ។ ចៅក្រមខ្លះយល់ថា សូម្បីតែប្តីប្រពន្ធមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ក៏ដោយ តុលាការនៅតែមានសមត្ថកិច្ចដោះស្រាយ "ការលែងលះ" ដែរ ជាពិសេសប្រសិនបើប្តីប្រពន្ធនោះមានកូន និងមានទ្រព្យសម្បត្តិរួម ។ អ្នកច្បាប់ផ្សេងទៀតយល់ថា ដោយសារប្តីប្រពន្ធទាំងនោះ មិនបានអនុវត្តតាមនីតិវិធីទាំងអស់របស់ច្បាប់ ពួកគេមិនបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ ហេតុដូច្នេះពួកគេមិនចាំបាច់ត្រូវការលិខិតលែងលះពីតុលាការទេ ។

---

១២៧ សូមមើល រឿងក្តីលេខ A4 នៅក្នុងឧបសម្ព័ន្ធ ២ ។

១២៨ សូមមើល រឿងក្តីលេខ E4 នៅក្នុងឧបសម្ព័ន្ធ ២ ។

១២៩ សូមមើល រឿងក្តីលេខ C2 នៅក្នុងឧបសម្ព័ន្ធ ២ ។

សម្រាប់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ ប្រសិនបើពួកគាត់បានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅឃុំ ហើយពួកគេបានរៀបចំពិធីរៀបអាពាហ៍ពិពាហ៍ទៀត ពួកគេយល់ខ្លួនគេថាជាការ "រៀបអាពាហ៍ពិពាហ៍" ទោះបីពួកគេមិនបានបំពេញនូវដំណាក់កាលចុះបញ្ជីក៏ដោយ។ ការយល់ដឹងផ្នែកវប្បធម៌និងសង្គមរបស់សហគមន៍ គឺដូចៗគ្នា។ បញ្ហានេះគឺមកពីការខ្វះខាតធនធានក្នុងការប្ដឹងទៅតុលាការដើម្បីសុំលែងលះ។ ក្នុងករណីជាច្រើន ស្ត្រីទៅរកអាជ្ញាធរមូលដ្ឋានដើម្បីដោះស្រាយរឿងលែងលះ អាហារកិច្ច និងការបែងចែកទ្រព្យសម្បត្តិ។

ប្រសិនបើប្ដីប្រពន្ធឈានដល់ការព្រមព្រៀងលើការលែងលះហើយនោះ ពួកគេនឹងស្នើសុំអាជ្ញាធរក្រុមប្រឹក្សាឃុំឱ្យធ្វើកំណត់ហេតុមួយបញ្ជាក់ពី "ការលែងលះ"។ ជាទូទៅសមាជិកក្រុមប្រឹក្សាឃុំព្យាយាមបញ្ជូនរឿងក្ដីទាំងនេះទៅតុលាការ ប៉ុន្តែប្រជាពលរដ្ឋចង់ឱ្យរឿងនេះត្រូវបានដោះស្រាយដោយអាជ្ញាធរមូលដ្ឋានវិញ វាចំណាយអស់ប្រាក់កាសតិច និងមិនខាតពេលវេលាច្រើនដូចទៅដល់តុលាការ ហើយពួកគាត់ក៏យល់អំពីនីតិវិធីទាំងនេះផងដែរ។ នៅពេលដែលភាគីទាំងពីរព្រមព្រៀងគ្នាហើយនោះ អាជ្ញាធរឃុំ និងពេលខ្លះមេភូមិបានចេញកំណត់ហេតុលែងលះទាំងនេះឱ្យគេ។

អំពើហិង្សាក្នុងគ្រួសារនិងសំណូមពរសុំលែងលះ មានភាគរយច្រើនលើចំនួនរឿងក្ដី ដែលបានដោះស្រាយដោយអាជ្ញាធរមូលដ្ឋាននៅថ្នាក់ឃុំ។ នៅក្នុងឃុំមួយចំនួន វាអាចឈានដល់ ២៥ ទៅ ៥០% នៃរឿងក្ដីទាំងអស់។ រឿងក្ដីលែងលះមានចំនួន ៤០% នៃរឿងក្ដីរដ្ឋប្បវេណីទាំងអស់ដែលមាននៅមុខតុលាការ ហើយស្ត្រីមាន ៨០% ដែលជាដើមបណ្ដឹង។

ការទទួលបានអាហារកិច្ចសមស្រប គឺជាបញ្ហាធំសម្រាប់ស្ត្រី ក្នុងករណីរឿងផ្ដាច់សង្វាស និងលែងលះ។

*រឿងលែងលះ (ដោយមានប្រពន្ធពីរ) និងអាហារកិច្ច :*

*ប្រពន្ធបានដាក់ពាក្យបណ្ដឹង ក្រោយពីប្ដីគាត់យកប្រពន្ធទីពីរ។ ប្រពន្ធដើមបានទាមទារអាហារកិច្ច។ កិច្ចព្រមព្រៀងបានធ្វើឡើងនៅមុខអាជ្ញាធរឃុំ ដែលប្ដីត្រូវបង់លុយទៅឱ្យប្រពន្ធដើម: "ខ្ញុំព្រមបង់លុយ ៣៨២.៥០០១៛ (ប្រហែល ៨៥ ដុល្លារ) ដើម្បីចិញ្ចឹមកូនដល់អាយុ ១៨ឆ្នាំ"។ គូភាគីសន្យាថា ឈប់រំខានគ្នាទៅវិញទៅមកនៅថ្ងៃមុខ[១៣០]។*

អាហារកិច្ច ជាទូទៅត្រូវបង់ម្ដងទាំងអស់ នៅពេលដែលគូភាគីចុះកិច្ចសន្យាលែងលះគ្នា។ ចំនួនដែលត្រូវបង់ជាធម្មតាមានចំនួនតិចជាងអ្វីដែលត្រូវបង់។ លើសពីនេះ កិច្ចព្រមព្រៀងផ្ដាច់សង្វាស និងអាហារកិច្ចរួមមាន ខដែលចែងថាគូភាគីនឹងមិនបង្កការរំខានដល់គ្នាទៀតទេ ហើយពួកគេមានសិទ្ធិរកប្ដីប្រពន្ធថ្មីបាន។ ហេតុដូចនេះ នៅពេលដែលបុរសរកគ្រួសារថ្មីទៀតនោះ វាជាការពិបាកក្នុងការឧបត្ថម្ភដល់កូនៗ ដែលមានកាលពីអាពាហ៍ពិពាហ៍មុន។

***ការលែងលះ និងអាហារកិច្ច*** *: គូភាគីចុះកិច្ចព្រមព្រៀងលែងលះ នៅក្នុងមេភូមិ។*

*"ខ្ញុំឈ្មោះ YY (ភេទប្រុស) អាយុ ៣០ឆ្នាំ និងឈ្មោះ XX (ភេទស្រី) អាយុ ២៨ឆ្នាំ យើងជាប្ដី ប្រពន្ធព្រមព្រៀងលែងលះគ្នា។ យើងមិនអាចរស់នៅជាមួយគ្នាតទៅទៀតបានទេ។" (ប្រពន្ធនិយាយថា) : "ខ្ញុំ(ស្រី) សូមឱ្យបង់លុយ ៦០០.០០០៛ (១៥០ ដុល្លារ) ដើម្បីចិញ្ចឹមកូន"។ ប្ដីយល់ព្រមបង់លុយចំនួនប៉ុណ្ណោះ។ "ភាគីទាំងពីរសុខចិត្តគោរពសិទ្ធិគ្នាទៅវិញទៅមក ក្នុងការរកប្ដី ឬ ប្រពន្ធថ្មី ហើយនឹងឈប់បង្កការរំខានដល់គ្នាទៀតហើយ" [១៣១]។*

---

១៣០ កំណត់ហេតុព្រមព្រៀងគ្នា : សូមមើល រឿងក្ដីលេខ E3 នៅក្នុងឧបសម្ព័ន្ធ ២។

១៣១ សូមមើល រឿងក្ដីលេខ E5 នៅក្នុងឧបសម្ព័ន្ធ ២។

*អាហារកិច្ច និងជម្លោះគ្រួសារ*

*SS (ភេទប្រុស អាយុ ៤៧ឆ្នាំ) បានរៀបការជាមួយ PP (ភេទស្រី អាយុ ៥០ឆ្នាំ) ហើយមានកូន។ ក្រោយមកគាត់បានទៅរស់នៅជាមួយស្រីម្នាក់ទៀត (អាយុ ៤៦ឆ្នាំ)។ បន្ទាប់មកប្រពន្ធបានដាក់ពាក្យប្ដឹងមកអាជ្ញាធរឃុំ ដើម្បីឱ្យដោះស្រាយ។ គាត់បានសុំឱ្យប្ដីគាត់ត្រលប់មករស់នៅជាមួយគាត់វិញ។ បើមិនដូច្នោះទេ គាត់នឹងឱ្យប្ដីបង់លុយចំនួន ១.000.000រ (២៥0ដុល្លារ)។ ប្ដីមិនព្រមបង់ថ្លៃច្រើនប៉ុណ្ណឹងទេ ប៉ុន្តែគាត់ក៏មិនចង់បែកពីប្រពន្ធថ្មីរបស់គាត់ដែរ។ ហេតុនេះ សមាជិកក្រុមប្រឹក្សាម្នាក់បានសួរទៅប្រពន្ធ : "ចុះអ្នកឯងគិតយ៉ាងម៉េចដែរ បើលោក XX គាត់យកទាំងពីរ"។ (ប្រពន្ធឆ្លើយថា): "បើដូច្នោះមែន ខ្ញុំនឹងចាត់ទុកនាងដូចជាប្អូនស្រីខ្ញុំ" ប៉ុន្តែស្ត្រីទីពីរមិនយល់ព្រមទេ គឺឱ្យបុរសនោះបង់លុយទៅឱ្យស្ត្រីទីមួយ។ សមាជិកក្រុមប្រឹក្សាទុកពេលឱ្យពួកគេគិត។ បន្ទាប់មក ប្ដីបានស្នើសុំបង់ត្រឹម ២៧0.000រ។ ចុងក្រោយ គូភាគីបានចុះហត្ថលេខា និងព្រមព្រៀងលែងលះ ហើយប្ដីព្រមបង់លុយ ៥៤0.000រ (ប្រហែល ១៣៥ ដុល្លារ) ដើម្បីចិញ្ចឹមកូន។ ពួកគេយល់ព្រមថា ឈប់បង្កវិវាទតទៅទៀតហើយ [១៣២]។*

មានរឿងក្ដីមួយចំនួន ដែលឪពុកព្រមបង់លុយប្រចាំខែ ប៉ុន្តែការបង់លុយបានធ្វើឡើងតែនៅពេលដែលធ្វើកិច្ចព្រមព្រៀងប៉ុណ្ណោះ។ បន្ទាប់មក វាមានការពិបាកក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ ប្រសិនបើឪពុកខកខានមិនបានបង់។

***អាហារកិច្ច*** *(ប្រចាំខែ ប៉ុន្តែក្រោយមកខកខានបង់)*

*កិច្ចព្រមព្រៀងលែងលះ បានធ្វើឡើងក្រោយពេលសម្រុះសម្រួល រួមទាំងកិច្ចព្រមព្រៀងបង់លុយ អាហារកិច្ចប្រចាំខែផងដែរ។ នៅពេលដែលប្ដីមិនបានបង់លុយនេះ ប្រពន្ធក៏បានដាក់ពាក្យប្ដឹងនៅមុខក្រុមប្រឹក្សាឃុំ តាមរយៈមេភូមិ។ "ខ្ញុំសូមប្ដឹងពីឈ្មោះ XX អាយុ ២៤ឆ្នាំ រស់នៅក្នុងភូមិនេះ ពីព្រោះគាត់មិនបានគោរពតាមកិច្ចសន្យាចុះថ្ងៃទី ១៧ ឧសភា ឆ្នាំ២00៤ ដែលបានធ្វើនៅមុខឃុំ ថាគាត់នឹងឧបត្ថម្ភប្រចាំខែដល់កូនៗ ពីព្រោះជីវភាពខ្ញុំក្រខ្សត់ណាស់ [១៣៣]។*

ដើម្បីលើកដម្កើងសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ស្ត្រី និងកុមារ វាគឺជាការចាំបាច់ដែលត្រូវមានអាជ្ញាធរ ដែលមានអំណាចយុត្តាធិការនៅជិតប្រជាពលរដ្ឋ។ អាជ្ញាធរដែលអាចដោះស្រាយរឿងរ៉ាវគ្រួសារ ដូចជា តុលាការ គ្រួសារជាដើម។ ស្ត្រីមិនអាចបន្តមានបន្ទុកបង់ថ្លៃសម្រាប់ដំណើរការតុលាការនៅមុខតុលាការទៀតទេ។

**តារាង: បទបញ្ញត្តិទាក់ទងនឹងរឿងអាពាហ៍ពិពាហ៍ និងការលែងលះ**

| បទបញ្ញត្តិទាក់ទងនឹងអាពាហ៍ពិពាហ៍និងគ្រួសារ | បញ្ហាជាក់ស្ដែងនានា |
|---|---|
| ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ (ទី២0 កក្កដា ឆ្នាំ ១៩៨៩)<br>មាត្រា ៣ : អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។ អាពាហ៍ពិពាហ៍និងមានអនុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះ ធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ។<br>មាត្រា១១ : មុនពេលរៀបអាពាហ៍ពិពាហ៍ អនាគតប្ដីប្រពន្ធត្រូវប្ដឹងដល់គណៈកម្មាធិការប្រជាពលរដ្ឋឃុំ-សង្កាត់ខាងលំនៅរបស់នារីដោយមាន ឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលចូលរួមផងក៏បាន។ | - ជាធម្មតាប្រជាពលរដ្ឋកម្ពុជា គោរពតាមទំនៀមទម្លាប់ដំបូងៗ ដូចជា ដាក់ពាក្យសុំរៀបការ រៀបចំពិធីមង្គលការតាមប្រពៃណី ប៉ុន្តែបន្ទាប់ពីរៀបការ ពួកគេមិន បានចុះបញ្ជីអាពាហ៍ពិពាហ៍ ដើម្បីឱ្យមានតម្លៃគតិយុត្តិស្របតាមច្បាប់ទេ។ |

១៣២ សូមមើល រឿងក្ដីលេខ F8 នៅក្នុងឧបសម្ព័ន្ធ ២។

១៣៣ សូមមើល រឿងក្ដីលេខ F6 នៅក្នុងឧបសម្ព័ន្ធ ២។

| | |
|---|---|
| មាត្រា ១៤ : អាពាហ៍ពិពាហ៍នឹងអាចចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់ បាន លុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តយកគ្នាជាប្ដីប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ខាងលំនៅរបស់នារី ។ កិច្ចសន្យាត្រូវចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ប្ដីប្រពន្ធ និងសាក្សីគ្រប់អាយុការពីរនាក់ ។<br><br>មាត្រា ៣៨ : ការលែងលះគ្នា គឺការផ្ដាច់ចំណងអាពាហ៍ពិពាហ៍របស់ប្ដីប្រពន្ធ ដែលបានរៀបការពេញច្បាប់ ក្នុងពេលរស់នៅទាំងពីរនាក់ ។<br><br>មាត្រា ៤១ : ការសម្រេចអំពីការលែងលះគ្នា ជាសមត្ថកិច្ចរបស់តុលាការប្រជាពលរដ្ឋខេត្តក្រុងខាងលំនៅរបស់ចុងចំលើយ ។<br><br>មាត្រា ៤២ : បណ្ដឹងសុំលែងលះគ្នា ត្រូវធ្វើជាលាយលក្ខ័ណ៍អក្សរ ចុះមូលហេតុដែលនាំឱ្យលែងលះគ្នា ។<br>- បណ្ដឹងនោះត្រូវដើមចោទយកទៅជូនតុលាការប្រជាពលរដ្ឋខេត្តក្រុងផ្ទាល់ក៏បាន ឬជូនគណៈកម្មាធិការប្រជាពលរដ្ឋឃុំ ឬសង្កាត់ ខាងលំនៅចុងចំលើយដោយខ្លួនឯងផ្ទាល់ក៏បាន ។<br>- ក្នុងករណីខាងក្រោយនេះ គណៈកម្មាធិការប្រជាពលរដ្ឋឃុំឬសង្កាត់ ត្រូវធ្វើការផ្សះផ្សារក្នុងរយៈ១៥ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្ដឹង ។ បើផ្សះផ្សាពុំបានសម្រេចត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការប្រជាពលរដ្ឋខេត្ត ក្រុង ។ | - រឿងក្ដីរដ្ឋប្បវេណី ដែលប្ដឹងទៅតុលាការញឹកញាប់ជាងគេ គឺទាក់ទងនឹងរឿងលែងលះ ។<br>- បណ្ដឹងសុំលែងលះ ក៏ត្រូវបានប្ដឹងញឹកញាប់ជាងគេផងដែរ នៅថ្នាក់ឃុំហើយចំនួនសរុបនៃរឿងក្ដីទាំងអស់ ទាក់ទងលែងលះ គឺនៅថ្នាក់ឃុំច្រើនជាងនៅតុលាការ ។<br>- តុលាការទទួលដោះស្រាយរឿងលែងលះ "ដែលមិនបានធ្វើឡើង ត្រឹមត្រូវតាមច្បាប់តម្រូវ" ដោយយល់ថាចំណងអាពាហ៍ពិពាហ៍របស់គេជាប់កាតព្វកិច្ចតាមលក្ខណៈ សង្គម និងវប្បធម៌ ។<br>- ករណីលែងលះខ្លះ ត្រូវបានដោះស្រាយដោយគូវិវាទ នៅចំពោះមុខក្រុមប្រឹក្សាឃុំ ដោយធ្វើជាកិច្ចព្រមព្រៀងលែងលះ ។ |

គ-អំពើរំលោភសេពសន្ថវៈ និងការរងគ្រោះទ្វេដង

អំពើរំលោភសេពសន្ថវៈ គឺជាទម្រង់មួយនៃអំពើហិង្សាផ្នែកយេនឌ័រ ដែលភាគច្រើនបានប្រព្រឹត្តឡើងដោយជនដែលស្គាល់ជនរងគ្រោះ ដូចជានៅក្នុងទំនាក់ទំនងក្រុមគ្រួសារ ដោយសាច់ញាតិ ឬអ្នកជិតខាង ។ នៅក្នុងទីរួមខេត្តផ្សេងៗ ការបំពានផ្លូវភេទ ក៏បានកើតឡើងក្នុងបរិបទសេវាកម្ម ដែលផ្ដល់ដោយស្ត្រីក្មេងៗ ដូចជាអ្នកលក់ស្រាបៀរ និងអ្នកដែលគេហៅថា "ស្រីការ៉ាអូខេ"ជាដើម ។ មានរឿងជាច្រើនដែរពីក្រុមបងធំ ។

បណ្ដឹងមួយចំនួនពីបទរំលោភសេពសន្ថវៈ អាចគ្របដណ្ដប់លើស្ថានភាពផ្សេងៗទៀត ។ ឧទាហរណ៍ នៅពេលដែលស្ត្រីត្រូវបានគេបោះបង់ចោលជាមួយកូននោះ គាត់បានប្ដឹងពីបទរំលោភសេពសន្ថវៈ ទោះបីជាទំនាក់ទំនងផ្លូវភេទកើតឡើងដោយមានការព្រមព្រៀងគ្នាក្ដី ដើម្បីទាញចំណាប់អារម្មណ៍ពីអាជ្ញាធរមូលដ្ឋាន ក្នុងរឿងអាហារកិច្ច ។ ការធ្វើបណ្ដឹងដើម្បីទាមទារអាហារកិច្ចដោយត្រង់តែម្ដង ហាក់ដូចជាមិនបានទទួលជោគជ័យទេ ។ ដូចនេះចាំបាច់ដែលខាងស្រី ត្រូវធ្វើឱ្យរឿងក្ដីមានភាពរំជួលចិត្តដល់តម្លៃដែលមាននៅមូលដ្ឋាន ។ ជាធម្មតាបុរសនឹងត្រូវបង់ប្រាក់ ។

*ករណីទី១ ការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ*

*វាគឺជាពាក្យបណ្ដឹងចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ ដែលធ្វើឡើងដោយក្មេងស្រី អាយុ១៩ឆ្នាំ ដោយបាននិយាយថា នៅពេលយប់ "ខ្ញុំបានចេញទៅហៅបងប្រុសខ្ញុំ (ហើយនៅតាមផ្លូវ) ពូ [១៣៤] SS បានមកចាប់កាន់ដៃខ្ញុំ ។ ខ្ញុំមិនអាចរើបានទេ ហើយខ្ញុំយំ ។ មឹងទូចបានពួ" ។*

១៣៤ នៅក្នុងភាសាខ្មែរកាលណាហៅថា "ពូ" គឺសំដៅលើ "ឪពុកមា" តែពាក្យថា "ពូ" នេះក៏ជាទូទៅត្រូវបានស្ត្រីភាគច្រើន ប្រើប្រាស់សម្រាប់ហៅបុរសដែលមានអាយុប្រហាក់ប្រហែលគ្នា ឬមានអាយុច្រើនជាងខ្លួនផងដែរ ។

អំណះអំណាងរបស់ចុងចោទ គឺថាគាត់គ្រាន់តែលេងសើចជាមួយនាង (SP) ទេ ដោយសារនាងចេះតែខ្លាចគាត់ ហើយបាននិយាយថា :"ពូមិនមែនជាព្រាននារីទេ ហើយហេតុអ្វីបានជាឯងចេះតែគេចពីពូ"។ គាត់ក៏បាននិយាយទៀតថា:"បាទខ្ញុំសារភាពថាបានចាប់ដៃនាងមែន ប៉ុន្តែខ្ញុំគ្មានគំនិតអាក្រក់ទេ។ ម្យ៉ាងទៀតយប់នៃខែភ្លឺណាស់ និងមានក្មេង១ជាច្រើនកំពុងនៅលេងទីនោះ"។ ជាលទ្ធផលជនរងគ្រោះឈ្មោះ SP និងឪពុកម្តាយនាងបានដាក់ពាក្យប្តឹងលោក SS ចោទប្រកាន់ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ដោយទាមទារ ១.៥០០.០០០៛ (៣៨០ដុល្លារ) សម្រាប់ការខូចខាតពីជនល្មើស។ នៅពេលសម្រុះសម្រួល សមាជិកក្រុមប្រឹក្សាឃុំម្នាក់បាននិយាយទៅចុងចោទ "ទោះបីជាអ្នកឯងលេងសើចក៏ដោយ ប៉ុន្តែវាជាពេលយប់អាធ្រាត ដូចនេះវាមិនមែនជារឿងល្អធ្វើបែបនេះមកលើរូបនាងទេ។ មិនថាអ្នកឯងស្មោះត្រង់ ឬមានបំណងល្អ ឬអត់នោះទេ"។ ក្រោយពីប៉ុន្មានថ្ងៃក្រោយ ថ្ងៃសម្រុះសម្រួលដ៏តឹងតែងមក នៅថ្ងៃទី១២ មករា ឆ្នាំ២០០៤ គូភាគីបានឈានដល់ការព្រមព្រៀងគ្នា ដោយជនល្មើសយល់ព្រមបង់លុយចំនួន ៣៥០.០០០៛ (៩០ដុល្លារ)។ ក្រោយមកនៅថ្ងៃទី១៥ មករា ឆ្នាំ២០០៤ ការបង់ប្រាក់បានធ្វើឡើងឱ្យទៅជនរងគ្រោះ (ថ្ងៃធ្វើការសម្រុះសម្រួល : ០៨ មករា ឆ្នាំ២០០៤) [១៣៥]។

**ករណីទី២ : បទរំលោភសេពសន្ថវៈ**

រឿងក្តីរំលោភសេពសន្ថវៈនេះ បានធ្វើឡើងដោយលោក TS ដែលជាឪពុករបស់ជនរងគ្រោះឈ្មោះ SY ដែលមានជម្ងឺសរសៃប្រសាទ។ នៅថ្ងៃទី២៩ មេសា ឆ្នាំ២០០៣ លោក TS បានចោទប្រកាន់ លោក កុយ ថាបានរំលោភកូនស្រីមិនគ្រប់ទឹករបស់គាត់ រហូតដល់នាងមានផ្ទៃពោះ ដែលនេះជាការដកស្រង់ "បណ្តឹងលើ លោក កុយ ភេទប្រុស អាយុ៤៥ឆ្នាំ រស់នៅក្នុងឃុំ ខ.ព ខេត្តកំពង់ឆ្នាំង ពីព្រោះគាត់បានរំលោភកូនស្រីរបស់ខ្ញុំ អាយុ ៣៣ឆ្នាំ រហូតនាងមានផ្ទៃពោះ។ ហេតុនេះខ្ញុំចង់ប្តឹង សុំលុយសំណងជម្ងឺចិត្តចំនួន ២.៥០០.០០០៛ (៦៣០ដុល្លារ)"។ នៅថ្ងៃទី៦ ឧសភា ២០០៣ រឿងក្តីត្រូវបានដោះស្រាយដោយការសម្រុះសម្រួលនៅឯទីស្នាក់ការឃុំ។ ចុងចោទយល់ព្រមសងជម្ងឺចិត្ត ដល់ជនរងគ្រោះប្រហែល ១០០ដុល្លារ ហើយចុងចោទបានប្រគល់លុយឱ្យទៅជនរងគ្រោះនៅថ្ងៃ ១០ ឧសភា ២០០៣។ ឃុំមួយនៅក្នុងខេត្តកំពង់ឆ្នាំង [១៣៦]។

**ករណីទី៣**

លោក CC និងនាង VH បានស្រលាញ់គ្នាដោយលួចលាក់ រហូតដល់នាង VH មានផ្ទៃពោះ ហើយ លោក CC បានសុំឱ្យនាង VH រំលូតកូនចេញ។ នៅពេលការរំលូតកូនបានសម្រេចហើយ ម្តាយរបស់នាងបានដឹង ហើយគាត់បានដាក់ពាក្យប្តឹងមកឃុំនៅថ្ងៃ ១៧ កុម្ភៈ ឆ្នាំ២០០៣។ នៅពេលលោក CC បានដឹងថា ម្តាយខាងស្រីបានដាក់ពាក្យបណ្តឹង គាត់បានហៅនាង និងប្រាប់ឱ្យនាងត្រូវនិយាយអ្វីតាមគាត់ចង់បាននៅចំពោះមុខឃុំ ប៉ុន្តែនាងបដិសេធមិនធ្វើតាមពាក្យសម្តីរបស់គាត់ទេ។ ជាចុងក្រោយលោក CC និយាយថា ប្រសិនបើនាងមិននិយាយតាមអ្វីដែលគាត់បានប្រាប់ទេ គាត់នឹងផ្តាច់ទំនាក់ទំនងជាមួយនាង VH។ បន្ទាប់មក នាង VH បានទាមទារថា នាងត្រូវការសំណងចំនួន ២.០០០.០០០៛ (៥០០ដុល្លារ)។ ការសម្រុះសម្រួលលើកទីមួយបានធ្វើនៅថ្ងៃទី២៦ មករា ២០០៣ ដោយមិនមានដំណោះស្រាយឡើយ។ ការសម្រុះសម្រួលលើកទីពីរ បានធ្វើនៅថ្ងៃ ១៤ មិនា ២០០៣ ហើយចុងចោទបានយល់ព្រមសងចំនួន ២៨០.០០០៛ (៧០ដុល្លារ) និងបានប្រគល់លុយនៅថ្ងៃទី ១៦ មិនា ២០០៣។

ឃុំមួយនៅក្នុងខេត្តកំពង់ឆ្នាំង [១៣៧]។

---

១៣៥ សូមមើល រឿងក្តីលេខ F15 នៅក្នុងឧបសម្ព័ន្ធ ២។

១៣៦ សូមមើល រឿងក្តីលេខ B8 នៅក្នុងឧបសម្ព័ន្ធ ២។

១៣៧ សូមមើល រឿងក្តីលេខ B9 នៅក្នុងឧបសម្ព័ន្ធ ២។

*ករណីទី៤ : ការប៉ុនប៉ងរំលោភសេពសន្ថវៈ*

*ការដកស្រង់ចេញពីពាក្យបណ្តឹង "នៅថ្ងៃសុក្រ ទី១០ ខែតុលា ឆ្នាំ២០០៣ នៅវេលាម៉ោង ១១ និង ៣០នាទី លោក ពេល បានហៅកូនស្រីខ្ញុំឈ្មោះ CC ឱ្យទៅយកខ្សែគោជាមួយគាត់ ហើយគាត់បាននាំនាងចូលទៅក្នុងព្រៃ។ នាងបានដើរតាមគាត់ចូលទៅក្នុងព្រៃ។ ចម្ងាយប្រហែល ៣០០ម៉ែត្រពីផ្លូវ លោក ពេល បានប៉ុនប៉ងរំលោភនាង។ ប៉ុន្តែនាងបានរត់រួច ហើយរត់មករកមិត្តភក្តិឱ្យជួយ ដែលកំពុងតែនៅចាំនាងនៅឯផ្លូវ។ មិត្តភក្តិនាងបាននាំនាងមកផ្ទះវិញ"។ ជាលទ្ធផល ឪពុកម្តាយជនរងគ្រោះ បានដាក់ពាក្យបណ្តឹងទាមទារ ២.០០០.០០០រ (៥០០ដុល្លារ) និងសុំឱ្យដាក់ទោសដល់ជនល្មើស។ នៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០០៣ ការសម្រុះសម្រួលបានធ្វើឡើង ហើយជនល្មើសបានយល់ព្រមសងការខូចខាតចំនួន ៨៥០.០០០រ (ប្រហែល ២០០ដុល្លារ)។ ក្រៅពីនេះ គូភាគីបានទៅរកវិហារនៅឯវត្ត ដើម្បីស្បថនៅមុខព្រះភ័ក្រព្រះសង្ឃចំនួន ៤អង្គ និងអាចារ្យផងដែរ (ចាស់ទុំ នៅក្នុងវត្ត)[១៣៨]។*

***ករណីទី៥ : ការចោទប្រកាន់ពីបទរំលោភ***

*លោក TT ជាឪពុក បានឃើញ លោក SS សើយសំពត់របស់កូនស្រីគាត់ចង់រំលោភនាង។ បន្ទាប់មកលោក TT ជាឪពុក បានរត់តម្រង់មកកាន់បុរសនោះ និងកូនស្រីគាត់។ ឃើញដូចនោះ លោក SS បានរត់ទៅផ្ទះខ្លួនបាត់ទៅ។ លោក TT បានសាកសួរកូនស្រីគាត់អំពីរឿងហេតុនេះ ក្រោយមកគាត់បានទៅផ្ទះរបស់ SS ដើម្បីព្រមាន។ តែផ្ទុយមកវិញ ឪពុកម្តាយរបស់ SS ព្យាយាមការពារកូនប្រុសខ្លួន។ ជាលទ្ធផល នៅថ្ងៃទី ២៩ មេសា ២០០៣ លោក TT បានដាក់ពាក្យប្តឹងទៅឃុំ ដើម្បីឱ្យជួយដោះស្រាយ។ នៅថ្ងៃទី៦ ឧសភា ២០០៣ ការសម្រុះសម្រួលបានធ្វើឡើង។ រឿងក្តីនេះបានដោះស្រាយដោយជោគជ័យ ដោយសារឪពុកម្តាយទាំងសងខាងយល់ព្រមស្រុះស្រួលគ្នា ហើយជនល្មើសបានសារភាព និងសន្យាថាឈប់ប្រព្រឹត្តបែបនេះទៀតហើយ។ ឯឪពុកម្តាយរបស់ជននោះក៏បានសន្យាថា នឹងអប់រំកូនប្រុសរបស់ខ្លួន [១៣៩]។*

*ករណីទី៦ : ការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ*

*ជនរងគ្រោះ និងចុងចោទរស់នៅក្នុងភូមិជាមួយគ្នា។ លោក PP ជាបុរសដែលមានគ្រួសារហើយ ឯនាង YY ជាស្ត្រីនៅលីវ។ នាង YY បានចោទលោក PP ថាបានរំលោភនាង ៣ដង។ ក្រោយពី នាង YY មានទម្ងន់ ៤ខែមក នាងបានដាក់ពាក្យនៅថ្ងៃ ១០ ឧសភា ២០០៣ ដើម្បីទាមទារសំណង នៅមុខក្រុមប្រឹក្សាឃុំ តាមរយៈមេភូមិ។ តាមរយៈការសម្រុះសម្រួល កិច្ចព្រមព្រៀងបានធ្វើឡើង នៅថ្ងៃទី ២១ ឧសភា ២០០៣ ដែលលោក PP ព្រមសងទៅនាង YY ចំនួន ៥០០.០០០រ [១៤០]។*

នេះគឺជាការរងគ្រោះទ្វេដង សម្រាប់ស្ត្រីដែលជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ ឬការបង្ករបួសស្នាម។ ស្ថានភាពរបស់ពួកគេកាន់តែធ្ងន់ធ្ងរ ដោយសារការចំណាយទាំងអស់លើតម្លៃធ្វើកោសល្យវិច្ច័យ និងការចំណាយផ្សេងទៀតដែលជនរងគ្រោះត្រូវបង់។ ពួកគេរស់នៅក្នុងភូមិ ឬឃុំដែលនៅឆ្ងាយពីទីរួមខេត្ត។ ព្រះរាជអាជ្ញាមិនដែលធ្វើដំណើរទៅភូមិទេ។ ជនរងគ្រោះត្រូវធ្វើដំណើរជាច្រើនលើកមកកាន់ទីរួមខេត្ត ឬទីក្រុង ដោយបាត់បង់ចំណូលប្រចាំថ្ងៃ ជារៀងរាល់ពេលដែលគេត្រូវធ្វើដំណើរមកកាន់ទីរួមខេត្ត និងបង់ថ្លៃសោហ៊ុយធ្វើដំណើរ និងម្ហូបអាហារសម្រាប់ខ្លួនឯង និងសាក្សីរបស់ខ្លួន[១៤១]។

---

១៣៨ សូមមើល រឿងក្តីលេខ B10 នៅក្នុងឧបសម្ព័ន្ធ ២។

១៣៩ សូមមើល រឿងក្តីលេខ B11 នៅក្នុងឧបសម្ព័ន្ធ ២។

១៤០ សូមមើល រឿងក្តីលេខ E9 នៅក្នុងឧបសម្ព័ន្ធ ២។

១៤១ សូមមើល ការរៀបរាប់ពីរឿងនេះនៅក្នុងជំពូក៣ : ការពិនិត្យធ្វើកោសល្យវិច័យ។

វាហាក់ដូចជាមានរឿងរ៉ាវមួយចំនួនឋិតនៅក្រៅបញ្ជី (black cipher of criminality) ទាក់ទងនឹងរឿងរំលោភលើផ្លូវភេទ។ ជនរងគ្រោះភាគច្រើន ច្រើនតែធ្វើពាក្យបណ្តឹងមកអាជ្ញាធរមូលដ្ឋាន ហើយរឿងក្តីភាគច្រើនត្រូវបានគេដោះស្រាយនៅទីនោះ ឯពួកគេក៏មិនតវ៉ាឡើងទៅទៀតដែរ។ ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ ឬការរំលោភផ្លូវភេទនៅតាមតំបន់ជនបទ ជាដំបូងទៅរកមេភូមិ អាជ្ញាធរឃុំ និងនគរបាលនៅឃុំ។ យោងតាមសក្ខីកម្មជាច្រើនដែលយើងបានទទួល នៅរឿងក្តីជាច្រើនដែលអាជ្ញាធរទាំងនេះ រួមទាំងនគរបាលដែរ បានព្យាយាមធ្វើការសម្រុះសម្រួលរឿងក្តីនៅថ្នាក់មូលដ្ឋាន។ ប្រសិនបើមិនមានការដោះស្រាយ នៅមូលដ្ឋានជាមួយជនដៃដល់ទេ នគរបាលនឹងដាក់ពាក្យឡើងទៅព្រះរាជអាជ្ញា។ នៅក្នុងរឿងក្តីមួយចំនួនទៀត ដោយសារតែមានវត្តមានរបស់អង្គការក្រៅរដ្ឋាភិបាល ជនរងគ្រោះត្រូវបានគេជួយនៅក្នុងការដាក់ពាក្យបណ្តឹងទៅកាន់ព្រះរាជអាជ្ញា និងតុលាការ។ រឿងក្តីមួយទាមទារឱ្យមានភស្តុតាងជាក់ស្តែង មុនពេលរឿងនោះអាចត្រូវបានដាក់ឡើងទៅលើបាន។ ជនរងគ្រោះត្រូវបានស្នើសុំដោយព្រះរាជអាជ្ញា ឬនគរបាល ឱ្យធ្វើកោសល្យវិច្ច័យ។ វាបានក្លាយជាបន្ទុកដ៏ធំមួយ និងជាឧបសគ្គក្នុងការទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះ ដោយអំពើរំលោភសេពសន្ថវៈ ឬអំពើបៀតបៀនលើរូបរាងកាយផ្សេងទៀត។ ជាមួយនឹងការធ្វើកោសល្យវិច្ច័យ ជនរងគ្រោះត្រូវបង់ថ្លៃធ្វើដំណើរមកកាន់ទីរួមខេត្តជាច្រើនលើក ដើម្បីតាមដានរឿងក្តីរបស់ខ្លួន។ ជនរងគ្រោះឋិតនៅក្រោមសម្ពាធគ្រប់ប្រភេទ រហូតដល់បោះបង់ចោលរឿងក្តី មុនពេលធ្វើសវនាការក៏មានដែរ។

## ៣.៤. បទល្មើសព្រហ្មទណ្ឌនានា

យោងតាមការស្ទង់មតិរបស់ IRL សមាជិកនៃអាជ្ញាធរផ្លូវការ (នគរបាល ចៅក្រម ព្រះរាជអាជ្ញា មេធាវី) យល់ថាបទល្មើសគឺជាបញ្ហាចម្បងក្នុងសង្គម នៅមុនភាពក្រីក្រទៅទៀត។ ប្រហែលជាការឆ្លើយតបបែបនេះ ដោយសារតែមានការពាក់ព័ន្ធនឹងវិជ្ជាជីវៈជាមួយនឹងរឿងរ៉ាវទាំងនេះ។ ក្រុមផ្សេងទៀតដែលបានគេស្ទង់មតិបានយល់ថា ភាពក្រីក្រគឺជាបញ្ហាសង្គមធ្ងន់ធ្ងរជាង។

សម្រាប់ក្រុមគោលដៅផ្សេងៗទៀត បទល្មើសឋិតនៅពីក្រោយភាពក្រីក្រ ឬបញ្ហាសង្គមផ្សេងទៀត (ដូចជាជំងឺ សុខភាព ។ល។ និង ។ល។)។ អ្នកចូលរួមក្នុងសិក្ខាសាលា បានពិភាក្សាប្រភេទបទល្មើសនានា ដែលបានកើតឡើងនៅភូមិ និងឃុំរបស់ពួកគេ ដូចជាអំពើហិង្សាក្នុងគ្រួសារ បទរំលោភសេពសន្ថវៈ ក្រុមបងធំ អំពើប្លន់ និងការបង្ករបួសស្នាម។ បទល្មើសតូចតាចត្រូវបាន ដោះស្រាយដោយអាជ្ញាធរមូលដ្ឋាន។ បទល្មើសធ្ងន់ធ្ងរ ត្រូវបានបញ្ជូនទៅនគរបាល។

**តារាង: រឿងក្តីព្រហ្មទណ្ឌនានា ដែលបានយល់ឃើញដោយអ្នកចូលរួមសិក្ខាសាលា**

| បញ្ហាចម្បង១ | ប្រភេទនៃវិវាទ | ដើមហេតុ |
|---|---|---|
| **បញ្ហារឿងព្រហ្មទណ្ឌ** | ១- ចោរកម្ម និងអំពើប្លន់ | រឿងក្តីមួយចំនួនទាក់ទងជាមួយនឹងភាពក្រីក្រ។ |
| | ២- ការវាយតប់ និង បង្ករបួសស្នាម | ទាក់ទងជាមួយនឹងវិវាទផ្សេងៗដូចជាការវាយតប់គ្នាការប្រើប្រាស់ជាតិស្រវឹង |
| | ៣- ក្រុមបងតូចបងធំ | រឿងនេះហាក់ដូចជាមានការកើនឡើង និងជាបញ្ហាដែលគួរយកចិត្តទុកដាក់ ទោះបីនៅតំបន់ជនបទក្តី។ ផលវិបាកៈ ការបង្ករបួសស្នាម ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។ |
| | ៤- បង្កអសន្តិសុខដោយហ្វូងមនុស្ស | ពិសេសទាក់ទងទៅនឹងអសន្តិសុខ និងកង្វះខាតការត្រួតពិនិត្យដោយអាជ្ញាធរនានា |
| | ៥- មនុស្សឃាត | ខ្លះទាក់ទងនឹងអំពើប្លន់ រំលោភសេពសន្ថវៈ |
| | ៦- គ្រោះថ្នាក់ចរាចរ និងផ្សេងៗ | បញ្ហានេះហាក់ដូចជាមានការកើនឡើងនៅតាមតំបន់ទីប្រជុំជន |

នៅក្នុងការធ្វើសម្ភាសន៍ និងសិក្ខាសាលា អ្នកចូលរួមបានបង្ហាញពីរបាំងពីរយ៉ាងសម្រាប់ជនរងគ្រោះ ដោយអំពើបទល្មើសព្រហ្មទណ្ឌ ក្នុងការស្វែងរកយុត្តិធម៌ៈ ក- តម្លៃពិនិត្យធ្វើកោសល្យវិច្ច័យដែលត្រូវបង់ដោយជនរងគ្រោះសម្រាប់ការពិនិត្យ ក្នុងការផ្តល់ភស្តុតាងនៃបទល្មើស និងការចំណាយផ្សេងទៀត និង ខ- មិនមានសំណងខូចខាត ។

សំណងរដ្ឋប្បវេណីសម្រាប់ជនរងគ្រោះ

តម្លៃថ្លៃសម្រាប់ជនរងគ្រោះ ក្នុងការប្តឹងរឿងក្តីព្រហ្មទណ្ឌមកតុលាការ គឺជារនាំងមួយក្នុងចំណោមរនាំងផ្សេងទៀត ដើម្បីទៅរកតុលាការ ។ ជនរងគ្រោះក៏មិនហ៊ានទៅរកតុលាការដែរ ដោយសារស្ថានភាពមិនប្រាកដថា ជនរងគ្រោះនឹងទទួលសំណងខូចខាត ឬការខាតបង់នោះ ។ ស្ថានភាពទាំងនោះអាចបង្ហាញប្រាប់ថា ហេតុអ្វីបានជាមានរឿងក្តីជាច្រើនត្រូវបាន "សម្រុះសម្រួល" ដោយនគរបាល ឬអាជ្ញាធរមូលដ្ឋាន នៅក្រៅប្រព័ន្ធតុលាការ ។ យោងតាមបទសម្ភាសន៍ និងរបាយការណ៍មួយចំនួនរបស់អង្គការក្រៅរដ្ឋាភិបាល រឿងក្តីព្រហ្មទណ្ឌនៅមូលដ្ឋានភាគច្រើន រួមទាំងអំពើប្លន់ បង្ករបួសស្នាម និងរំលោភសេពសន្ថវៈផង ត្រូវបានដោះស្រាយដោយការសម្រុះសម្រួលនៅចំពោះមុខនគរបាល ឬអាជ្ញាធរមូលដ្ឋាន ។

តាមការអនុវត្ត ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌមិនបានទទួលសំណងអ្វីទេ សូម្បីតែពេលដែលជនជាប់ចោទត្រូវបានដាក់ទោសក៏ដោយ ។ ដើម្បីអនុវត្តការបង់សំណងរដ្ឋប្បវេណី ជនរងគ្រោះត្រូវមានពាក្យបណ្តឹងរដ្ឋប្បវេណីមួយ ដោយការចំណាយបិតលើពួកគេ (ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីមាត្រា ១៩៣) ។ ប្រសិនបើជនល្មើសមិនព្រមបង់ តុលាការនឹងដាក់ទោសទណ្ឌពន្ធនាគារដើម្បីបង្ខំលើទណ្ឌិតឱ្យសង (ច្បាប់ស្តីពីការដាក់គុក បង្ខំដល់រូបកាយ មាត្រា ១០) ។ ការដាក់ពន្ធនាគារនេះមិនអាចមានរយៈពេលលើសពី ២ឆ្នាំបានទេ ។ យោងតាមចៅក្រម និង ព្រះរាជអាជ្ញា មានជនល្មើសតែ ៣ ទៅ ៥នាក់ប៉ុណ្ណោះក្នុងមួយឆ្នាំដែលព្រមបង់ថ្លៃសំណងរដ្ឋប្បវេណីឱ្យទៅជនរងគ្រោះ ។ ជនល្មើសភាគច្រើនមិនអាច ឬមិនចង់សងសំណងរដ្ឋប្បវេណី និងតម្លៃចំណាយលើតុលាការឱ្យទៅជនរងគ្រោះទេ ពួកគេសុខចិត្តនៅជាប់ទោសពន្ធនាគារវែងថែមទៀត ជាជាងសងសំណង ។ ស្ថានភាពនេះបានជម្រុញឱ្យគូភាគី សុខចិត្តទទួលយកការដោះស្រាយក្រៅផ្លូវការនៅក្រៅតុលាការ នៅចំពោះមុខអាជ្ញាធរមូលដ្ឋាន និងនគរបាល ។ តាមវិធីបែបនេះ ជនល្មើសចៀសផុតពីដំណើរការព្រហ្មទណ្ឌ ហើយជនរងគ្រោះទទួលបានសំណងខូចខាតមួយចំនួន ។ នៅក្នុងសហគមន៍មួយចំនួន ជនល្មើសត្រូវបានបង្ខំឱ្យសុំទោស និងសន្យាថាគេនឹងមិនប្រព្រឹត្តអំពើនេះទៀតទេ ។ ពួកគេថែមទាំងត្រូវបានគេឱ្យទៅស្បថនៅក្នុងវត្ត ដើម្បីឱ្យពង្រឹងការប្តេជ្ញាចិត្តរបស់គេ ។ ឧទាហរណ៍មួយដែលយើងបានស្រាវជ្រាវរកឃើញ គឺយុវជនម្នាក់ត្រូវបានចោទប្រកាន់ នៅក្នុងរឿងក្តីនៃបទប៉ុនប៉ងរំលោភសេពសន្ថវៈ ឪពុកម្តាយជនរងគ្រោះបានសុំឱ្យឪពុកម្តាយជនល្មើសប្តេជ្ញាអប់រំកូនខ្លួន ដើម្បីធានាថា កូននឹងមិនប្រព្រឹត្តរឿងនោះទៀត ។ រឿងនេះបង្ហាញថាក្រៅពីសំណងជាលុយកាក់ ជនរងគ្រោះអាចស្នើសុំមានការបង្កាមិនឱ្យមានអំពើបែបនេះកើតឡើងម្តងទៀត រួមទាំងការអប់រំ និងការពង្រឹងតម្លៃផ្លូវចិត្ត និងសាសនា តាមរយៈការដោះស្រាយបែបនេះ ។ វាមានសារៈសំខាន់ក្នុងការគិតដល់ការបង្ការកុំឱ្យមានបទល្មើសតាមគ្រប់រូបភាព ជាពិសេសនៅក្នុងករណីជនល្មើសក្មេងៗ ។

រឿងនេះបង្ហាញពីកង្វះឱកាសការងារនៅពេលជាប់ពន្ធនាគារ ហេតុនេះអ្នកជាប់ពន្ធនាគារមិនអាចរកប្រាក់ចំណូលបានទេ ដើម្បីជួយដល់ក្រុមគ្រួសាររបស់ពួកគេ និងដើម្បីសងសំណងនៅពេលជាប់ពន្ធនាគារ ។

តារាង៖ មូលដ្ឋានច្បាប់សម្រាប់ចំណាត់ការក្តីព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី

| ខ្លឹមសារសង្ខេប | បញ្ញត្តិច្បាប់ |
|---|---|
| បណ្តឹងអាជ្ញា និងរដ្ឋប្បវេណី | **ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣**<br>មាត្រា ២ : បទល្មើសព្រហ្មទណ្ឌណាក៏ដោយ អាចបណ្តាលឱ្យមានបណ្តឹងពីរយ៉ាងផ្សេងពីគ្នា គឺបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ។<br>មាត្រា ១៦ : បណ្តឹងរដ្ឋប្បវេណីធ្វើបានក្នុងពេលជាមួយនឹងបណ្តឹងអាជ្ញាដែរ នៅចំពោះមុខចៅក្រមដដែលនោះ ។ បណ្តឹងរដ្ឋប្បវេណីអាចធ្វើដោយឡែកបាន ។ ក្នុងករណីក្រោយនេះ ការធ្វើបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្អាកសិន កាលណាបណ្តឹងអាជ្ញាមិនទាន់បានសម្រេចជាស្ថាពរនៅឡើយ ។ |
| បណ្តឹងអាជ្ញា ជាបន្ទុករបស់ព្រះរាជអាជ្ញា | **ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣**<br>មាត្រា ៤៨ : ក្នុងករណីណាក៏ដោយមន្ត្រីនគរបាលយុត្តិធម៌ គ្មានសិទ្ធិតម្កល់ទុកឥតចាត់ការនូវរឿងអាជ្ញា ដែលខ្លួនបានទទួលទោះមានការសម្រុះសម្រួលព្រមព្រៀងគ្នាហើយក៏ដោយ គឺត្រូវធ្វើកំណត់ហេតុបញ្ជូនទៅរដ្ឋអាជ្ញាមានសមត្ថកិច្ចជាដរាប ។ |
| បណ្តឹងអាជ្ញាមិនអាចសម្រុះសម្រួលបានឡើយ | **ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣**<br>មាត្រា ៧ : បណ្តឹងអាជ្ញាមិនអាចសម្រុះសម្រួលបានដោយកិច្ចការណាមួយឡើយ ។ សាលាជំរះក្តី បង្ក្រាបបទល្មើសព្រហ្មទណ្ឌ ដែលនឹងមានចែងក្នុងមាត្រាខាងមុខ កាលបើបានទទួលដឹងអំពីបទល្មើសព្រហ្មទណ្ឌណាមួយហើយ ត្រូវជំនុំជំរះបទល្មើសព្រហ្មទណ្ឌនោះ ។ ការមិនគោរពតាមគោលការណ៍នេះ ត្រូវទុកជាបទល្មើសមិនជំនុំជំរះ ហើយបទល្មើសនេះត្រូវផ្តន្ទាទោស ដាក់វិន័យរដ្ឋបាល ឬដាក់គុកពី ៦ ថ្ងៃ ដល់ ១ ខែ ។<br>មាត្រា ៨ : ការធ្វើបណ្តឹងអាជ្ញា និងការជម្រុញបណ្តឹងអាជ្ញានេះឱ្យមានដំណើរការ ជាមុខងាររបស់អយ្យការ ។ |
| តុលាការសម្រេចអំពីសំណងជូសជុល និងជម្ងឺចិត្ត | **ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣**<br>មាត្រា ១៥១ : ជាមួយគ្នានឹងការសម្រេចអំពីទោស តុលាការក៏ត្រូវសម្រេចផងដែរអំពីការជូសជុលសំណង និងជម្ងឺចិត្ត ។ |
| ដើមបណ្តឹងត្រូវដាក់ពាក្យទាមទារសំណង និងជម្ងឺចិត្ត | **ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣**<br>មាត្រា ១៥៣ : ក្នុងករណីផ្តន្ទាទោស សាលក្រមត្រូវបានអនុវត្ត និងធានាដោយរដ្ឋអាជ្ញា ចំពោះទោសគុក និងការទារប្រាក់ពិន័យ ។ ចំណែកឯការជូសជុលសំណង និងជម្ងឺចិត្តនោះត្រូវបានអនុវត្ត ក្រោយពីមានពាក្យសុំនៃដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ បានសុំតាមចំណែករបស់ខ្លួន ។ |
| ដាក់ពន្ធនាគារដល់រូបកាយដើម្បីបង្ខំឱ្យបង់នូវសំណងជូសជុល | **ច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយ ( ឆ្នាំ ២០០២)**<br>មាត្រា ៣ : ការដាក់គុកបង្ខំដល់រូបកាយគឺជាវិធានការ បង្ខំទណ្ឌិតឱ្យសងធនទណ្ឌតែប៉ុណ្ណោះ មិនមែនជាការកាត់កងឱ្យរួចពីធនទណ្ឌនោះទេ ។ នៅពេលដែលទណ្ឌិតបានរួចផុតពីកំណត់កាលដាក់ទោសបង្ខំដល់រូបកាយ ប្រាក់ដែលទណ្ឌិតមិនទាន់បានសងប៉ុន្មាន ត្រូវនៅជំពាក់ដដែល ។ ប៉ុន្តែមិនត្រូវ យកទណ្ឌិតនេះទៅដាក់គុកបង្ខំដល់រូបកាយជាថ្មី ដើម្បីទារប្រាក់ជំពាក់ដដែលនេះទៀតទេ ។ |

| | |
|---|---|
| | មាត្រា ១០ : ...ក្នុងរឿងព្រហ្មទណ្ឌមិនចាំបាច់ឱ្យមានបណ្តឹងពីភាគីដើមបណ្តឹងទេ តុលាការត្រូវតែសម្រេចបង្គាប់ឱ្យដាក់គុកបង្ខំដល់រូបកាយដើម្បីទារធនទណ្ឌ បើកូនបំណុលមិនព្រមសង។<br>មាត្រា ៧ : ...ទោះបីប្រាក់ជំពាក់នោះមានចំនួនច្រើនយ៉ាងណាក៏ដោយ ក៏រយៈវេលាដែលត្រូវដាក់គុកទណ្ឌិតតែម្នាក់ឯងក្នុងរឿងតែមួយដោយសរុបទាំងអស់ មិនត្រូវឱ្យលើសពី ពីរឆ្នាំទេ។ |

## ៤. ការរំលោភសិទ្ធិបុគ្គល និងនីតិវិធីច្បាប់

នៅក្នុងការស្ទង់មតិរបស់ IRL អាជ្ញាធរផ្លូវការ (ចៅក្រម និងនគរបាល) និងអាជ្ញាធរឃុំបានចង្អុលបង្ហាញថា ភាពខ្វះខាតក្នុងការគោរពសិទ្ធិមនុស្ស ក៏ជាបញ្ហាមួយចម្បងក្នុងសង្គមដែរ។ ការរំលោភបំពានទៅលើសិទ្ធិមនុស្សមិនគ្រាន់តែជារឿងដែលមានពីពេលមុននោះទេ។ ប៉ុន្តែមានតែរឿងក្តីមួយចំនួននៃការរំលោភសិទ្ធិមនុស្សប៉ុណ្ណោះ ត្រូវបានគេគិតថាសក្តិសមនឹងប្តឹងទៅតុលាការ។ ការយល់បែបនេះមិនមែន ដោយសារតែខ្វះការយល់ដឹង ពីសិទ្ធិដែលត្រូវបានគេរំលោភនោះទេ តែក៏ដោយសារខ្វះទំនុកចិត្តលើស្ថាប័ន ថានឹងដោះស្រាយរឿងទាំងនេះបាន។

ពីមុនមក ប្រជាពលរដ្ឋមិននិយាយដោយចំហអំពីរឿងរំលោភសិទ្ធិមនុស្ស ដែលពួកគេបានរងគ្រោះទេ សូម្បីតែក្នុងកំឡុងពេលសង្គ្រាមក៏ដោយ។ ការបាត់បង់ជីវិតប្រហែលមួយលានប្រាំពីរសែននាក់ (ប្រហែលជា ២៥%នៃប្រជាពលរដ្ឋទាំងអស់)[១៤២] ការផ្លាស់ទីកន្លែងដែលមានសភាពខ្លាំងក្លា ភាពក្រីក្រតោកយ៉ាក ការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ និងការដួលរលំខាងស្ថាប័ន គឺជាមរតកដែលបានបន្សល់ទុកដោយសង្គ្រាមជាងបីទសវត្សរ៍ និងរបបនយោបាយដែលប្រើហិង្សា។ ការសងការខូចខាតដល់ជនរងគ្រោះនិងការធានាមិនឱ្យមានការរំលោភបំពាន លើសិទ្ធិមនុស្សម្តងហើយម្តងទៀតនៅតែមិនទាន់បានដោះស្រាយ[១៤៣]។ វាហាក់ដូចជាមិនមានតម្រូវការយុត្តិធម៌ជាចំហទាល់តែសោះ ក្នុងទំនាក់ទំនងទៅនឹងការរំលោភបំពានសិទ្ធិមនុស្ស ដែលមានកាលពីមុន ប៉ុន្តែវាមិនមែនមានន័យថារបួសស្នាមទាំងនោះត្រូវបានសះជានៅឡើយទេ។ ផ្ទុយទៅវិញ វាគ្រាន់តែអាចធ្វើការឆ្លុះបញ្ចាំងនូវទស្សនៈ ជាទូទៅថា វាមិនមានលទ្ធផលអ្វីទេ ចំពោះការព្យាយាមឱ្យមានការទទួលស្គាល់ការរំលោភបំពានដែលបានធ្វើពីមុន និងសងការខូចខាតលើរឿងនេះ។ មិនទាន់មានការបញ្ចប់អំពីបញ្ហានេះ លើអំពើរំលោភសិទ្ធិមនុស្សកន្លងមកនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។

ថ្មីៗនេះ មហាសន្និបាតអង្គការសហប្រជាជាតិបានបញ្ចេញនូវការបារម្ភរបស់ខ្លួន អំពី "ការរំលោភបំពានលើសិទ្ធិមនុស្សដែលមានជាបន្តបន្ទាប់ រួមទាំងការធ្វើទារុណកម្ម ការដាក់គុកបណ្តោះអាសន្នហួសពេលកំណត់មុនការកាត់ក្តី ការរំលោភលើសិទ្ធិការងារ ការបណ្តេញចេញដោយបង្ខំ និងអំពើហិង្សាផ្នែកនយោបាយ រួមទាំងការសំលាប់សកម្មជននយោបាយ(...)"[១៤៤]។ អង្គការសហប្រជាជាតិបានបង្ហាញឱ្យឃើញថា ភាគច្រើននៃអ្នកដែលត្រូវបានគេចោទប្រកាន់ថា បានប្រព្រឹត្តិទារុណកម្ម និងការរំលោភបំពានសិទ្ធិមនុស្សរីករាយនឹងភាពគ្មានទោស (និរទោស) នៅពេលដែលប្រជាពលរដ្ឋក្រីក្រដែលត្រូវបានគេចោទប្រកាន់ពីបទល្មើសតូចតាច ហើយឋិតនៅក្នុងការឃុំឃាំងមុនពេលសវនាការអស់រយៈពេលយ៉ាងយូរ។

---

[១៤២] គេហទំព័ររបស់ Genocide Watch : http://www.genocidewatch.org/CambodiaHR399.htm (ថ្ងៃចូលមើលគេហទំព័រ : មិថុនា ឆ្នាំ ២០០៥)

[១៤៣] អង្គជំនុំជំរះវិសាមញ្ញសម្រាប់កាត់សេចក្តីមេដឹកនាំខ្មែរក្រហម គឺជាយន្តការមួយដែលប្រជាពលរដ្ឋកម្ពុជាអាចរកសេចក្តីពិត និង យុត្តិធម៌។

[១៤៤] អង្គការសហប្រជាជាតិ (ឆ្នាំ ២០០៤) : *សេចក្តីសម្រេចចិត្តដែលបានអនុម័តដោយ មហាសន្និបាត លើស្ថានភាពសិទ្ធិមនុស្ស នៅកម្ពុជា* A/RES/58/191 (២៣ មិនា ២០០៤) ទំព័រ ៣ (ចាប់ពីនេះទៅ សរសេរថា A/RES/58/191)។

ករណីរំលោភសិទ្ធិមនុស្សមួយចំនួន ទាក់ទងនឹងដំណើរការក្តីព្រហ្មទណ្ឌ និងស្ថានភាពនៅក្នុងពន្ធនាគារ។ អ្នកទាំងនោះមិនបានដឹងពីសិទ្ធិរបស់ខ្លួន ដែលត្រូវមានអ្នកបកប្រែ ឬការឃុំឃាំងមុនសវនាការមានពេលកំណត់នោះទេ។ ផ្ទុយទៅវិញ បើពួកគេអាចដឹងពីសិទ្ធិរបស់គេ ក៏គេមិនដឹងថាមានសមត្ថកិច្ចណាដែលអាចប្តឹងបានដែរ នៅពេលដែលសិទ្ធិត្រូវបានគេរំលោភបំពាននោះ។ ឧទាហរណ៍ ដោយសារមិនមានមេធាវីការពារនៅក្នុងខេត្តមួយចំនួន ដូចជាខេត្តរតនៈគីរីជាដើម ទោះបីជាជនជាប់ចោទដឹងថាពួកគេមានសិទ្ធិទទួលបានមេធាវីការពារក្តី ក៏គ្មានលទ្ធភាពក្នុងការដាក់ពាក្យបណ្តឹងដែរ នៅពេលដែលពួកគេមិនមានអ្នកតំណាងនៅក្នុងសវនាការ។ ក្នុងករណីការធ្វើទារុណកម្មពេលជាប់ឃុំឃាំង ទោះបីអ្នកជាប់ពន្ធនាគារដឹងថាការធ្វើទារុណកម្មនៅកន្លែងនគរបាលជារឿងខុសច្បាប់ បណ្តឹងមិនត្រូវបានគេធ្វើទេ ដោយសារគ្មាននីតិវិធី ឬពីព្រោះការភ័យខ្លាចចំពោះការសងសឹក។

ការសង្កេតមើលស្ថានភាពពន្ធនាគារ: សិទ្ធិពន្ធនាគារ

***ពន្ធនាគារខេត្តរតនៈគីរី*** [១៤៥]

*មានទណ្ឌិតប្រមាណ ៩០នាក់នៅក្នុងពន្ធនាគារខេត្ត ដែលបានឃុំខ្លួនក្នុងបន្ទប់តូចៗ។ មានប្រហែលជា ១៥នាក់ ក្នុងបន្ទប់មួយ (ទំហំប្រហែល ៤ គុណនឹង ៣ ម៉ែត្រក្រឡា)។ មានស្ត្រី ៣នាក់ដែលឃុំនៅក្នុងបន្ទប់មួយ។ ហេដ្ឋារចនាសម្ព័ន្ធជាទូទៅមានសភាពទ្រុឌទ្រោម ហើយអនុប្រធានមន្ទីរឃុំឃាំងបានប្រាប់យើងថា ដំបូលលិចនៅពេលមានភ្លៀង។ បន្ទប់មានទ្វារមួយ និងបង្អួចមួយដែលមានចម្រឹងដែក។ អ្នកជាប់ពន្ធនាគារ ត្រូវនៅទីនោះពេញមួយថ្ងៃ។*

*មានជនជាតិដើមភាគតិចច្រើនគួរសមនៅក្នុងពន្ធនាគារ។ ជនជាតិដើមភាគតិច ៧នាក់ត្រូវបានជាប់ចោទពីបទល្មើសព្រៃឈើ។ អ្នកជាប់ពន្ធនាគារខ្លះត្រូវបានជាប់ចោទពីអំពើឃាតកម្ម និងបង្ករបួសស្នាម ប៉ុន្តែក៏មានអ្នកផ្សេងទៀតផងដែរ ដែលបានជាប់ចោទពីបទល្មើសមិនធ្ងន់ធ្ងរ។ មានក្មេងប្រុសម្នាក់អាយុ ១៦ឆ្នាំ ជាប់ចោទពីបទប្រើប្រាស់គ្រឿងញៀន។ គេបាននិយាយប្រាប់ថា ក្មេងនេះមានថ្នាំ "យ៉ាម៉ា" ដែលជាថ្នាំគ្រាប់ចេញពីប្រទេសថៃ ហើយដែលប្រើ "ដើម្បីធ្វើឱ្យមនុស្សនោះមានកម្លាំងខ្លាំង"។*

***សិទ្ធិតាមផ្លូវច្បាប់ក្នុងពេលជាប់ឃុំ និងការជម្រះ***

*អ្នកជាប់ពន្ធនាគារជាច្រើនបានប្រាប់ថា ពួកគេបានទទួលការធ្វើទារុណកម្មនៅក្នុងពេលជាប់ឃុំឃាំង នៅជាមួយនគរបាល។ ប្រធានតុលាការ និងព្រះរាជអាជ្ញាបានឱ្យយើងដឹងថា កង្វះខាតមេធាវីនៅក្នុងខេត្ត ដើម្បីការពារជនជាប់ចោទនៅក្នុងពេលសវនាការដូចបានតម្រូវដោយច្បាប់។*

*ជនជាតិដើមភាគតិចបានប្រឈមមុខនឹងសវនាការ ដោយគ្មានមេធាវី ឬក៏អ្នកបកប្រែភាសាទេ។*

*អ្នកជាប់ពន្ធនាគារបានរអ៊ូរទាំថា ពួកគេគ្មានលុយកាក់នឹងបង់ថ្លៃឱ្យមេធាវី និងតម្លៃផ្សេងៗដែលពួកគេត្រូវបានគេស្នើសុំឱ្យបង់។*

*អ្នកជាប់ពន្ធនាគារជនជាតិដើមភាគតិចម្នាក់បានប្រាប់យើងថា ប្រពន្ធរបស់គាត់ត្រូវលក់ទ្រព្យសម្បត្តិរបស់គ្រួសារទាំងអស់ (ក្របី ២ក្បាល និងដីធ្លី) ដើម្បីមានលុយកាក់សម្រាប់ចំណាយលើដំណើរការក្តីរបស់គាត់។ គាត់មានកូន ៨នាក់ ហើយឥឡូវនេះ គាត់គ្មានទ្រព្យសម្បត្តិអ្វីទៀតដើម្បីចិញ្ចឹមគ្រួសារគាត់ទេ។ នៅដំណាក់កាលដំបូង គាត់ត្រូវបានរកឃើញ*

---

[១៤៥] ក្រុមការងាររួមជាមួយសមាជិកក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើទស្សនកិច្ចសិក្សា និងចូលពិនិត្យមើលស្ថានភាពពន្ធនាគារនៅខេត្តរតនៈគីរី នៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៥។ នៅទីនោះ ក្រុមការងារក៏បានសម្ភាសជាមួយពិរុទ្ធជន ក៏ដូចជាប្រធាន និងអនុប្រធានពន្ធនាគារ។ មួយថ្ងៃមុនចូលទៅពិនិត្យមើលស្ថានភាពពន្ធនាគា ក្រុមការងារបានសម្ភាសជាមួយប្រធានតុលាការ និងព្រះរាជអាជ្ញា។

ថាគ្មានទោសទេ ដោយសារខ្វះភស្តុតាង ប៉ុន្តែព្រះរាជអាជ្ញា បានធ្វើបណ្តឹងឧទ្ធរណ៍ ។ គាត់បានជាប់នៅក្នុងពន្ធនាគារអស់រយៈពេល ១ឆ្នាំ ដោយគ្មានទោស ។ សាលាឧទ្ធរណ៍ឋិតនៅក្នុងទីក្រុងភ្នំពេញ ដែលត្រូវចំណាយពេល ១៥ម៉ោងក្នុងការធ្វើដំណើរពីខេត្តរតនៈគីរី ប៉ុន្តែគ្រួសាររបស់គាត់ គ្មានធនធានដើម្បីនឹងធ្វើដំណើរ និងស្វែងរកការការពារតាមផ្លូវច្បាប់ទេ ។

*ស្ថានភាពរបស់អ្នកជាប់ពន្ធនាគារ*

អ្នកជាប់ពន្ធនាគារ ឋិតនៅពេញមួយថ្ងៃក្នុងបន្ទប់របស់ពួកគេ ដែលមានគ្នា ១៥នាក់ ។ អ្នកជាប់ពន្ធនាគារមានតែប៉ុន្មាននាទីប៉ុណ្ណោះក្នុងមួយថ្ងៃ ដើម្បីងូតទឹក និងឱ្យចេញក្រៅបន្ទប់ ។ ក្រៅពីនោះពួកគេត្រូវធ្វើអ្វីផ្សេងៗទៀត នៅក្នុងស្បោងផ្លាស្ទិកនៅជ្រុងមួយនៃបន្ទប់ ។

អ្នកជាប់ពន្ធនាគារមានសភាពស្លេកស្លាំងដោយសារខ្វះពន្លឺព្រះអាទិត្យ ហើយស្ទើរតែទាំងអស់គ្នារអ៊ូនឹងជម្ងឺប្រភេទខ្លះដូចជាកន្ទួលរមាស់លើស្បែក ឬស្គីកខ្លួន ។ ប្រធានពន្ធនាគារយល់ថា បញ្ហាចម្បងដែលអ្នកជាប់ពន្ធនាគារទទួលរងគឺជម្ងឺផ្លូវចិត្ត ។ ពួកគេមិនបានមានឱកាសរៀនសូត្រ ឬធ្វើពលកម្មអ្វីទេ ។

នៅក្នុងបន្ទប់ មិនមានដាក់ឱ្យដាច់ពីគ្នារវាងអនីតិជន និងមនុស្សពេញវ័យ អ្នកជាប់ពន្ធនាគារដោយការជាប់ឃុំបណ្តោះអាសន្ន និងទណ្ឌិត ជនល្មើសជាប់ពីបទល្មើសតូចតាច និងជនជាប់ពីបទល្មើសធ្ងន់ធ្ងរ ។

អ្នកជាប់ពន្ធនាគារទទួលបានអាហារពីរពេល ។ អនុប្រធានពន្ធនាគារបានពន្យល់ប្រាប់ថា ពន្ធនាគារខ្វះខាតធនធាន ។ គ្មានបទបញ្ញត្តិណាចែងពីការមកសួរសុខទុក្ខ (ពេលវេលា និង វិធាន) ។ អ្នកជាប់ពន្ធនាគារខ្លះទៀត មកពីខេត្តផ្សេងក្រៅពីរតនៈគីរី ។ មានអ្នកជាប់ពន្ធនាគារម្នាក់មកពី ខេត្តមណ្ឌលគីរី ដែលមិនធ្លាប់មានអ្នកមកសួរសុខទុក្ខទេ ដោយសារតែឆ្ងាយពីស្រុកកំណើតរបស់ខ្លួនពេក ។ យោងតាមបទសម្ភាសន៍ជាមួយអ្នកជាប់ពន្ធនាគារ និងអ្នកមកសួរសុខទុក្ខ អ្នកមកលេងត្រូវបង់លុយមួយម៉ឺនរៀល (២.៥ ដុល្លារអាមេរិក) ដើម្បីចូលទៅក្នុងពន្ធនាគារក្នុងមួយលើក និង ២.០០០ រៀល (០.៥ ដុល្លារ អាមេរិក) សម្រាប់យកម្ហូបទៅឱ្យអ្នកជាប់ពន្ធនាគារ ។

មានបន្ទប់ពិសេសក្នុងពន្ធនាគារចំនួន ៥បន្ទប់ដែលជាបន្ទប់ងងឹត ហើយមានគ្នា ២ ទៅ ៣ នាក់ ។ អនុប្រធានពន្ធនាគារប្រាប់យើងថា បន្ទប់ពិសេសទាំងនោះសម្រាប់ដាក់: ១-អ្នកជាប់ពន្ធនាគារថ្មី១ "រហូតពួកគេត្រូវបានទទួលឱ្យនៅក្នុងពន្ធនាគារ ហើយ ២-សម្រាប់អ្នកដែលធ្វើបាបអ្នកដទៃ ឬធ្វើបាបខ្លួនឯង ។ អនុប្រធានពន្ធនាគារបានប្រាប់យើងថា គាត់គឺជាអ្នកដែលសម្រេចពីពេលវេលាលើអ្នកជាប់ពន្ធនាគារត្រូវនៅក្នុងបន្ទប់ងងឹតទាំងនោះយូរប៉ុណ្ណា : "វាអាចប្រើពេលច្រើនខែ ឬអាចដល់ ២ឆ្នាំ" ។

***ស្ត្រីនៅក្នុងពន្ធនាគារៈ ការឆ្លុះបញ្ចាំងពីអំពើហិង្សាផ្អែកយេនឌ័រ***

នៅក្នុងពន្ធនាគារ យើងឃើញមាន ស្ត្រី ៣ នាក់ :

១- អនីតិជនអាយុ ១៦ឆ្នាំ មិនមែនជាជនជាតិដើមភាគតិច ដែលបានទៅនៅខេត្តរតនៈគីរី ដើម្បីធ្វើការជាមួយគ្រួសារនាង ។ នាងបានប្រាប់យើងខ្ញុំថា នាងត្រូវជាប់ទោស ៥ឆ្នាំក្នុងពន្ធនាគារពីបទបង្ករបួសស្នាម ។ យោងតាមច្បាប់ព្រហ្មទណ្ឌ ដោយសារនាងជាអនីតិជនអាយុតិចជាង ១៨ឆ្នាំ នាងគួរទទួលទោសត្រឹមពាក់កណ្តាលនៃទណ្ឌកម្មប៉ុណ្ណោះ ប៉ុន្តែនាងទទួលទោសអតិបរមាសម្រាប់បទបង្ករបួសស្នាម ។ មិនមានមេធាវី ដែលការពាររឿងក្តីរបស់នាងទេ ។

២- ស្ត្រីម្នាក់ដែលមានផ្ទៃពោះ ៨ខែ ដែលជាប់ពន្ធនាគារ ១ខែដោយគ្មានការជម្រះក្តី ។ ឪពុករបស់ក្មេងក្នុងពោះបានបោះបង់គាត់ចោល ដូច្នេះគាត់កំពុងរកជំនួយ ព្រោះគាត់មានកូនម្នាក់ទៀតនៅក្រៅ ។ គាត់ត្រូវបានជាប់ចោទពីការបាន

ទទួលទូរស័ព្ទដែលគេលួច ។ គាត់និយាយថា នគរបាលបាននាំគាត់មកដាក់ពន្ធនាគារផ្ទាល់ ហើយគាត់មិនទាន់បានជួប ចៅក្រមទេ ។ ទោះបីគាត់ត្រូវបានគេរកឃើញថាមានទោស គាត់នឹងត្រូវផ្តន្ទាទោសតិចជាងមួយឆ្នាំក្នុងពន្ធនាគារ ហេតុដូច្នេះ គាត់អាចមានសិទ្ធិដើរចេញដោយសេរី ដោយពុំចាំបាច់មានសវនការទេ ព្រោះគាត់បានទទួលទោសទណ្ឌរួច ហើយ ។ ទោះជាយ៉ាងណាក្តី គាត់ក៏គ្មានមេធាវីតំណាងដែរ ។

៣- ស្ត្រីម្នាក់ជាប់ចោទពីអំពើឃាតកម្មគិតទុកជាមុន ។ គាត់បានរៀបការនឹងមន្ត្រីនគរបាលម្នាក់ ដែលធ្លាប់វាយធ្វើបាប គាត់ ហើយមានសាហាយស្មន់ ។ ស្ត្រីបានខឹងយ៉ាងខ្លាំង និងបានសម្លាប់សាហាយរបស់ប្តីខ្លួន ។ ឥឡូវគាត់កំពុងនៅក្នុង មន្ទីរឃុំឃាំង ហើយប្តីគាត់បានរៀបការជាមួយប្អូនស្រីរបស់សាហាយខ្លួន ។ គាត់និយាយថា គាត់ត្រូវបានដាក់ទោស ជាប់ពន្ធនាគារចំនួន ១៥ឆ្នាំ ។

## ៥. ការរំលោភសិទ្ធិសង្គម និងការរំលោភអំណាច

នៅក្នុងសិក្ខាសាលា បទសម្ភាសន៍ និងក្នុងការស្ទង់មតិរបស់ IRL ក្រុមគោលដៅត្រូវបានសួរអំពី បញ្ហាចម្បងក្នុងសង្គម និងវិវាទដែលពួកគេបានជួបប្រទះ ។ ការស្ទង់មតិរបស់ IRL បានផ្តោតលើ ក្រុមគោលដៅចំនួន ៤ (អាជ្ញាធរផ្លូវការ អាជ្ញាធរឃុំស្ត្រី និងជនជាតិភាគតិច[១៤៦]) ហើយបានចោទសួរអំពីបញ្ហាចម្បង ក្នុងសង្គមដែលពួកគេជួបប្រទះ ។ ក្រុមគោលដៅទាំងនេះត្រូវបាន សាកសួរ នៅក្នុងខេត្តចំនួន ៤ (កំពង់ឆ្នាំង កំពង់ស្ពឺ មណ្ឌលគិរី និងសៀមរាប) ។ ចម្លើយជាញឹកញាប់ដែលបានផ្តល់មកមាន : ១- ភាពក្រីក្រ ២- វិវាទដីធ្លី ៣- សុខភាពសាធារណៈ ៤- បំណុល និង ៥- ការរំលោភសិទ្ធិមនុស្ស ។ បញ្ហាបន្ទាប់បន្សំផ្សេងៗ ទៀតមានដូចជា ៦- បទល្មើស ៧- អំពើពុករលួយ និង ៨- លំនៅដ្ឋាន ។

**តារាងសរុបរួមស្តីពីបញ្ហាជាចម្បងៗរបស់សង្គម តាមរយៈការស្ទង់មតិរបស់ IRL :**

| បញ្ហាចម្បងរបស់សង្គម | ភាពញឹកញាប់ (ចំនួនដង) | កម្រិត ឬលំដាប់នៃបញ្ហា | ការយល់ឃើញថា អាចជារឿងក្តីបាន |
|---|---|---|---|
| ភាពក្រីក្រ | ៤/៤នៃក្រុមដែល ពិគ្រោះ | ទី១ (៣ក្រុម), ទី២ (១ក្រុម) | ដោយមិនផ្ទាល់ |
| អំពើហិង្សាក្នុងគ្រួសារ (ការយល់ឃើញរបស់ស្ត្រី) | ១ | ទី២ | អាចបានខ្លះ |
| វិវាទដីធ្លី | ៤/៤ | ទី២ (២ក្រុម),ទី៣ (១ក្រុម) ទី៤(១ក្រុម) | អាចបាន |
| សុខភាពសាធារណៈ | ៣/៤ | ទី២ (១ក្រុម) ទី៣ (១ក្រុម) ទី៤ (១ក្រុម) | មិនអាចបាន |
| បំណុល | ៣/៤ | ទី៣ (២ក្រុម), ទី៤ (១ក្រុម) | អាចបាន |
| រំលោភសិទ្ធិមនុស្ស | ៣/៤ | ទី៤ (១ក្រុម), ទី៥ (ក្រុម) | អាចបានខ្លះ |
| បទល្មើស | ១/៤ | ទី១ (១ក្រុម) | អាចបាន |
| អំពើពុករលួយ | ១/៤ | ទី៥ (១ក្រុម) | កម្រ |
| លំនៅដ្ឋាន | ១/៤ | ទី៥ (១ក្រុម) | មិនអាចបាន |

[១៤៦] នៅក្រោមផ្លាកថា "ជនជាតិភាគតិច" ការស្ទង់មតិ IRL បានរាប់បញ្ចូលជនជាតិដើមភាគតិចថាជាអន្តប្រវេសន៍តាំងពីបុព្វជន (វៀតណាម និងជនជាតិភាគតិច ដទៃទៀត) នៅក្នុងខេត្តចំនួន ៤ ។ នៅក្នុងខេត្ត មណ្ឌលគិរី អ្នកដែលត្រូវបានគេសម្ភាស ភាគច្រើនជាជនជាតិដើមភាគតិច ។

ទស្សនៈអំពីបញ្ហាផ្សេងៗដែលពាក់ព័ន្ធ គឺមានលក្ខណៈប្រែប្រួលអាស្រ័យទៅលើក្រុមអ្នកឆ្លើយ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ៖

តារាង ៖ការឆ្លើយតបរបស់ក្រុមគោលដៅ ទៅលើបញ្ហាចម្បងៗទាំងប្រាំ-ការស្ទង់មតិរបស់ IRL ៖




ការស្ទង់មតិរបស់ IRL បានចោទសួរទៅស្ត្រីថា "អ្វីជាបញ្ហាចម្បងដែលអ្នកបានទទួលរងគ្រោះ ក្នុងនាមជាស្ត្រី?" ក្នុងករណីជាទូទៅ គឺភាពក្រីក្រ បន្ទាប់ពីអំពើហិង្សាក្នុងគ្រួសារ។

ឥឡូវ យើងនឹងធ្វើការវិភាគពីបញ្ហាទាំងឡាយដែលត្រូវបានចាត់ទុកថាជា "បញ្ហាសង្គម" ប៉ុន្តែមិនមែនជារឿងក្តី។

### ភាពក្រីក្រ កង្វះខាតសុខភាពសាធារណៈ ផ្ទះសំបែង ការអប់រំ

យោងតាមការស្ទង់មតិរបស់ IRL ស្ត្រី ជនជាតិភាគតិច និងអាជ្ញាធរឃុំចាត់ទុកថា ភាពក្រីក្រ ជាបញ្ហាចម្បងក្នុងសង្គម នៅមុនវិវាទដីធ្លី និងសុខភាពសាធារណៈ។ មន្ត្រីតុលាការយល់ថា ភាពក្រីក្រ គឺជាបញ្ហាចម្បងសំខាន់ទីពីរ បន្ទាប់ពីបទល្មើស។ ភាពក្រីក្របានជះឥទ្ធិពលដល់ ៨៥% នៃប្រជាពលរដ្ឋនៅតាមជនបទ។ វាជារឿងបញ្ជាក់ច្បាស់ណាស់ថា ហេតុអ្វីបានជាប្រជាពលរដ្ឋនៅតាមជនបទយល់ថា ភាពក្រីក្រ ជាបញ្ហាក្នុងសង្គមដែលចម្បងជាងគេ។ ភាពក្រីក្រមិនត្រឹមតែត្រូវបានគេយល់ថា ជាស្ថានភាពក្នុងសង្គមទេ តែវាជា *បញ្ហា* មួយ ឬស្ថានភាពមិនមានយុត្តិធម៌ ដែលមិនមានការបំពេញដល់តម្រូវការជាមូលដ្ឋានរបស់មនុស្ស ដូចជា ម្ហូបអាហារ សុខភាព ផ្ទះសំបែង ការអប់រំ សំលៀកបំពាក់[១៤៧]។ ភាពក្រីក្រ គឺជាបរិស្ថានសង្គមមួយ ដែលនាំឱ្យវិវាទផ្សេងៗរវាងបុគ្គលបានកើតឡើង[១៤៨]។

---

១៤៧ បើគិតដល់ស្ថានភាពនេះ ការកាត់បន្ថយភាពក្រីក្រ គឺជាគោលដៅមួយក្នុងចំណោមគោលដៅផ្សេងៗទៀតនៃដំណើរការ ធ្វើកំណែទម្រង់សព្វថ្ងៃ ប៉ុន្តែនៅមានផ្លូវដ៏វែងឆ្ងាយដើម្បីនឹងកែប្រែស្ថានភាពនេះ។ រាជរដ្ឋាភិបាលកម្ពុជា ៖ *យុទ្ធសាស្ត្រជាតិ កាត់បន្ថយភាពក្រីក្រ* (NPRS) ភ្នំពេញ ឆ្នាំ ២០០២។

១៤៨ ទោះបីជាវិវាទតូចតាចជាបញ្ហាដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលតិច។ រឿងវិវាទខ្លះមានតម្លៃជាប្រាក់ត្រឹមតែ ១ ឬ ២ ដុល្លារប៉ុណ្ណោះ តែចំនួន ១ ឬ ២ ដុល្លារនេះគឺមានតម្លៃស្មើនឹងប្រាក់ចំណូលប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅតាមជនបទ។

**សុខភាពសាធារណៈ ៖** កង្វះខាតការទទួលបានសុខភាពសាធារណៈ ជាបញ្ហាចម្បងក្នុងសង្គមមួយទៀត ដែលបានលើកឡើងដោយជនជាតិភាគតិច នៅក្នុងការស្ទង់មតិរបស់ IRL (ថាជាបញ្ហាចម្បងទីពីរ បន្ទាប់ពីភាពក្រីក្រ) ក៏ដូចជាអាជ្ញាធរឃុំ និងស្ត្រីផងដែរ។ កង្វះការទទួលបានសុខភាពសាធារណៈនេះ មានទំនាក់ទំនងផ្ទាល់នឹងភាពក្រីក្រ។ អ្នកក្រីក្រមានការលំបាកក្នុងការទទួលបានសេវាសុខភាពនៅក្នុងប្រទេស។ សេវាសុខភាពពិបាកក្នុងការរក ហើយមានតម្លៃខ្ពស់។ កង្វះខាតនៃសេវានេះនាំឱ្យមានអត្រាមរណភាពរបស់មាតា និងទារកខ្ពស់[១៤៩]។ រដ្ឋធម្មនុញ្ញបានធានាដល់សុខភាពប្រជាពលរដ្ឋ និងផ្ដល់ឱ្យដោយឥតគិតថ្លៃលើការពិនិត្យមើលជម្ងឺជូនអ្នកក្រីក្រ។ ក្នុងការអនុវត្តជាក់ស្តែង មន្ទីរពេទ្យនានាគិតតម្លៃសូម្បីចំពោះការពិនិត្យសុខភាព[១៥០]។ តម្រូវការជាមូលដ្ឋាន ដូចជាសុខភាពជាដើម មិនត្រូវបានពេញចិត្តពីសំណាក់ប្រជាពលរដ្ឋភាគច្រើន ដែលមានអត្រាចំណូលទាបជាងមួយដុល្លារក្នុងមួយថ្ងៃទេ។ ជាទូទៅ ប្រជាពលរដ្ឋមិនបានដឹងថាពួកគាត់មានសិទ្ធិ ទទួលបានការពិគ្រោះដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យទេ។ សម្រាប់អ្នកក្រីក្រ ការទទួលបានការថែទាំសុខភាពគឺជា *បញ្ហាសង្គម* ប៉ុន្តែមិនមែនជា *ព្រឹត្តិការណ៍ដែល អាចជារឿងក្តីបាន* ទេ។ ពួកគេមិនប្រើមធ្យោបាយផ្លូវច្បាប់ដើម្បីអនុវត្ត សិទ្ធិទទួលបានសុខភាពទេ។

| |
|---|
| **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ (ធ្វើវិសោធនកម្មនៅឆ្នាំ ១៩៩៩)** |
| (សិទ្ធិទទួលបានសេវាសុខភាព) |
| មាត្រា ៧២ : **សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺ និងព្យាបាលជម្ងឺ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យគិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ។ រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ។** |

**ជនជាតិភាគតិច** តាមការស្ទង់មតិរបស់ IRL **បញ្ហាក់ថាលំនៅដ្ឋាន** ក៏ជាបញ្ហាចម្បងមួយផងដែរក្នុងសង្គម។ បញ្ហានេះក៏ជាប់ពាក់ព័ន្ធទៅនឹងភាពក្រីក្រផងដែរ។ ការខ្វះខាតលំនៅដ្ឋានមិនបានក្លាយជារឿងក្តីទេ ប៉ុន្តែវិវាទដែលទាក់ទងនឹងលំនៅដ្ឋានគឺជារឿងក្តី។

**សិទ្ធិទទួលការអប់រំ:** កង្វះសិទ្ធិទទួលបានការអប់រំ ត្រូវបានរៀបរាប់ដោយក្រុមស្ត្រីថាជាបញ្ហាចម្បងមួយ ដែលពួកគេជួបប្រទះ។ បញ្ហានេះទាក់ទងនឹងភាពក្រីក្រ ហើយវាមានភាពធ្ងន់ធ្ងរនៅតំបន់ជនបទ និងសម្រាប់ស្ត្រី។ អត្រានៃភាពមិនចេះអក្សរមានកម្រិតខ្ពស់ ក្នុងចំណោមស្ត្រី ជាងក្នុងចំណោមបុរស។

ស្ថានភាពសង្គមទាំងអស់ដែលបានលើកមកខាងលើ (ភាពក្រីក្រ កង្វះខាតការទទួលបានសេវាសុខភាព អប់រំ និងលំនៅដ្ឋាន) ត្រូវបានយល់ដោយអ្នកទាំងអស់ថាជាបញ្ហាសង្គម ហើយមិនបានយល់ថា ជាភាពខ្វះខាតសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌ឡើយ។ នេះដោយសារតែការខ្វះខាតនៃការយល់ដឹងពីសិទ្ធិ។ រដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្សដែលបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា នៅតែមិនទាន់បានដឹងឮ ដោយប្រជាពលរដ្ឋភាគច្រើននៅឡើយ។

---

[១៤៩] យោងតាមរបាយការណ៍របស់ក្រសួងសុខាភិបាល ប្រទេសកម្ពុជាទទួលរងនូវអត្រាទារកស្លាប់យ៉ាងខ្ពស់គឺ ១២៥/១០០០នាក់ (ក្នុងឆ្នាំ១៩៩៩) ហើយអត្រាមាតាស្លាប់មានប្រមាណ ៤៧៣/១០០ ០០០ នាក់។ រីឯអត្រាស្លាប់ដោយជំងឺរបេង ក៏ខ្ពស់ណាស់ដែរ។ ដកស្រង់ចេញពី : អង្គការ Jica Cambodia: *Health Sector Development,* គេហទំព័រ : http://www.jica.org.kh/Health%20Sector%20Development.htm (ថ្ងៃចូលមើល: ខែមេសា ២០០៥)

[១៥០] អនុប្រធានតុលាការខេត្តរតនៈគីរី បានមានប្រសាសន៍ប្រាប់ក្រុមការងារយើងថា នៅក្នុងរឿងក្តីមួយចំនួន នៅពេលអ្នកមកប្តឹងជាជនក្រីក្រ ដោយមានចំណាររបស់ប្រធានភូមិបញ្ជាក់ថា បុគ្គលនោះពិតជាក្រីក្រមែន ករណីនេះ មន្ទីពេទ្យជួយពិនិត្យ និងធ្វើកោសល្យវិច្ច័យដោយឥតគិតថ្លៃ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ (ធ្វើវិសោធនកម្មនៅឆ្នាំ ១៩៩៩)

**(សិទ្ធិទទួលការអប់រំ)**

មាត្រា ៤៨ :

- រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្ដីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារ ក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារ ប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។
- រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយណាដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

**(សិទ្ធិទទួលការអប់រំដោយឥតគិតថ្លៃ)**

មាត្រា ៦៥ : រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវ ចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប (.....) ។

មាត្រា ៦៨ : រដ្ឋផ្ដល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈ សម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ។ រដ្ឋជួយផ្សព្វផ្សាយនិងលើកតម្កើងសាលាបាលី និងពុទ្ធិកសិក្សា (......) ។

ការអនុវត្តសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌ អាចត្រូវបានធ្វើជាដំណាក់កាលៗ ឬភ្លាមៗ។ គេចាត់ទុកថាធ្វើជាដំណាក់កាលៗ នៅពេលដែលមានភាពចាំបាច់ដែលរដ្ឋត្រូវចាត់វិធានការរយៈពេលយូរៈ ដូចជា ការសាងសង់សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព ជាដើម។ ការយល់ដឹងពីសិទ្ធិមានសារៈសំខាន់ក្នុងការ លើកដម្កើងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការអភិវឌ្ឍសង្គមតាមបែបលទ្ធិប្រជាធិបតេយ្យ។ វាក៏ជាការចាំបាច់ក្នុងការបង្កើតយន្តការ ដើម្បីអនុវត្តសិទ្ធិសង្គម ដូចជាសិទ្ធិទទួលបានការអប់រំ សុខភាព ដីធ្លី និងមធ្យោបាយ ក្នុងការរស់នៅ។ កង្វះយន្តការប្រជាធិបតេយ្យនិងជាក់លាក់ទាំងនេះ អាចធ្វើឱ្យមានការតវ៉ានៅក្នុងសង្គម ដែលអាចក្លាយជារឿងហិង្សា។

ការអនុវត្តសិទ្ធិសង្គមតម្រូវឱ្យមានការអនុវត្តវិធានការនយោបាយ និងសេដ្ឋកិច្ច ដូចជាកសាង មន្ទីរពេទ្យ សាលារៀន ។ល។ និង ។ល។ រដ្ឋត្រូវតែអនុវត្តសិទ្ធិទាំងនេះជាដំណាក់កាលៗ។ គេមិនត្រូវនៅស្ងៀម ឬចាត់វិធានការដើរថយក្រោយទេ (ដូចជាការកាត់បន្ថយថវិកាសម្រាប់ការអប់រំ សាលារៀន ។ល។)។ នៅក្នុងស្ថានភាពបែបនេះ ការអនុវត្តសិទ្ធិទាំងអស់នេះ មិនសមស្របសម្រាប់ការសម្រេចភ្លាមៗតាមផ្លូវតុលាការទេ។ នៅក្នុងស្ថានភាពផ្សេងទៀត វាអាចមានលទ្ធភាពទាមទារឱ្យអនុវត្តដោយផ្ទាល់នូវសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌។ ប្រជាពលរដ្ឋអាចប្ដឹងទៅតុលាការដើម្បីអនុវត្តសិទ្ធិទាំងនោះ។ ឧទាហរណ៍ ក្នុងករណីដែលមានមន្ទីរពេទ្យ ប៉ុន្តែអ្នកក្រីក្រត្រូវបានគេបដិសេធមិនឱ្យទទួលការពិនិត្យ ដោយឥតគិតថ្លៃ ឬប្រសិនបើមានសាលារៀនរដ្ឋ ប៉ុន្តែសិស្សត្រូវបានគេមិនលើកទឹកចិត្តឱ្យទៅរៀន ដោយត្រូវបង់ប្រាក់ដើម្បីចូលរៀនជាដើម។

តារាង ៖ ផ្ទះបញ្ចាំងអំពីការអនុវត្តសិទ្ធិខាងសេដ្ឋកិច្ចសង្គម និងវប្បធម៌




ក- អំពើពុករលួយ

ការសូកប៉ាន់ត្រូវបានគេប្រាប់ថា ជារឿងកើតមានឡើងញឹកញាប់ និងរីករាលដាលក្នុងការផ្តល់សេវា សាធារណៈមួយចំនួនដូចជាការអប់រំ (នៅតាមសាលា) សុខភាព យុត្តិធម៌ជាដើម ។ ការសូកប៉ាន់ក៏កើតមានខ្ពស់ ដែរនៅក្នុងដំណើរការរដ្ឋបាលផ្សេងៗនៃការិយាល័យរបស់រដ្ឋ (ដូចជា ការបង់ថ្លៃនានា សម្បទាន ការចុះបញ្ជីអគ្រានុកូលដ្ឋាន ការទទួលបានការងារ)[១៥១] ។ អ្នកដែលគេសម្ភាសន៍មួយចំនួនបានប្រាប់ថា ពួកគេត្រូវបានគេសុំឱ្យ បង់ថ្លៃមួយចំនួន (ក្រៅច្បាប់) ដើម្បីចូលទៅសួរសុខទុក្ខ ឬផ្តល់ម្ហូបទៅឱ្យអ្នកជាប់ពន្ធនាគារ ។ ទោះបីជាប្រជាពលរដ្ឋគិតថាវាជាបញ្ហាធ្ងន់ធ្ងរ តែបណ្តឹងលើអំពើពុករលួយនៅមុខតុលាការមិនមានច្រើនទេ ដោយសារតែខ្លាចពាក់ព័ន្ធ ថាខ្លួនជាអ្នកសូក គេបារម្ភថានឹងលែងទទួលបានសេវាប្រសិនបើគេប្តឹង ការភ័យខ្លាចចំពោះការសងសឹក ភាពគ្មានទំនុកចិត្តថាបណ្តឹងរបស់ពួកគេបានឈ្នះប្រសិនបើតវ៉ា និងមានទំនាក់ទំនងអវិជ្ជមានរវាងតម្លៃនិងប្រយោជន៍[១៥២] ។ ប្រជាពលរដ្ឋថែមទាំងគិតថា មន្ត្រីរាជការដែលសុំលុយ(ខុសច្បាប់)ទាំងនេះ គឺដោយសារតែប្រាក់ខែរបស់គេទាប ។

ក្រមព្រហ្មទណ្ឌបានចែងពីបទល្មើសពុករលួយ ប៉ុន្តែមានរឿងក្តីពីអំពើពុករលួយតិចតួចណាស់ ដែលបានដាក់ពាក្យប្តឹងនៅមុខតុលាការ ។ នេះគឺជាគម្លាតមួយក្នុងចំណោមគម្លាតដែលធំបំផុត រវាងតម្រូវការយុត្តិធម៌ជាសក្តានុពល និងតម្រូវការយុត្តិធម៌ជាក់ស្តែង ដោយសារប្រជាពលរដ្ឋមិនបានគិតដល់ការដាក់ពាក្យបណ្តឹងជាផ្លូវការ អំពីរឿងពុករលួយទេ ។

[១៥១] របាយការណ៍សិទ្ធិមនុស្សជាច្រើន បានបង្ហាញពីបញ្ហាដែលកំពុងរីករាលដាល (របាយការណ៍ ADHOC ឆ្នាំ ២០០៤) ។

[១៥២] ជួនកាល សូម្បីតែនៅពេលការបង់ថ្លៃកើតឡើងញឹកញាប់ តែចំនួនលុយតិចណាស់ (ដូចជាការបង់ថ្លៃដែលស្នើសុំដោយគ្រូ បង្រៀន ឱ្យសិស្សបង់ថ្លៃបន្ថែម) ម្នាក់ៗមិនបានពិចារណាក្នុងការប្តឹងទៅតុលាការអំពីរឿងទាំងនេះទេ... ក្រោយពាក្យបណ្តឹងបានទៅដល់ក្រសួងអប់រំ យុវជន និងកីឡាហើយរដ្ឋមន្ត្រីបានចាត់វិធានការដើម្បីបង្ការរឿងបង់ថ្លៃខុសច្បាប់ទាំងនេះ ប៉ុន្តែរឿងនេះមិនទាន់ទទួលបានជោគជ័យនៅឡើយ (របាយការណ៍ ADHOC ឆ្នាំ ២០០៤) ។

អ្នកតំណាងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តសៀមរាប :

*"វាជាការពិបាកក្នុងការដាក់ពាក្យបណ្ដឹងលើអំពើពុករលួយ ពីព្រោះការសូកប៉ាន់ក៏ពាក់ព័ន្ធនឹង អំពើពុករលួយដែរ"* ។

(ខែធ្នូ ឆ្នាំ ២០០៤)

## ៦. តម្រូវការយុត្តិធម៌នៅក្នុងសហគមន៍ជនជាតិដើមភាគតិច

### ក- វិវាទកើតឡើងផ្ទៃក្នុង

នៅក្នុងសហគមន៍ជនជាតិដើមភាគតិច តម្រូវការយុត្តិធម៌បានកើតឡើងចេញពីជម្លោះផ្ទៃក្នុងនានាជាច្រើនប្រភេទ ដែលកើតចេញពីអន្តរទំនាក់ទំនងនៅក្នុងសង្គមជារៀងរាល់ថ្ងៃដូចជា ជម្លោះរវាងអ្នកជិតខាង ប្ដីប្រពន្ធ ការធ្វើកសិកម្មពនេចរ ជម្លោះដោយសារការផឹកស្រា ការបង្ករបួសស្នាមការចោទប្រកាន់ពីរឿងអាបធ្មប់ និងការជេរបញ្ចោរគ្នាជាដើម ។ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច សមាជិកបាននាំយកជម្លោះរបស់ពួកគេទៅឱ្យចាស់ទុំ ដែលនិយាយភាសាផ្ទាល់ខ្លួនរបស់គេជួយដោះស្រាយ ។ ពួកគេទទួលបាននិងអាចដោះស្រាយស្ទើរ តែគ្រប់វិវាទទាំងអស់របស់ខ្លួន យោងតាមវិធាន តម្លៃ នីតិវិធី និងជំនឿរបស់គេ ។

វាជាការពិបាក ក្នុងការកំណត់ចំនួនរឿងក្ដីដែលបានទទួល និងដោះស្រាយដោយសហគមន៍ជនជាតិដើមភាគតិច ។ តែទោះជាយ៉ាងណាក្ដី តួលេខមួយដែលពួកគេបានទទួល និងដោះស្រាយស្ទើរតែគ្រប់វិវាទរបស់ពួកគេនោះ គឺដោយសារមានរឿងក្ដីរដ្ឋប្បវេណី និងព្រហ្មទណ្ឌចំនួនតិចណាស់ដែលទទួលបាននៅតុលាការ នៅក្នុងខេត្តដែលមានជនជាតិដើមភាគតិចរស់នៅ ។

### ខ- ដីរបស់ជនជាតិដើមភាគតិច

បញ្ហាដែលធ្ងន់ធ្ងរបំផុតដែលជនជាតិដើមភាគតិចកំពុងប្រឈមមុខ គឺរឿងទន្ទ្រានយកដីដោយអ្នកខាងក្រៅ[១៥៣] ។ ការទន្ទ្រានយកដីធំៗដោយអ្នកខាងក្រៅ បានកើតមានឡើងនៅ២-៣ឆ្នាំចុងក្រោយនេះ ។ ក្រោយពីផ្លូវត្រូវបានស្ថាបនារួចមកកាន់ខេត្តរតនៈគិរី និងមណ្ឌលគិរី អ្នកចំណូលថ្មីបានរើមកនៅ ហើយតម្លៃដីបានកើនឡើង ។ លទ្ធផលនៃការទន្ទ្រានយកដីដោយអ្នកខាងក្រៅ បានធ្វើឱ្យសហគមន៍ជនជាតិដើមភាគតិច ជាច្រើនបានបាត់បង់ដីរួមរបស់គេ និងបានគំរាមកំហែងដល់អត្ថិភាពរបស់ពួកគេក្នុងនាមជាប្រជាពលរដ្ឋ ។ ការទន្ទ្រានយកដីរបស់ជនជាតិដើមភាគតិច ដោយអ្នកខាងក្រៅ និងការពង្រីកដំណាំ កសិកម្មស្វាយចន្ទី ការកាប់បំផ្លាញព្រៃឈើ បានក្លាយទៅជាបញ្ហាបរិស្ថានដ៏ធ្ងន់ធ្ងរមួយផងដែរ ។

បញ្ហាធ្ងន់ធ្ងរដទៃទៀតទាក់ទងនឹងសម្បទាន មានដូចខាងក្រោម :

***ពាក្យបណ្ដឹង*** [១៥៤]

*យើងជាប្រជាពលរដ្ឋរស់នៅភូមិ ភូហាម ឃុំសែនមនោរម្យ ស្រុកអូរាំង ខេត្តមណ្ឌលគិរី ។*

*កម្មវត្ថុ : សូមប្ដឹងក្រុមហ៊ុនចិនដែលដាំដើមស្រល់នៅលើភ្នំ ជាកន្លែងដែលប្រជាពលរដ្ឋធ្លាប់ប្រើប្រាស់ ដើម្បីចិញ្ចឹមសត្វ និងជាកន្លែងដែលនៅទំនេររាប់សតវត្សរ៍មកហើយ ។ ដូចបានជម្រាបជូនខាងលើ យើងសូមសំណូមពរឱ្យលោកមេឃុំ និងលោកអភិបាលស្រុកអូរាំង ជួយយើងខ្ញុំទាមទារយកដីនោះមកវិញ ដើម្បីឱ្យយើងខ្ញុំអាចប្រើប្រាស់តាមប្រពៃណីរបស់យើងតទៅទៀត ។ ខាងក្រោមនេះជាចំនួនប្រជាពលរដ្ឋ ដែលផ្ដិតមេដៃប្ដឹងក្រុមហ៊ុន ។ ដូចបានរៀបរាប់ខាងលើនេះ*

---

[១៥៣] ឯកសាររបស់អង្គការ NGO Forum on Cambodia (2004): *Land Alienation from Indigenous Minority Communities in Rattanakiri.* Phnom Penh: NGO Forum; OHCHR (2004): *Land Concessions for economic purposes in Cambodia. A human rights perspective.* Phnom Penh: OHCHR; Ironside, Jeremy (2005): *Dap village case (Pate commune, O Yadou District).* Rattanakiri (work document). ADB (2002): Indigenous Peoples/Ethnic minorities and poverty reduction Cambodia. Manila: ADB.

[១៥៤] រឿងក្ដីដែលបានបង្ហាញនៅក្នុងសិក្ខាសាលានៅខេត្តមណ្ឌលគិរី ដោយជនជាតិភ្នង និងអភិបាលស្រុក ។ សូមមើល រឿងក្ដីលេខ G2 ក្នុងឧបសម្ព័ន្ធ២ ។

*យើងសូមឱ្យអាជ្ញាធរ ទាំងអស់ជួយយើងខ្ញុំ ដែលជាប្រជារាស្ត្រផង ។*

*- ស្នាមមេដៃចំនួន ៧៥រូប*

*- សូមអរគុណ*

*- ថ្ងៃទី ៦ កញ្ញា ២០០៤ ។*

អចលនវត្ថុសម្ូហភាពរបស់ជនជាតិដើមភាគតិចដូចមានចែងក្នុងច្បាប់ភូមិបាល

យោងតាមច្បាប់ភូមិបាលដែលបានអនុម័តក្នុងឆ្នាំ ២០០១ សហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិ ក្នុងការប្រើប្រាស់អចលនវត្ថុសម្ូហភាព[១៥៥] ។ ការកាន់កាប់ទាំងឡាយ ឋិតក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរ ប្រពៃណី និងយន្តការក្នុងការធ្វើសេចក្តីសម្រេចរបស់សហគមន៍ យោងតាមទំនៀមទំលាប់របស់ពួកគេ ( មាត្រា ២៦ ) ។ យោងតាមច្បាប់ ការវាស់វែង និងការកំណត់ព្រំ នឹងត្រូវកំណត់តាមនីតិវិធីដូចមានចែងក្នុងច្បាប់ និងអនុក្រឹត្យដែលពាក់ព័ន្ធ ( មាត្រា ២៥ ) ។ នៅពេលដែលបទដ្ឋានច្បាប់ត្រូវបានគេអនុម័តហើយនោះ សហគមន៍ មានសិទ្ធិក្នុងការថែរក្សាគ្រប់គ្រងដីសម្ូហភាព ហើយនិងសហគមន៍ខ្លួនឯង យោងតាមវិធានទំនៀមទំលាប់ របស់ពួកគេ ( មាត្រា ២៣ ) ។ ក្នុងករណីណាក៏ដោយ ច្បាប់ភូមិបាល ( ២០០១ ) បានហាមប្រាមការទន្ទ្រានយកដីរបស់សហគមន៍ជនជាតិដើមភាគតិច ពីសំណាក់អ្នកខាងក្រៅ ។ រាល់កិច្ចសន្យាទាក់ទងទៅនឹងការទន្ទ្រានយកដីសម្ូហភាពរបស់ជនជាតិដើមភាគតិច គួរតែត្រូវបានកំណត់ដោយអាជ្ញាធរថាគ្មានសុពលភាព ។

***ច្បាប់ភូមិបាល (២០០១)***

**( អចលនវត្ថុសម្ូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច)**

មាត្រា ២៥ : ដីសហគមន៍ជនជាតិដើមភាគតិច គឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និង ប្រកបរបរកសិកម្មប្រពៃណី ។ ដីសហគមន៍ជនជាតិដើមភាគតិចមិនមែនមានតែដីដែលដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបំរុងចាំបាច់ក្នុងការដូរវេនដំណាំថែមទៀត ដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល ។ ការវាស់វែងនិងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនោះត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែង ដូចដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាង និងដែលបានកំណត់តាមនីតិវិធីក្នុងមាតិកាទី ៦ នៃច្បាប់នេះ និងអនុក្រឹត្យពាក់ពន្ធ័ ។

**( កម្មសិទ្ធិរួមរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវគ្រប់គ្រងដោយអាជ្ញាធរប្រពៃណី និងមិនត្រូវទន្ទ្រានពីបុគ្គលណាមួយបានឡើយ)**

មាត្រា ២៦ : កម្មសិទ្ធិនៃអចលនវត្ថុដែលបានចែងនៅក្នុងមាត្រា ២៥ ត្រូវបានផ្តល់ដោយរដ្ឋជូនសហគមន៍ ជនជាតិដើមភាគតិចជាកម្មសិទ្ធិសម្ូហភាព ។ កម្មសិទ្ធិសម្ូហភាពរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិ ដូចកម្មសិទ្ធិឯកជនដែរ ។ ប៉ុន្តែសហគមន៍នោះគ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយ នៃកម្មសិទ្ធិសម្ូហភាព ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅបុគ្គល ឬ ក្រុមណាមួយបានឡើយ ។ ការអនុវត្តនូវសិទ្ធិជាកម្មសិទ្ធិ ទាក់ទងនឹងអចលនវត្ថុរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់ នៃការប្រើប្រាស់ដីត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសម្រេចរបស់សហគមន៍ អនុលោមតាមទំនៀមទំលាប់របស់ពួកគេ ហើយត្រូវដាក់ឱ្យនៅក្រោមច្បាប់នៃការអនុវត្តទូទៅទាក់ទងនិងអចលនវត្ថុដូចជាច្បាប់ការពារបរិស្ថានជាដើម ។ បញ្ញត្តិនៃមាត្រានេះមិនមែនជាឧបសគ្គដល់សកម្មភាពការងាររបស់រដ្ឋ ដែលជាតម្រូវការនៃប្រយោជន៍ជាតិ ឬតម្រូវការជាបន្ទាន់របស់ជាតិឡើយ ។

---

[១៥៥] នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ មានផ្នែកមួយដែលចែងយ៉ាងច្បាស់អំពី "អចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច" ( ផ្នែក ២ នៃជំពូក ៣ កម្មសិទ្ធិសហគមន៍ ) ។ ផ្នែកនេះមាន ៦ មាត្រា ។ ច្បាប់នេះបានធានាសិទ្ធិដល់បងប្អូនជនជាតិដើមភាគតិច ទាក់ទងនឹងអចលវត្ថុសហគមន៍រួមទាំង : ក-និយមន័យសហគមន៍ជនជាតិដើមភាគតិច ( មាត្រា ២៣ ) ខ-និយមន័យសមាជិកសហគមន៍ជនជាតិដើមភាគតិច ( មាត្រា ២៤ ) គ-និយមន័យដីសហគមន៍ជនជាតិដើមភាគតិច ( មាត្រា ២៥ ) ឃ-កម្មសិទ្ធិរួមរបស់សហគមន៍ជនជាតិដើមភាគតិច ( មាត្រា ២៦ ) ង-សិទ្ធិកម្មសិទ្ធិឯកត្តជនដែលនៅក្រៅសហគមន៍ ( មាត្រា ២៧ ) និង ច-បញ្ញត្តិចែងអំពីសិទ្ធិផ្តាច់មុខរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការប្រើប្រាស់អចលវត្ថុសហគមន៍ពួកគេ ( មាត្រា ២៨ ) ។ សូមមើលមាត្រាទាំងនេះក្នុងឧបសម្ព័ន្ធទី៣ ។

អន្តរហេតុទាក់ទិននឹងការទន្ទ្រានយកដីដោយអ្នកខាងក្រៅ

តាមសក្ខីកម្មដែលទទួលបានពីខេត្តរតនៈគិរី អ្នកទិញដើម្បីកេងចំណេញ អ្នកមាន យោធា និងមន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់ៗ បាននាំគ្នាទិញដីតាមរយៈឈ្មួញកណ្តាល ឬអ្នកកួកជេរនៅមូលដ្ឋាន។ ក្នុងករណីខ្លះឈ្មួញកណ្តាលគឺជាសមាជិកក្រុមប្រឹក្សាឃុំ មេភូមិ ឬអាជ្ញាធរមូលដ្ឋានផ្សេងៗទៀត ក៏ដូចជាជនជាតិដើម ភាគតិចខ្លួនឯងខ្លះដែរ។ ឈ្មួញកណ្តាលប្រើទំនាក់ទំនង និងវិធីសាស្ត្រផ្សេងៗក្នុងការចូលជិតសហគមន៍ ជនជាតិដើមភាគតិច ដើម្បីបញ្ចុះបញ្ចូលពួកគេ ឬពេលខ្លះគំរាមកំហែងពួកគេឱ្យ "លក់" ដីរបស់ពួកគេ។ ឈ្មួញកណ្តាលទាញយកអត្ថប្រយោជន៍ពីការខ្វះការយល់ដឹងពីសិទ្ធិនិងច្បាប់ ពីសំណាក់ជនជាតិដើមភាគតិច ពីសេចក្តីត្រូវការលុយកាក់របស់ពួកគេ និងពីស្ថានភាពទន់ខ្សោយរបស់ពួកគេ បើធៀបនឹងប្រជាពលរដ្ឋដទៃទៀត។ ឈ្មួញកណ្តាលខ្លះនិយាយ ទៅកាន់សហគមន៍ជនជាតិដើមភាគតិចថា : "ដោយសារពួកអ្នកឯង ជាជនជាតិចារ៉ាយ ហើយមិនមែនជាជនជាតិខ្មែរ អ្នកឯងគ្មានសិទ្ធិលើដីធ្លីនេះទេ។ រដ្ឋាភិបាលនឹងដកហូតយក ដីធ្លីពីពួកអ្នកឯងដោយគ្មានផ្តល់ប្រាក់កំរៃអ្វីទាំងអស់។ ដូច្នេះវាជាការល្អសម្រាប់ពួកអ្នកឯង បើលក់វាបាននៅមុនពេលរដ្ឋាភិបាលយកដីទាំងនេះវិញ"[១៥៦]។ រឿងនេះត្រូវបានគេនិយាយទៅកាន់សហគមន៍ជនជាតិដើមភាគតិច ក្នុងគោលបំណងដើម្បីឱ្យចាកចេញពីដីរបស់ពួកគេ សម្រាប់កសាងផ្លូវ "ដើម្បីធ្វើការអភិវឌ្ឍ"។ ការធ្វើបែបនេះ ឈ្មួញកណ្តាលរៀបចំការដោះដូរដីតាមតម្លៃទាបបំផុត ឬស្មើនឹងអំបិលមួយគីឡូក្រាមក្នុងជនជាតិដើមភាគតិចមួយគ្រួសារ ដូចក្នុងរឿងក្តីដែលបានប្រមូលឯកសារបានដោយអង្គការក្រៅរដ្ឋាភិបាល ហើយបច្ចុប្បន្នត្រូវបានដាក់ពាក្យប្តឹងទៅគណៈកម្មការសុរិយោដី[១៥៧]។

"កិច្ចសន្យា" មួយចំនួន ដែលពាក់ព័ន្ធទៅដល់ការទន្ទ្រានយកដីពីសំណាក់អ្នកខាងក្រៅ មានរួមទាំងការពង្រីកយកដីធ្លីធំជាងលើសពីអ្វីដែលជនជាតិដើមភាគតិចបានលក់ឱ្យទៅទៀត។ យោងតាមសក្ខីកម្មនានា "កិច្ចសន្យា" ទាំងនេះមិនត្រូវបានអានឱ្យជនជាតិដើមភាគតិចទាំងនោះបានស្តាប់ទេ ហើយពួកគាត់ក៏មិនបានទទួលឯកសារថតចម្លង កិច្ចសន្យាទាំងនោះណាមួយហើយក៏មិនបានជួបអ្នកទិញពិតប្រាកដដែរ។ ក្នុងករណីខ្លះអាជ្ញាធរមូលដ្ឋានប្រាប់ជនជាតិដើមភាគតិចថា ពួកគេត្រូវផ្តិតមេដៃលើក្រដាសមួយ (ដែលនោះតាមពិតជាកិច្ចសន្យាមួយ) ដើម្បីក្នុងគោលបំណងធ្វើជំរឿន។

ក្នុងករណីខ្លះទៀត មិនមានកិច្ចសន្យាអ្វីទេ។ អ្នកមានអំណាចបានមកចាប់ដណ្តើមយកដីធ្លី ពីជនជាតិដើមភាគតិចតាមរយៈវិធីផ្សេងៗ។ រឿងមួយក្នុងចំណោមរឿងក្តីបែបនេះ ឥឡូវកំពុងឋិតនៅក្រោមការដោះស្រាយ របស់គណៈកម្មការសុរិយោដី។ សហគមន៍ជនជាតិដើមភាគតិចតវ៉ាថា មន្ត្រីរដ្ឋបាលព្រៃឈើជាន់ខ្ពស់មួយរូប ក្រោយពីមានកិច្ចសន្យាមុនលើដីចំនួន ២០ហិចតា បានចាប់យកដីលើសពីនេះ៥ដង ដែលឥឡូវនេះកំពុងកាន់កាប់ដីប្រហែល ១០០ហិចតា។ រឿងក្តីនេះកំពុងតែត្រូវឋិតនៅក្នុងដៃរបស់អង្គការ។

ជាធម្មតា "អ្នកទិញ" ឬអ្នកដែលបានចាប់យកដី បានជួលកម្មករឱ្យមកកាប់ឆ្ការដី ធ្វើរបង និងដាំដំណាំ។ ជូនកាលមានការប្រឈមមុខដោយប្រើកម្លាំងដាក់គ្នា រវាងកម្មករ និងក្រុមគ្រួសារជនជាតិដើមភាគតិច ដែលចង់ការពារដីរបស់ពួកគេ។

ឧទាហរណ៍ខាងក្រោមនេះ បង្ហាញពីការកើតឡើងនៃការទន្ទ្រានយកដីជនជាតិដើមភាគតិចដោយអ្នកខាងក្រៅ សូម្បីនៅក្រោយច្បាប់ភូមិបាលបានចូលជាធរមានហើយក្តី។ ក្នុងរឿងក្តីនេះ សហគមន៍ជនជាតិដើមភាគតិចបានតវ៉ាថា ក្រុមគ្រួសាររបស់ពួកគេត្រូវបានគេឱ្យព័ត៌មានខុស និងត្រូវបានគំរាមកំហែងដោយអាជ្ញាធរមូលដ្ឋានឱ្យលក់ដី។ សហគមន៍មិនបានទទួលឯកសារ

---

[១៥៦] សម្ភាសជាមួយមេធាវីបំរើការនៅ PILAP-CLEC (នៅភ្នំពេញ ថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០០៥) និងជាមួយលោក Jeremy Ironside (នៅខេត្តរតនៈគិរី ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៥)

[១៥៧] PILAP (CLEC) និង ADHOC ។

ផតចម្លងកិច្ចសន្យានោះទេ។ ដីពិតប្រាកដត្រូវបានវាតយកដោយអ្នកទិញរហូតដល់ ១០ដង ធំជាងអ្វីដែលសហគមន៍បានព្រមលក់ឱ្យទៅទៀត។ ករណីក្នុងរឿងនេះ កំពុងតែឋិតនៅគណៈកម្មការសុរិយោដីនៅឡើយ។

*សហគមន៍ខ្លូយ៉ាជារ៍ ខេត្តរតនៈគិរី* [១៥៨]

*សហគមន៍នេះមានប្រមាណជា ៤៦ គ្រួសារ។*

*យោងតាមសក្ខីកម្មរបស់ពួកគេ មានអាជ្ញាធរមូលដ្ឋានខ្លះ (សមាជិកក្រុមប្រឹក្សាឃុំ និងមេភូមិ) បានប្រាប់សមាជិកសហគមន៍ថា រដ្ឋនឹងដកហូតយកដីពីពួកគេ ដូចនេះវាជាការល្អសម្រាប់ពួកគេដើម្បីលក់ដី។ ហេតុដូច្នេះពួកគេក៏បានយល់ព្រមលក់ដីមួយចំណែករបស់ពួកគេ ដែលនៅជាប់ផ្លូវ។ ពួកគេនៅចាំថាពួកគេបានលក់ ៥០ ហិចតា តម្លៃ ២០.០០០ ដុល្លារ។*

*ថ្ងៃមួយឈ្មួញកណ្ដាលបានមកសហគមន៍ និងបាននាំស្រាមកផង ហើយពីក្រោយនោះ ពួកគេបានសុំឱ្យប្រជាពលរដ្ឋផ្ដិតមេដៃនៅលើក្រដាសទទេមួយ។ "កិច្ចសន្យា" ត្រូវបានចុះហត្ថលេខានៅក្នុងខែ សីហា ឆ្នាំ ២០០៤ ប៉ុន្តែឈ្មួញកណ្ដាលបានសុំឱ្យសហគមន៍និយាយថាពួកគេបានលក់ដីនោះ នៅមុនឆ្នាំ២០០១។ សហគមន៍មិនបានទទួល ឯកសារថតចម្លងកិច្ចសន្យានោះទេ ហើយក៏មិនបានស្គាល់ឈ្មោះរបស់អ្នកទិញដែរ។*

*គ្រួសារនីមួយៗ ទទួលបានប្រាក់ ៤៥០ដុល្លារ ហើយគ្រួសារខ្លះទៀតទទួលបានពាក់កណ្ដាល សម្រាប់ការដែលបានប្រឆាំងមិនបានលក់ពីពេលដំបូង។ វាហាក់ដូចជាឃើញថា ឈ្មួញកណ្ដាល និងអាជ្ញាធរមូលដ្ឋានខ្លះបានទទួលពី ១.៦០០ ទៅ ៣.៥០០ ដុល្លារ។ ក្រោយមកពួកគេត្រូវបានគេមកប្រាប់ថា "កិច្ចសន្យា" នោះគឺចំនួន ៥០០ហិចតា មិនមែន ៥០ហិចតា ដូចដែលពួកគេបានយល់នោះទេ។ ឥឡូវសហគមន៍ ជួបការខ្វះខាតដីក្នុងការបន្តទំលាប់ធ្វើកសិកម្មពនេចរ ដែលជារឿងចាំបាច់សម្រាប់ចិញ្ចឹមជីវិត។*

*នៅពេលពួកគេព្យាយាមដាក់ពាក្យប្ដឹងទៅអាជ្ញាធរមួយចំនួន ពួកគេត្រូវបានប្រាប់វិញថា ពួកគេបានចុះហត្ថលេខាលក់ដីរួចហើយ គ្មានផ្លូវណាអាចធ្វើអ្វីបានឡើយ។*

*អ្នកទិញបានជួលកម្មករមកកាប់ឆ្ការដី ហើយធ្វើរបងដោយមានជំនួយពីយោធាផងដែរ។ ដំបូងមានការប្រឈមមុខដាក់គ្នារវាងកម្មករ និងគ្រួសារជនជាតិដើមភាគតិច។ អាជ្ញាធរមូលដ្ឋាន ប្រាប់ក្រុមគ្រួសារទាំងនោះថាដីរបស់ពួកគេនឹងត្រូវរដ្ឋដកហូត ឥឡូវនេះសហគមន៍ចង់ធ្វើ សវនាការជាមួយព្រះមហាក្សត្រ ដើម្បីនឹងទូលសួរទ្រង់ដោយផ្ទាល់ ថាតើអ្វីដែលគេបាននិយាយ ពិតជាដូច្នោះមែនឬយ៉ាងណា។ ក្រោយពីមានការទន្ទ្រានយកដីរបស់ពួកគេបែបនេះ សហគមន៍កំពុងរៀនស្វែងយល់ពីច្បាប់ភូមិបាល (ឆ្នាំ២០០១) និងសិទ្ធិដែលបានផ្ដល់ទៅឱ្យជនជាតិដើមភាគតិច ក្រោមទំនុកបំរុងរបស់អង្គការក្រៅរដ្ឋាភិបាលមួយ។ ឥឡូវដោយបានយល់ដឹងពីសិទ្ធិរបស់ខ្លួន សហគមន៍បានដាក់ពាក្យបណ្ដឹងទៅគណៈកម្មការសុរិយោដី ដែលរឿងនេះកំពុងរង់ចាំការដោះស្រាយ។*

[១៥៨] ក្រុមការងារសិក្សាស្រាវជ្រាវ និងសមាជិកក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ម្នាក់ បានធ្វើទស្សនកិច្ចសិក្សានៅ សហគមន៍នេះ នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០០៥។ អង្គហេតុដូចដែលបានលើកមកនេះ គឺជាករណីជាក់ស្ដែង (រឿងពិត) ដែលអះអាងនិងរៀបរាប់ប្រាប់ដោយសមាជិកសហគមន៍។

ក្នុងរឿងក្តីនៃការទន្ទ្រានយកដី របស់ជនជាតិដើមភាគតិចដោយអ្នកខាងក្រៅទាំងនេះ វាជាការបញ្ជាក់ ច្បាស់លាស់ណាស់ថា សហគមន៍ជនជាតិដើមភាគតិចមិនបានដឹងពីច្បាប់ភូមិបាល ដែលបានផ្តល់សិទ្ធិឱ្យពួកគេ ក្នុងការគ្រប់គ្រងលើអចលនទ្រព្យសម្ភូហភាព ក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរតាមបែបប្រពៃណីរបស់ខ្លួន និងយន្តការក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ពួកគេនោះឡើយ។ ប្រសិនបើពួកគេបានដឹងពីបញ្ហានេះ ពួកគេនឹងមិនបណ្តោយឱ្យទទួលរងការគំរាមកំហែងយ៉ាងខ្លាំងក្លាបែបនេះពីសំណាក់ឈ្មួញកណ្តាលនោះទេ។ វាក៏បង្ហាញច្បាស់ណាស់ដែរថា ពួកគេមិនបានដឹងថាច្បាប់ភូមិបាលបានហាមប្រាមមិនឱ្យមានការលក់អចលនទ្រព្យសម្ភូហភាព របស់ជនជាតិដើមភាគតិចទៅអ្នកខាងក្រៅ ដូច្នេះកិច្ចសន្យាលក់ដីរបស់ជនជាតិដើមភាគតិច គ្មានប្រសិទ្ធិភាពតាមផ្លូវច្បាប់ទេ ពីព្រោះកម្មវត្ថុនៃកិច្ចសន្យាមានលក្ខណៈខុសច្បាប់។ ដូចនៅក្នុងឧទាហរណ៍ខាងលើ សហគមន៍បានស្នើសុំធ្វើសវនាការជួបជាមួយព្រះមហាក្សត្រ វាបង្ហាញឱ្យឃើញនូវកង្វះខាតការយល់ដឹងពីស្ថាប័នដែលមាននៅពេលបច្ចុប្បន្ន ដើម្បីដោះស្រាយពីតម្រូវការយុត្តិធម៌របស់ពួកគេ[១៥៩]។

រឿងក្តីនៃការទន្ទ្រានយកដីរបស់ជនជាតិដើមភាគតិចដោយអ្នកខាងក្រៅផ្សេងៗទៀត មានទាក់ទងទៅនឹងសេចក្តីត្រូវការលុយកាក់ ដោយសារពួកគេទាំងនោះមិនមានមូលធន ដើម្បីអភិវឌ្ឍសហគមន៍របស់ខ្លួននៅក្នុងសេដ្ឋកិច្ចទីផ្សារ។

នៅក្នុងខេត្តមណ្ឌលគិរី មានបញ្ហាទន្ទ្រានយកដីដោយអ្នកខាងក្រៅជាច្រើនកំពុងរង់ចាំការដោះស្រាយ ហើយកម្រិតនៃការគ្រប់គ្រងរបស់ជនជាតិដើមភាគតិច មានកម្រិតទាបជាងក្នុងខេត្តរតនៈគិរី។ អ្នកចំណូលថ្មីបានកំពុងចូលមកតាំងទីលំនៅផងដែរ ក្រោយពីការកសាងផ្លូវរួចមក។ ឈ្មោះផ្សេងៗដែលសរសេរលើបន្ទះក្តារ និងព្យួរនៅលើដើមឈើកំពុងតែមាននៅតាមកូនភ្នំនានា ដែលសហគមន៍ជនជាតិដើមភាគតិចប្រើសម្រាប់កសិកម្មពនេចរ។

គ- សិទ្ធិជាក់លាក់មួយចំនួន

ប្រជាពលរដ្ឋជនជាតិដើមភាគតិចបានបង្ហាញថា មានបញ្ហាបាត់បង់វប្បធម៌ ភាសា ទំនៀមទម្លាប់ និងអាជ្ញាធរប្រពៃណីរបស់ពួកគេ។ វាហាក់ដូចជាឃើញថាមានក្រុមជនជាតិដើមភាគតិចជាច្រើន មិនបានដឹងពីបទដ្ឋានច្បាប់ដែលចែងពីការការពារសិទ្ធិរបស់ពួកគេទេ។ លើសពីនេះ ពួកគេមិនបានទៅរកស្ថាប័នណា ដើម្បីដោះស្រាយនូវតម្រូវការរបស់ពួកគេ សម្រាប់ការអនុវត្តសិទ្ធិទាំងនោះផងដែរ។ ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការគោរពវប្បធម៌ អនុវត្តជំនឿ និងប្រើប្រាស់ភាសារបស់គេបាន បើយោងតាមអនុសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។

**មាត្រា ២៧ នៃអនុសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** *(ចុះហត្ថលេខាដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា នៅថ្ងៃទី ២០ ខែមេសា ឆ្នាំ ១៩៩២)*

**ក្នុងរដ្ឋទាំងឡាយដែលជាសមាជិកនៃកតិកាសញ្ញានេះ តែងតែមានប្រជាពលរដ្ឋភាគតិចសព្វបែបយ៉ាង ទាំងក្នុងវិស័យសាសនា និងវិស័យភាសា។ មនុស្សដែលជាសមាជិកនៃសង្គមភាគតិចទាំងនេះ មានសិទ្ធិក្នុងការគោរពទំនៀមទំលាប់វប្បធម៌ខ្លួន សិទ្ធិក្នុងការគោរព និងប្រារព្ធពិធីសាសនាខ្លួន ព្រមទាំងសិទ្ធិក្នុងការប្រើប្រាស់ភាសាកំណើតរបស់ខ្លួន ទាំងនៅក្នុងសហគមន៍ខ្លួន ទាំងជាមួយសមាជិកដទៃទៀត"។**

[១៥៩] សហគមន៍ជនជាតិដើមភាគតិចដើមឡើយមិនបានដឹងអំពីអត្ថិភាពរបស់គណៈកម្មការសុរិយោដីទេ។ ពួកគេក៏ពុំបានដឹងថា ពួកគេអាចមានសិទ្ធិប្តឹងទៅតុលាការ បើសិនជាពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌដែរ។ តាមពិតអាជ្ញាធរទាំងអស់ ដែលបានទទួលលុយពីអ្នកទិញ ដើរតួជាឈ្មួញកណ្តាល បានប្រព្រឹត្តបទល្មើស (អំពើពុករលួយ)។ ហើយអ្នកទិញបានរំលោភអំណាច ដោយទាក់ទាញឱ្យបងប្អូនជនជាតិដើមភាគតិចបាត់បង់ដីធ្លីរបស់ពួកគេ តាមរយៈការទិញដូរដែលខុសនឹងច្បាប់។ អ្នកទិញបានរំលោភបំពានលើសិទ្ធិកម្មសិទ្ធិ ដោយព្យាយាមកាន់កាប់ដោយប្រើកម្លាំងលើដីធ្លីទទួលបានដោយខុសច្បាប់។ ព្រះរាជអាជ្ញាក៏អាចចាត់វិធានការដើម្បីទប់ស្កាត់ករណីនេះបានដែរ។

### ការការពារវប្បធម៌ជនជាតិដើមភាគតិច

សិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការអនុវត្តវប្បធម៌របស់ខ្លួន ការពាររបៀបរបបរស់នៅរបស់គេ ប្រពៃណី ការអនុវត្តក្នុងសង្គម ប្រព័ន្ធដើម្បីអភិរក្សនិងចម្លងវប្បធម៌ ទម្រង់នៃការរៀបចំសង្គម បទបញ្ញត្តិ នៃជីវិតសង្គម និងយន្តការសម្រាប់ធ្វើសេចក្តីសម្រេច។ ការអភិរក្សវប្បធម៌របស់ជនជាតិដើមភាគតិច ក៏មានវិធាន ប្រពៃណី និងតម្លៃសង្គមផងដែរ។

### ការការពារការប្រើប្រាស់ភាសា

ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការប្រើភាសារបស់ខ្លួនជាលក្ខណៈឯកជន នៅក្នុងក្រុមគ្រួសារ និងសហគមន៍ និងនៅទីសាធារណៈ ដូចជា សាលារៀន មន្ទីរពេទ្យ និងនៅតុលាការ។ ការការពារការប្រើប្រាស់ ភាសាជនជាតិដើមភាគតិច រួមមានសិទ្ធិក្នុងការថែរក្សា ចម្លង និងអភិវឌ្ឍភាសារបស់ជនជាតិដើមភាគតិច។ ការការពារការប្រើភាសាជនជាតិដើមភាគតិច នៅខាងក្រៅសហគមន៍ តម្រូវឱ្យមានសេវាកម្មបកប្រែផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរ ដែលផ្តល់ដោយស្ថាប័នច្បាប់ និងស្ថាប័នដទៃទៀតដែលផ្តល់សេវាសាធារណៈ។

### ការការពារការអនុវត្តជំនឿ

ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការទទួលស្គាល់ និងអនុវត្តជំនឿរបស់ខ្លួន ដែលរួមមានការការពារការចម្លង និងប្រតិបត្តិគ្រប់រូបភាព និងការការពារទីកន្លែងដែលគេអនុវត្តជំនឿរបស់ខ្លួន។ ជនជាតិដើមភាគតិច គួរតែមិនត្រូវបានគេរើសអើង រំខាន ឬដាក់ឱ្យនៅក្រៅពីការអនុវត្តសិទ្ធិមនុស្ស ដោយសារតែគេបានប្រើប្រាស់ភាសា ជំនឿ និងវប្បធម៌របស់ខ្លួននោះទេ។

ដើម្បីអនុវត្តសិទ្ធិទាំងនេះ រដ្ឋគួរសម្របសម្រួលក្នុងការផ្តល់សេវាសាធារណៈ ធ្វើឡើងជាភាសាជនជាតិដើមភាគតិច ដូចជាសេវាសុខាភិបាល និងយុត្តិធម៌ ក៏ដូចជាការអប់រំអន្តរវប្បធម៌ធ្វើឡើងជាពីរភាសា។ នៅឆ្នាំ១៩៩៧ គណៈកម្មាធិការអន្តរក្រសួង ដើម្បីអភិវឌ្ឍប្រជាពលរដ្ឋនៅតំបន់ខ្ពង់រាបបានចេញនូវសេចក្តីព្រាងមួយពី "គោលនយោបាយទូទៅសម្រាប់ការអភិវឌ្ឍប្រជាពលរដ្ឋនៅតំបន់ខ្ពង់រាប" ដែលជាលទ្ធផលនៃដំណើរការប្រឹក្សាយោបល់យ៉ាងយូរ ប៉ុន្តែវាមិនដែលត្រូវបានអនុម័តជាផ្លូវការដោយរាជរដ្ឋាភិបាលទេ។ "គោលនយោបាយទូទៅ" នោះនឹងផ្តល់នូវការការពារពិសេសមួយចំនួនដល់ ប្រជាពលរដ្ឋរស់នៅតំបន់ខ្ពង់រាប ដែលមានទាក់ទងនឹងសិទ្ធិលើដីធ្លី និងប្រើប្រាសធនធាន ការការពារវប្បធម៌ និងការអនុវត្តក្នុងសង្គម ការពិភាក្សា និងការចូលរួម។ រឿងដែលសំខាន់ៗទាំងអស់នៅក្នុងដំណើរការវិមជ្ឈការ និងការកែប្រែស្ថាប័ននៅពេលបច្ចុប្បន្ននេះ[១៦០]។ សេចក្តីព្រាងនេះ បច្ចុប្បន្នឋិតនៅក្នុងដំណើរការពិភាក្សា នៅក្នុងខេត្តជាច្រើន ដោយក្រសួងអភិវឌ្ឍន៍ជនបទ។ វាជាការសំខាន់ដែលថាគោលនយោបាយសម្រាប់ជនជាតិដើមភាគតិច ត្រូវបានគេអនុម័តដើម្បីពង្រឹងសិទ្ធិរបស់ជនជាតិដើមភាគតិច។

ដោយគិតទៅដល់ក្របខ័ណ្ឌច្បាប់ ជនជាតិដើមភាគតិចមានសិទ្ធិមួយចំនួននៅក្នុងប្រព័ន្ធយុត្តិធម៌ ដូចជាការប្រើអ្នកបកប្រែភាសា និងសិទ្ធិឱ្យមានអ្នកតំណាងច្បាប់របស់ខ្លួន។ ការដឹងឮពីសិទ្ធិទាំងនេះនៅក្នុងចំណោម ជនជាតិដើមភាគតិចមិនមានចំនួនច្រើនទេ។ រដ្ឋខកខានក្នុងការធ្វើឱ្យគេទទួលបានសិទ្ធិទាំងនេះ។

---

[១៦០] បទបញ្ញត្តិមួយចំនួន ដែលបានដកស្រង់ដោយរបាយការណ៍របស់ធនាគារពិភពលោក (ឆ្នាំ២០០៣) គឺ : "[the government] "shall promote understanding and respect of cultural diversity and ensure that Highland Peoples can practice their own cultures" (para.1); "Highland Peoples shall have the right to be fully informed about, determine the priorities for and to exercise control over their economic, social and cultural development" (para. 6); and this provision in the policy guidelines section of the document: "Highland Peoples" communities shall be given the opportunity to participate and take responsibility in all decisions regarding infrastructure projects that affect them. The affected community and persons must have agreed, after being fully informed in a language that they clearly understand, of the project and all its consequences for them and their natural enviroment, before any development project may proceed" (para.72). 13. WB-RILGP.

# ៧. តម្រូវការយុត្តិធម៌ក្នុងសង្គមជាក់ស្តែង: លក្ខណៈវិនិច្ឆ័យនៃតម្រូវការយុត្តិធម៌

តម្រូវការយុត្តិធម៌ក្នុងសង្គមជាក់ស្តែង រួមមានចំនួនសរុបនៃរឿងក្តីដែលត្រូវបានដោះស្រាយរួចរាល់ហើយ តាមរយៈភ្នាក់ងារដែលមានដើម្បីដោះស្រាយវិវាទ។ ប្រជាពលរដ្ឋអាចប្តឹងដោះស្រាយតម្រូវការយុត្តិធម៌។

## ៧.១. កម្មវត្ថុនៃរឿងក្តី និងក្របខណ្ឌច្បាប់

យោងតាមច្បាប់ ប្រជាពលរដ្ឋត្រូវបានគេកំណត់ឱ្យទៅរកផ្លូវ ឬអាជ្ញាធរមួយចំនួនដែលពួកគេត្រូវប្រើ ដើម្បីដោះស្រាយវិវាទ ដោយគិតពីកម្មវត្ថុនៃរឿងរ៉ាវនៃវិវាទ ទីកន្លែងកើតហេតុ និងតម្រូវការផ្លូវច្បាប់ផ្សេងទៀត។ ទោះជាយ៉ាងនេះក្តី ជារឿយៗកត្តាដទៃទៀតធ្វើអន្តរាគមក្នុងការសម្រេចចិត្ត ដើម្បីប្តឹងទៅអាជ្ញាធរណាមួយ ដូចជាភាពងាយស្រួលរកស្ថាប័ន ប្រពៃណី និងការយល់ដឹងផ្នែកវប្បធម៌។

- យោងតាមច្បាប់របស់កម្ពុជា ក្នុង**រឿងក្តីព្រហ្មទណ្ឌ** ប្រជាពលរដ្ឋត្រូវតែប្តឹងទៅនគរបាលយុត្តិធម៌ ឬប្តឹងទៅព្រះរាជអាជ្ញា។ ប្រសិនបើនគរបាលទទួលបានរឿងក្តីហើយពួកគេត្រូវស៊ើបអង្កេត និងបញ្ជូនរឿងក្តីមកអយ្យការ។ ព្រះរាជអាជ្ញាត្រូវធ្វើបណ្តឹងអាជ្ញាមកតុលាការ។ តែមានរឿងក្តីជាច្រើនត្រូវបានដោះស្រាយដោយការសម្រុះសម្រួលនៅចំពោះមុខនគរបាលថ្នាក់ឃុំ ស្រុក ឬខេត្ត។ រឿងក្តីព្រហ្មទណ្ឌតិចណាស់ ដែលបានទៅដល់ដៃព្រះរាជអាជ្ញា និងដល់តុលាការ។
- ក្នុង**ករណីលែងលះ** រឿងគ្រួសារផ្សេងៗ ព្រមទាំងរឿងរដ្ឋប្បវេណីមួយចំនួន ច្បាប់ចែងថាមានតែតុលាការទេ ដែលមានសមត្ថកិច្ចដោះស្រាយរឿងក្តីទាំងនេះបាន។
- សម្រាប់វិវាទដីធ្លីលើ **ដីដែលបានចុះបញ្ជីរួចហើយ** ប្រជាពលរដ្ឋត្រូវប្តឹងទៅតុលាការដើម្បីដោះស្រាយវិវាទ។
- អាជ្ញាធរស្របច្បាប់ដែលត្រូវដោះស្រាយវិវាទទាក់ទងនឹង **ដីធ្លីមិនបានចុះបញ្ជី** គឺគណៈកម្មការសុរិយោដី។ គណៈកម្មការសុរិយោដីត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០២ ហើយនៅមានប្រជាពលរដ្ឋជាច្រើនដែលមិនទាន់បានដឹងពីរឿងនេះនៅឡើយ ដូចនេះ ពួកគេដំបូងទៅរកអាជ្ញាធរមូលដ្ឋានសិន ដើម្បីដោះស្រាយវិវាទដីធ្លីនេះ។ តែជាក់ស្តែងក្រុមប្រឹក្សាឃុំ អភិបាលស្រុក និងតុលាការតែងតែបញ្ជូនជារៀងរាល់ពេលនូវវិវាទជាច្រើន ដែលទាក់ទិននឹងដីធ្លីមិនបានចុះបញ្ជី ទៅកាន់គណៈកម្មការសុរិយោដី ប្រសិនបើមានការិយាល័យសុរិយោដីនៅថ្នាក់ស្រុក។
- អង្គការសិទ្ធិមនុស្សជាច្រើន កំពុងធ្វើអន្តរាគមន៍ជួយគាំទ្រដល់ជនរងគ្រោះ ក្នុង**អំពើរំលោភបំពានលើសិទ្ធិមនុស្ស** ដូចជាការចាប់ខ្លួនខុសច្បាប់ អំពើហិង្សាក្នុងគ្រួសារ និងការចាប់យកដីធ្លី។ អង្គការទាំងនេះបានលើកទឹកចិត្តប្រជាពលរដ្ឋឱ្យប្រើមធ្យោបាយតាមផ្លូវច្បាប់ ដូចជា តុលាការ ឬការិយាល័យសុរិយោដី។
- ការទៅរកជំនួយពី **អ្នកនយោបាយ**: ប្រជាពលរដ្ឋក្នុងភូមិ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាល តែងព្យាយាមប្តឹងទៅរដ្ឋមន្ត្រី ព្រះមហាក្សត្រ និងអាជ្ញាធរនយោបាយ ដើម្បីរកយុត្តិធម៌ នៅពេលដែលនៅពីក្រោយ វិវាទមានដូចជា អ្នកនយោបាយ យោធា ឬអ្នកមានអំណាច។

តារាង៖ រឿងក្តីនានា និងផ្លូវនៃបណ្តឹងតាមច្បាប់នានា

| បញ្ហារឿងក្តី | ផ្លូវនៃបណ្តឹងតាមច្បាប់ | ស្ថាប័នដែលមាន (ទីកន្លែងរបស់ស្ថាប័ន) |
|---|---|---|
| គ្រប់រឿងក្តីព្រហ្មទណ្ឌទាំងអស់ | នគរបាល | ឃុំ ស្រុក ខេត្ត/ក្រុង |
| | ព្រះរាជអាជ្ញា | ខេត្ត/ក្រុង |
| | តុលាការ | ខេត្ត/ក្រុង |
| វិវាទលើដីធ្លីមិនទាន់ចុះបញ្ជី | គណៈកម្មការសុរិយោដី | ស្រុក ខេត្ត ជាតិ (ភ្នំពេញ) |
| វិវាទលើដីធ្លីចុះបញ្ជីរួច រឿងក្តីរដ្ឋប្បវេណី និងពាណិជ្ជកម្ម ការលែងលះ | តុលាការ | ខេត្ត (ជាន់ទីមួយ) សាលាឧទ្ធរណ៍ (ភ្នំពេញ) តុលាការកំពូល (ភ្នំពេញ) |
| វិវាទការងាររួម | ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ តុលាការ | ភ្នំពេញ |
| វិវាទតាមមូលដ្ឋានមួយចំនួន | ក្រុមប្រឹក្សាឃុំ | ឃុំ |

ទស្សនទាននៃការប្រើប្រាស់ប្រព័ន្ធទាំងនេះ

ការស្ទង់មតិរបស់ IRL បានសួរពីទស្សនៈរបស់ប្រជាពលរដ្ឋ ទាក់ទងនឹងការប្រើប្រព័ន្ធ "ផ្លូវការ" ឬ "មិនផ្លូវការ"។ ចំពោះពាក្យថា "ផ្លូវការ" ការស្ទង់មតិបានបញ្ចូល នគរបាល និងតុលាការ ហើយពាក្យថា "មិនផ្លូវការ" មានន័យសង្កត់ធ្ងន់ទៅលើអាជ្ញាធរមូលដ្ឋាន។ ចំណុចខុសគ្នាខ្លាំងរវាងការប្រើប្រាស់ "ប្រព័ន្ធយុត្តិធម៌ផ្លូវការ (នគរបាល និងតុលាការ)" ហើយនិងអាជ្ញាធរមូលដ្ឋាន គឺឋិតនៅត្រង់បញ្ហារឿងក្តីព្រហ្មទណ្ឌ និងអំពើហិង្សាក្នុងគ្រួសារ។ ជាទស្សនទូទៅ គឺថាក្នុងរឿងក្តីព្រហ្មទណ្ឌ បុគ្គលគ្រប់រូបច្រើនតែទៅរកនគរបាល និងតុលាការ នៅពេលដែលរឿងអំពើហិង្សាក្នុងគ្រួសារវិញ បុគ្គលគ្រប់រូបចូលចិត្តទៅរកអាជ្ញាធរមូលដ្ឋាន។ ឯរឿងហេតុផ្សេងៗទៀតមានលក្ខណៈស្រដៀងគ្នា។ វិវាទដីធ្លី និងការលែងលះ ហាក់ដូចជាឋិតក្នុងលំដាប់ទី២ និងទី៣ ក្នុងការប្រើប្រាស់ប្រព័ន្ធទាំងពីរស្មើគ្នា។

**សំណួរ៖ តើបញ្ហាប្រភេទណាខ្លះដែលប្រជាពលរដ្ឋប្រើប្រាស់ប្រព័ន្ធផ្លូវការ (តុលាការ នគរបាល)?**

| ការឆ្លើយតប | ភាពញឹកញាប់សរុបលើក្រុមពិភាក្សាទាំង ៥ក្រុម |
|---|---|
| ១. រឿងក្តីព្រហ្មទណ្ឌ | (៥ក្រុម/៥) |
| ២. វិវាទដីធ្លី | (៥/៥) |
| ៣. ការលែងលះ/ផ្តាច់សង្វាសគ្នា | (៥/៥) |
| ៤. អំពើហិង្សាក្នុងគ្រួសារ | (៣/៥) |
| ៥. រឿងក្តីរដ្ឋប្បវេណី | (៤/៥) |
| ៦. វិវាទមរតក | (២/៥) |
| ៧. វិវាទការងារ | (១/៥) |




តើវិវាទប្រភេទណាខ្លះដែលប្រជាពលរដ្ឋប្រើ "ប្រព័ន្ធក្រៅផ្លូវការ" (អាជ្ញាធរមូលដ្ឋាន)?

| ការឆ្លើយតប | ភាពញឹកញាប់សរុបលើក្រុមគោលដៅទាំង ៥ក្រុម |
|---|---|
| ១. អំពើហិង្សាក្នុងគ្រួសារ | (៥/៥) |
| ២. វិវាទដីធ្លី | (៥/៥) |
| ៣. ការលែងលះ/ផ្តាច់សង្វាសគ្នា | (៥/៥) |
| ៤. រឿងក្តីរដ្ឋប្បវេណី | (៥/៥) |
| ៥. វិវាទការងារ | (៣/៥) |
| ៦. វិវាទមរតក | (១/៥) |
| ៧. រឿងក្តីព្រហ្មទណ្ឌ | (១/៥) |




## ៧.២. អត្ថិភាពនៃស្ថាប័នៈ ភាពនៅជិត និងការស្គាល់ច្បាស់

ដំបូងបុគ្គលគ្រប់រូប ចូលចិត្តចង់ទៅរកស្ថាប័នដែលមាននៅជិតបំផុត។ ជាទូទៅស្ថាប័នដែលនៅជិតប្រជាពលរដ្ឋស្គាល់ច្បាស់ ចំណាយលុយតិច និងមាននីតិវិធីលឿន។ តែងតែមានទំនាក់ទំនងដោយផ្ទាល់រវាង ភាពនៅជិត ការស្គាល់ច្បាស់ ហើយនិងទំនាក់ទំនងផ្ទុយគ្នារវាងភាពនៅជិតជាមួយតម្លៃនិងពេលវេលា។ ក្នុងទំនាក់ទំនងដោយផ្ទាល់ ភ្នាក់ងារដែលនៅជិតជាងគឺមានការស្គាល់ច្បាស់ជាង។ ក្នុងទំនាក់ទំនងផ្ទុយគ្នា កន្លែងដែលភ្នាក់ងារ នៅកាន់តែឆ្ងាយកាន់តែមិនសូវស្គាល់ច្បាស់ និងត្រូវចំណាយប្រាក់កាសនិងប្រើពេលវេលាអស់ច្រើនជាង។

- **ថ្នាក់ភូមិ**: អាជ្ញាធរដែលមាននៅជិតជាងគេនៅក្នុងភូមិ គឺមេភូមិ។ មេភូមិគឺជាអាជ្ញាធរនយោបាយ មួយដែលត្រូវបានតែងតាំងដោយរដ្ឋាភិបាល ដោយគ្មានសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការដោះស្រាយវិវាទទេ។ អ្នកភូមិយកវិវាទនានា ដំបូងគេទៅរកមេភូមិ ដែលជាអាជ្ញាធរតែមួយគត់ដែលមាននៅថ្នាក់ភូមិ។
- **ថ្នាក់ឃុំ**: ភ្នាក់ងារដែលញឹកញាប់ជាងគេទីពីរ ហើយត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋ និងសម្រាប់គ្រប់បញ្ហាផងដែរនោះ គឺក្រុមប្រឹក្សាឃុំ។
- នៅថ្នាក់ឃុំ មានប៉ុស្តិ៍នគរបាល ដូចនេះប្រជាពលរដ្ឋ បានទៅរកនគរបាលញឹកញាប់ផងដែរ មិនត្រឹមតែរឿងក្តីព្រហ្មទណ្ឌប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរឿងក្តីរដ្ឋប្បវេណី អំពើហិង្សាក្នុងគ្រួសារ បំណុល ។ល។
- **ថ្នាក់ស្រុក**: នៅថ្នាក់ស្រុកមានអាជ្ញាធរដែលមាននៅទីនោះជាច្រើនៈ អភិបាលស្រុក នគរបាល និងគណៈកម្មការសុរិយោដីសម្រាប់វិវាទទាក់ទងនឹងដីធ្លី។
- **ថ្នាក់ខេត្ត**: ភ្នាក់ងារយុត្តាធិការដែលមានហើយនៅជិតជាងគេបំផុតនោះ គឺមាននៅថ្នាក់ខេត្ត។ មានតែនៅទីរួមខេត្តប៉ុណ្ណោះដែលមានតុលាការ និងព្រះរាជអាជ្ញា។ ទីរួមខេត្តឋិតនៅឆ្ងាយសម្រាប់អ្នកភូមិភាគច្រើន ដែលរស់នៅក្នុងតំបន់ជនបទ។

## ៧.៣. ការយល់ដឹងផ្នែកវប្បធម៌ និងលទ្ធភាពនៃការចរចារ

បុគ្គលគ្រប់រូបចូលចិត្តទៅរកស្ថាប័ន និងអាជ្ញាធរដែលពួកគេអាចមានលទ្ធភាពក្នុងការចរចា និងចូលរួមក្នុងការដំណើរការដោះស្រាយវិវាទ។ ដូច្នេះហើយបានជាមានចំណង់ចំណូលចិត្តយ៉ាងខ្លាំង ចំពោះអាជ្ញាធរមូលដ្ឋាន។ មូលហេតុមួយចំនួនដែលបានបង្ហាញឡើង នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ និងការស្ទង់មតិ ចំពោះមូលហេតុទាំងឡាយ ដែលនាំឱ្យពួកគេចូលចិត្តទៅរកអាជ្ញាធរទាំងនោះ មានដូចជា :

- អាជ្ញាធរមូលដ្ឋានយល់ដឹងពីប្រវត្តិនៃវិវាទនានា។
- គូវិវាទយល់ពីនីតិវិធី និងភាសានៅមូលដ្ឋាន។ អ្នកដែលក្រុមសិក្សាស្រាវជ្រាវបានសម្ភាសន៍ និងអ្នកចូលរួមក្នុងសិក្ខាសាលាបានបង្ហាញពីការលំបាកក្នុងការស្វែងយល់ពីនីតិវិធីច្បាប់ និងភាសាដែលប្រើដោយតុលាការ។
- នៅថ្នាក់មូលដ្ឋាន វាមានលទ្ធភាពក្នុងការប្រើប្រាស់ការសម្រុះសម្រួល ដើម្បីដោះស្រាយវិវាទក្នុងចំណោមអ្នកភូមិ។
- គូវិវាទស្គាល់គ្នាទៅវិញទៅមកនៅថ្នាក់មូលដ្ឋាន។
- នគរបាល ក្រឡាបញ្ជី ព្រះរាជអាជ្ញា និងចៅក្រមមានលក្ខណៈមិនគួរសម និងគំរោះគំរើយចំពោះអ្នកភូមិ។

ការប្រើចំណេះដឹងវប្បធម៌រួម និងភាសារឹតតែជារឿងសំខាន់ថែមទៀត សម្រាប់ជនជាតិដើមភាគតិច ដូចជាជនជាតិភ្នងជាដើម។ ពួកគេមានវិធានបទដ្ឋាន ទំនៀមទម្លាប់ អាជ្ញាធរ នីតិវិធី និងស្ថាប័នផ្ទាល់ខ្លួនឯង ដើម្បីគ្រប់គ្រងជីវិតសង្គមរបស់ពួកគេ និងដោះស្រាយវិវាទនានា។ ស្ថាប័នទាំងនេះគឺជាផ្នែកនៃក្របខ័ណ្ឌវប្បធម៌ ទូលំទូលាយមួយ។ ចំពោះជនជាតិភ្នង អាជ្ញាធរមូលដ្ឋានរបស់ពួកគេមានការទទួលស្គាល់ច្រើនក្នុងការធ្វើអន្តរាគមន៍ក្នុងវិវាទនានា ជាងអាជ្ញាធរមកពីខាងក្រៅ។

ក្នុងការស្ទង់មតិរបស់ IRL អ្នកត្រូវបានគេធ្វើសម្ភាសន៍បានពន្យល់ពីលក្ខណៈវិនិច្ឆ័យរបស់ពួកគេ ក្នុងការជ្រើសរើសប្រព័ន្ធមួយ ឬប្រព័ន្ធផ្សេងទៀតដូចរៀបរាប់ខាងក្រោមនេះ។

**សង្ខេបខ្លឹមសារសំខាន់ៗ** — **ខ្លឹមសារគន្លឹះ**

**អាជ្ញាធរឃុំ-សង្កាត់**

- អាជ្ញាធរឃុំ-សង្កាត់ត្រូវបានមើលឃើញថាមានភាពជឿជាក់ជាងគេ ហើយ ត្រូវទៅនឹងផ្នែកដទៃទៀតនៅប្រព័ន្ធច្បាប់។
- ប្រជាពលរដ្ឋចូលចិត្តពួកគេ ដោយសារតែពួកគេស្ថិតនៅ និង អាចរកបាននៅក្នុងតំបន់ និង ប្រើប្រាស់ការសម្រុះសម្រួលអោយត្រូវគ្នា។ ពួកគេក៏យល់ដឹងថា មានការចំណាយ តិចជាងស្ថាប័នដទៃៗ ។ អាជ្ញាធរឃុំ-សង្កាត់ត្រូវបានមើលដឹងថាមានភាពជឿជាក់ពីគ្រប់កម្រិតនៃច្បាប់។
- ដោយឡែកជនជាតិភាគតិចក៏ចូលចិត្តអាជ្ញាធរឃុំ-សង្កាត់របស់ពួកគេដែរ ដែលជាអ្នកនៅក្នុងសហគមន៍ដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយស្ត្រីជាច្រើន យល់ឃើញថា អាជ្ញាធរឃុំ-សង្កាត់នេះនៅតែមាន ភាពអយុត្តិធម៌ច្រើនជាងយុត្តិធម៌ខ្លះដែរ ។
- បញ្ហា ចម្បងជាមួយអាជ្ញាធរឃុំ-សង្កាត់គឺត្រូវបានដឹងថាពិបាកប៉ាន់ស្មានបាននូវលទ្ធផល និង មានភាពលំអៀងទៅកាន់អ្នកមាន និងអ្នកមានអំណាច។ ការចេះដឹងមិនច្បាស់លាស់ និងមិនមានសមត្ថភាពគ្រប់គ្រាន់នៃច្បាប់ក៏ត្រូវបានលើកឡើងថាមានបញ្ហាដែរដោយអ្នកតបសំភាសន៍មួយចំនួន។
- ការទៅរកអាជ្ញាធរឃុំ-សង្កាត់គឺត្រូវបានដឹងថាមានចំនួនខ្ពស់ជាង និងការអនុវត្តក៏ខ្ពស់ជាង អ្នកប្រើប្រព័ន្ធតុលាការ និង ប៉ូលីស។ មនុស្សភាគច្រើនបានយល់ឃើញទៅរកការជួយពីអាជ្ញាធរឃុំ-សង្កាត់។ ជាការពិត ១ ក្នុងចំណោមស្ត្រី ៥នាក់ និងជនជាតិភាគតិចបានទៅរកអាជ្ញាធរឃុំ-សង្កាត់។
- រឿងក្តី ចម្បង ៗដែលនាំទៅកាន់អាជ្ញាធរឃុំ-សង្កាត់គឺទាក់ទងទៅនឹងរឿងដី និង អំពើហិង្សាក្នុងគ្រួសារ។ រឿងទាំងនោះច្រើនតែបានប្តឹងទៅដោយស្ត្រី ដែលភាគច្រើន មានការទាក់ទងទៅនឹងជំលោះ អំពើហិង្សាដី និង ការលែងលះ ចំណែកឯ រឿងចំបងៗរបស់ជនជាតិភាគតិចឯណោះវិញ គឺជំលោះអំពើហិង្សាដីធ្លីផង និង ស៊ីវិលផង ។

PROJECT "UNDP-PALJR" TOPLINE REPORT
PRESENTATION - DECEMBER 2004

Page 15

តារាងទីបី ៖ ភ្នាក់ងារដែលមានយោងតាមចម្ងាយភូមិសាស្ត្រសម្រាប់អ្នកភូមិ

| ទីតាំងមូលដ្ឋាន | ភូមិ | ឃុំ | ស្រុក | ខេត្ត | ក្រុង |
|---|---|---|---|---|---|
| **ភ្នាក់ងារ(អាជ្ញាធរ) ដែលមានស្រាប់** | - មេភូមិ<br>- ចាស់ព្រឹទ្ធាចារ្យ<br>- សាច់ញាតិ បងប្អូន | - ក្រុមប្រឹក្សាឃុំ<br>- ប៉ូលីសប៉ុស្តិ៍ (នគរបាលប៉ុស្តិ៍ថ្នាក់ឃុំ) | - អភិបាលស្រុក<br>- ប៉ូលីស<br>- គណៈកម្មការសុរិយោដីស្រុក | - អភិបាលខេត្ត<br>- ប៉ូលីស<br>- ព្រះរាជអាជ្ញា<br>- តុលាការ<br>- គណៈកម្មការសុរិយោដីខេត្ត | - សាលាឧទ្ធរណ៍<br>- គណៈកម្មការ<br>- សុរិយោដីជាតិ ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ |
| **ចំងាយ ភូមិសាស្ត្រ** | **ជិតបំផុត** | **ជិតល្មម** | **ឆ្ងាយ** | **ឆ្ងាយល្មម** | **ឆ្ងាយបំផុត** |
| **ស្គាល់អាជ្ញាធរ និងនីតិវិធីច្បាស់** | ស្គាល់ច្បាស់បំផុត | ស្គាល់ច្បាស់ល្មម | ស្គាល់មិនសូវច្បាស់ | មិនស្គាល់ | មិនស្គាល់ទាល់តែសោះ |
| **ចំណាយធ្វើដំណើរ/ ចំណាយផ្សេងៗ** | តម្លៃទាប | អាចបង់បាន | ថ្លៃជាង | ថ្លៃខ្លាំងពេក | ថ្លៃខ្លាំងបំផុត |
| **ពេលវេលា** | ប្រើពេលតិច | ប្រើពេលមធ្យម | ប្រើពេលច្រើន | ប្រើពេលច្រើនពេក | ប្រើពេលច្រើនបំផុត |